ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើកទី២២**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្តារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr. Sturart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

កញ្ញា ទី ស្រ៊ីនណា

លោក យុង ផានិត

លោក គីម ម៉េងឃី

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វែ៊នណឺ

*(Mr. Alain WERNER)*

លោកស្រីអេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សីជំនាញ ៖** លោក ក្រេក អេតឆេសាន់


សួរបន្តដោយ លោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ....................ទំព័រ ៤៣
សួរដោយ លោក ហុង គឹមសួន ផ្តើមពី ....................ទំព័រ ៤៥
សួរដោយ លោក គឹម ម៉េងឃី ផ្តើមពី....................ទំព័រ ៥៤
សួរដោយ លោក គង់ ពិសី ផ្តើមពី ....................ទំព័រ ៥៧
សួរដោយ ចៅក្រម ហ្សង់ ម៉ាកឡារ៉ែន៍ ផ្តើមពី ....................ទំព័រ ៦២
សួរដោយ លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី ផ្តើមពី ....................ទំព័រ ៦៥
សួរដោយ កញ្ញា ទី ស្រ៊ុនណា ផ្តើមពី ....................ទំព័រ ៧០

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ក្រេក អេតឆេសាន់ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍ | បារាំង |
| លោកស្រី វ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[សវនាការចាប់ផ្តើមម៉ោង ០៩:១០]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ។ ជាកិច្ចដំបូងនេះអង្គជំនុំជម្រះ សូមសួរទៅជនជាប់ចោទ ថាតើជនជាប់ចោទចង់មានយោបល់អ្វីទេ អំពីឯកសារទាំងប្រាំបួន ដែលសហព្រះរាជអាជ្ញាបានដាក់ លើកឡើងដើម្បីពិភាក្សាដេញដោលចំពោះអ្នកជំនាញ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ឯកសារទាំងអស់នេះ ខ្ញុំបានឃើញ ហើយបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេតរួចហើយ នៅក្នុងកំណត់ហេតុសួរចម្លើយថ្ងៃទី៧ មេសា ២០០៨ ។ ដូច្នេះ ខ្ញុំរក្សាជំហរទាំងអស់ដែលខ្ញុំបានរាយការណ៍ជូន សហចៅក្រមស៊ើបអង្កេត ។ ក៏ប៉ុន្តែ បើលោកប្រធានឃើញបញ្ហាអីដែលចាំបាច់ឲ្យខ្ញុំបញ្ជាក់ជូនអង្គសវនាការនេះតទៅទៀត ខ្ញុំនឹងបញ្ជាក់ជូនតាមបញ្ហា ។

សូមអស់យោបល់ ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា តើមានសំណួរចង់ពាក់ព័ន្ធទៅជនជាប់ចោទដែរឬទេ? អំពីឯកសារទាំងប្រាំបួន ដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងដើម្បីសុំអង្គជំនុំជម្រះដាក់ពិភាក្សាដេញដោលទៅលើអ្នកជំនាញ ក្រេក អេតឆេសាន់ នេះ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ គឺសហព្រះរាជអាជ្ញាមានសំណួរមួយចំនួនដែលចង់សួរទៅកាន់ជាប់ចោទ ប្រសិនបើអង្គសវនាការពិចារណាថា វាជាពេលសមស្រប ខាងសហព្រះរាជអាជ្ញានឹងសួរសំណួរទៅកាន់ជនជាប់ចោទ ។ ប៉ុន្តែ ប្រសិនបើអង្គសវនាការធ្វើការគិតថា នឹងអាចអនុញ្ញាតឲ្យនៅពេលក្រោយដែលជាពេលសមស្របនោះ គឺខ្ញុំនឹងគោរពទៅតាមនុ៎ង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ដើម្បីធ្វើការសួរសំណួរមួយចំនួនទៅដល់ជនជាប់

ចោទពាក់ព័ន្ធជាមួយនឹងឯកសារទាំងប្រាំបួន ដែលសហព្រះរាជអាជ្ញាបានលើកឡើងដើម្បីពិភាក្សាដេញដោលជាមួយនឹងអ្នកជំនាញ ក្រេក អេតឆេសាន់ នេះ នាពេលនេះ ។ សូមអញ្ជើញ ។

[០៩:១៥:00]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោកប្រធាន ។

ជាបឋម គឺខ្ញុំសូមសួរទៅកាន់ជនជាប់ចោទឲ្យបញ្ជាក់ថា គាត់បានបញ្ជូនចម្លើយសារភាព ស-២១ ទៅកាន់ ស៊្វ ម៉េត តាមការស្នើសុំរបស់ ស៊្វ ម៉េត នោះ តើមែនដែរឬទេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! អត្ថបទក្នុងសំបុត្រគឺ ស៊្វ ម៉េត ទារអញ្ចឹងមែន ។ នេះជារឿងពិតពាក្យដែលសរសេរក្នុងសំបុត្រ ក៏ប៉ុន្តែនៅក្នុងសេចក្តីប្រកាសរបស់ខ្ញុំ ដែលខ្ញុំឆ្លើយបញ្ជាក់ចៅក្រមស៊ើបអង្កេតដែលស្របទៅតាមការពិត គឺរឿងស្អីក៏ដោយសុទ្ធតែឆ្លងតាមមេ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលជារបបផ្តាច់ការ ដែលយើងហៅថា អាចប្រៀបបានទៅនឹងសម័យ *ឡាតែរើ (La tereur)* នៅប្រទេសបារាំងនោះ ស្អីក៏ដោយ ក៏វាតឹងតែងច្បាស់លាស់ទៅតាមខ្សែចាត់តាំងជានិច្ចមិនដែលហ៊ានរំលងទេ ។

នៅក្នុងចម្លើយរបស់ខ្ញុំដែលរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត ក៏ខ្ញុំបាននិយាយច្បាស់ដោយលើកឧទាហរណ៍បន្ថែមមួយទៀត គឺចម្លើយសារភាពលើកទីពីររបស់ មុំ វឿន ហៅ មុន្នី កងពល ២៩០ មាននាទីអនុសេនាធំ ចុះថ្ងៃទី២៨ កុម្ភៈ ឆ្នាំ១៩៧៧ ចម្លើយនេះខ្ញុំជូនទៅដល់មេខ្ញុំលោកគ្រូ សុន សេន ។ លោកគ្រូ សុន សេន បានសរសេរជាពណ៌ក្រហមចម្លងជូន តាល់ និង ណាត ពិនិត្យនេះជារបៀបការដែលយើងខ្ញុំធ្វើមិនដែលហ៊ានរំលងមេទេ បើកាលណារំលងមេ គឺខុសនឹងការចាត់តាំងត្រូវតែមានទោស នេះជាប្រាកដ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

តើលោកអាចបញ្ជាក់ដែរឬទេថា ស៊្វ ម៉េត បានស្នើសុំពីលោកឲ្យប្រាប់គាត់ ថាអ្នកទោស មួយចំនួននៅស-២១ គឺបានផ្តល់ចម្លើយសារភាពយ៉ាងជាក់លាក់ គឺខ្ញុំយោងទៅលើឯកសារចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៧ ដែលឯកសារនេះ គឺមានលេខយោង D64 ERN00002078 ជាភាសាខ្មែរ និង 00224319 ជាភាសាអង់គ្លេស និងលេខ00238846 ជាភាសាបារាំង?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ចម្លើយរបស់ខ្ញុំបាទ ជាមួយនឹងចៅក្រមស៊ើបអង្កេត ខ្ញុំបាទបានយកឯកសារថ្ងៃ១០ សីហា នេះជាភស្តុតាងសម្រាប់បញ្ជាក់នូវអំណះអំណាងរបស់ខ្ញុំ ។ ខ្ញុំឆ្លើយពេលនោះយ៉ាងនេះ គឺខ្ញុំសូមអាន៖

[០៩:១៨:២០]

អ្វីទាំងអស់ត្រូវតែឆ្លងកាត់តាម សុន សេន ឬ នួន ជា នាពេលក្រោយមក ។ តាមពិតទៅនេះគឺជាឧទាហរណ៍នៃឧបាយកលប្រើប្រាស់ដោយ សុន សេន និង នួន ជា ដើម្បីលាក់ឈ្មោះរបស់ពួកគេតែប៉ុណ្ណោះ ។ សំបុត្រនេះ ត្រូវបានធ្វើឲ្យឃើញថា ត្រូវផ្ញើមកខ្ញុំផ្ទាល់ដោយ ស៊ួ ម៉េត ពីព្រោះ សុន សេន បានប្រាប់ទៅ ស៊ួ ម៉េត ឲ្យសរសេរបែបនេះ ។ ប៉ុន្តែ សំបុត្រនេះត្រូវបានបញ្ជូនមកខ្ញុំដោយ សុន សេន ។ ហើយខ្ញុំបានបញ្ជូនចម្លើយសារភាពទៅ សុន សេន ផងដែរ ភស្តុតាងមាននៅក្នុងឃ្លាចុងក្រោយនៃលិខិតចុះថ្ងៃទី១០ ខែសីហា ១៩៧៧ ERN00002078 ដែលមានខ្លឹមសារដូច្នេះថា " ខ្ញុំត្រូវបញ្ជូនព័ត៌មានទៅ ស៊ួ ម៉េត តាមរយៈអង្គការ" នេះខ្ញុំសូមបញ្ជាក់ថា សំបុត្រដែលសហព្រះរាជអាជ្ញាលោកលើកឡើងនេះ វាជាសំបុត្រដែលខ្ញុំបានលើកយកទៅអះអាងជូនចៅក្រមស៊ើបអង្កេតចាប់តាំងពី ថ្ងៃទី២ ខែមេសា ២០០៨ មកម្ល៉េះ ។ នេះសូមចប់ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំគិតថា លោកមិនបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទេ តើលោកអាចបញ្ជាក់បានដែរឬ ទេថា ស៊ួ ម៉េត គឺបានស្នើសុំលោកឲ្យប្រាប់ទៅគាត់ ថាតើអ្នកទោសមួយចំនួន គឺអ្នកទោស អា សាអ៊ុំ បានឆ្លើយចម្លើយសារភាពយ៉ាងជាក់លាក់ តើលោកអាចបញ្ជាក់ប្រាប់ខ្ញុំទៅលើបញ្ហានេះ ថាលោក ស៊ួ ម៉េត បានបញ្ជាក់ថាអ្នកទោសនេះ គឺបានឆ្លើយពិតប្រាកដ និងជាក់លាក់ទៅលើចម្លើយសារភាពរបស់គាត់?

**ជនជាប់ចោទ៖**

នៅក្នុងសំបុត្រថ្ងៃទី១០ ខែសីហា ១៩៧៧ នៅខាងចុង ស៊ួ ម៉េត សរសេរថា តើចម្លើយ ឈ្មោះ សាអ៊ុំ វាច្បាស់លាស់ឬក៏នាំយកចម្លើយ សែម មកពិនិត្យថែមទៀត? នេះ ស៊ួ ម៉េត សរសេរមកសួរអ៊ីចឹង ។ រឿងនេះ វាកន្លងផុតទៅច្រើនឆ្នាំហើយ បើលោកព្រះរាជអាជ្ញាចង់ច្បាស់ ខ្ញុំគិតឃើញថា ជាការល្អ គួរយកចម្លើយរបស់ឈ្មោះ សាអ៊ុំ ហើយនិងឈ្មោះ សែម មកពិនិត្យទាំងអស់គ្នាជាមុនសិន

ឬក៏ខ្ញុំសូមពេលវេលាពិនិត្យបញ្ហានេះជាមុនសិន ។ អានេះ ដើម្បីឲ្យឆ្លើយបានច្បាស់លាស់ចំពោះករណីមួយនេះ ក៏ប៉ុន្តែ បើនិយាយករណីជាទូទៅ ខ្ញុំអាចជម្រាបបានថាសំបុត្រនេះ ស៊ូ ម៉េត សរសេរនៅមុខមេមានបញ្ហាអីមេ ហើយនិង ស៊ូ ម៉េត ពិគ្រោះគ្នា ដល់ ស៊ូ ម៉េត ចេញទៅមេហៅខ្ញុំទៅក្រោយចូល មេឲ្យសំបុត្រនេះមក ហើយណែនាំឲ្យខ្ញុំធ្វើយ៉ាងនេះធ្វើយ៉ាងនោះទៀត ។ នេះសភាពការណ៍រួមគឺវាតែងតែអ៊ីចឹង បើនិយាយថា បើចង់ជ្រាបចម្លើយ សាអ៊ុំ វាយ៉ាងម៉េច? ចម្លើយ សែម វាយ៉ាងម៉េច? សភាពការណ៍ពេលនោះយ៉ាងម៉េច? យើងយកចម្លើយទាំងពីរនោះយកមកដាក់នៅលើតុទាំងអស់គ្នា ហើយពិនិត្យ ហើយទើបខ្ញុំបាទពន្យល់បាន ព្រោះរឿងវាកន្លងទៅហើយ ។ ខ្ញុំមិនចាំថា សាអ៊ុំ នៅកងណាផងណាផងឥឡូវនេះសូមជម្រាបដោយស្មោះត្រង់ ។

[០៩:២២:៤៣]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

យើងមិនចាំបាច់អានចម្លើយរបស់ សាអ៊ុំ ដើម្បីអ្នកឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទេ លោក កាំង ហ្គេកអ៊ាវ នេះគឺជាចំណុចសាមញ្ញបំផុត តើលោកអាចបញ្ជាក់បានទេថា សំបុត្រនេះដែល ស៊ូ ម៉េត ជាអ្នកសរសេរបានស្នើឲ្យលោកផ្តល់ព័ត៌មានប្រាប់គាត់ ថាតើជនជាប់ចោទសម្លួយហ្នឹងបានផ្តល់នូវចម្លើយលម្អិត ហើយនិងពិស្តារទេ នេះគឺជាសំណួរដែលខ្ញុំសួរទៅអ្នក? តើអ្នកអាចបញ្ជាក់បានទេ ថានេះគឺជាអ្វីដែលគាត់សួរអ្នកនោះ?

**ជនជាប់ចោទ៖**

រឿងនេះគាត់សួរខ្ញុំហើយពេលនោះខ្ញុំមិនដឹងជាថាខ្ញុំឆ្លើយទៅគាត់តាមរយៈមេ ឬក៏ឆ្លើយថា ម៉េចខ្ញុំមិនចាំ បើសិនជាខ្ញុំឆ្លើយ ក៏ខ្ញុំហើយនិង ស៊ូ ម៉េត មិនដែលជួបគ្នាផ្ទាល់មាត់ទេ គឺសុទ្ធតែតាមរយៈមេទាំងអស់ ។ ដូច្នេះ រឿងនេះវាភ្លេច ក៏ប៉ុន្តែ ទិដ្ឋភាពរួមនៃការធ្វើការងារគឺសុទ្ធតែតាមរយៈមេ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ជាទូទៅ នៅពេលដែល ស៊ូ ម៉េត ស្នើមកអ្នកឲ្យផ្តល់ព័ត៌មានទៅគាត់អំពី ថាតើអ្នកទោសហ្នឹងឆ្លើយសារភាពឬអត់ ឬក៏មានបណ្តាញក្បត់ដែលត្រូវបានពាក់ព័ន្ធនៅក្នុងចម្លើយសារភាពណានោះ តើពេលនុំងលោកឆ្លើយផ្ទាល់ ឆ្លើយតបទៅគាត់ឬ?

**ជនជាប់ចោទ៖**

ខ្ញុំគ្មានខ្សែទាក់ទងអីទៅ ស៊ូ ម៉េត ផ្ទាល់ទេ ។ ទូរស័ព្ទក៏គ្មាន សិទ្ធិទាក់ទងទៅ ស៊ូ ម៉េត ផ្ទាល់ ។

នីរសាររបស់ខ្ញុំក៏មិនដែលទៅកន្លែងនីរសារ ស៊ូ ម៉េត ។ បើនិយាយពីទូរស័ព្ទ តែប៉ានតែទៅហ្នឹង គឺត្រូវឆ្លងកាត់សង់ត្រាល់នៅសេនាធិការ ។ ហើយសង់ត្រាល់នៅសេនាធិការជាដៃជើងរបស់មេ ខ្ញុំអត់មានសិទ្ធិឆ្លងកាត់ទៅណោះបានទេ ។ ដូច្នេះ តាមទូរស័ព្ទក៏ មិនមាន តាមសំបុត្រ ក៏មិនមាន តាមស្អីក៏មិនមានដែរ ទាល់តែតាមរយៈមេ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំយល់ថា អ្វីដែលលោកប្រាប់មកយើងខ្ញុំហ្នឹងគឺថា លិខិតរបស់ ស៊ូ ម៉េត ដំបូងគឺឡើងទៅលោកសុន សេន មុននឹងបានមកដល់ដៃលោក ហើយឥឡូវនេះលោកក៏បានប្រាប់យើងថា ចម្លើយរបស់លោកដំបូងគឺត្រូវឡើងទៅសុន សេន មុននឹងប្រគល់ទៅឲ្យ ស៊ូ ម៉េត ។ ហើយដូច្នេះសំណួររបស់ខ្ញុំគឺថាតើលោកធ្វើការទាក់ទងជាមួយគេជាមួយ ស៊ូ ម៉េត ហ្នឹង តាមរយៈសុន សេន ឬ ក្នុងការឆ្លើយតបទៅនឹងសំណើរបស់គាត់នោះ?

[០៩:២៦:៣៦]

**ជនជាប់ចោទ៖**

សុទ្ធតែតាមរយៈមេៗ អត់មាននរណាប៉ានឆ្លងកាត់ទទឹងការងារបក្ស ការងាររដ្ឋជំនាន់នុំងផ្ទាល់ទេ ។ ទទឹងមិនបានទេ គ្រោះថ្នាក់ផុតជីវិត ទាំងពីរនាក់គ្មាននរណាប៉ានប្តូរទេ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំយល់ថា អ្វីដែលលោកប្រាប់មកខ្ញុំហ្នឹង គឺខ្ញុំនឹងយល់ ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់បន្តិច ។ នៅលើសំបុត្រចុះថ្ងៃទី១០ សីហា ឆ្នាំ១៩៧៧ នោះ ស៊ូ ម៉េត បានសួរទៅអ្នកថា តើមានអ្នកទោសជាក់លាក់ណាមួយដែលបានផ្តល់ចម្លើយលម្អិតនិងពិស្តារទេ នៅក្នុងចម្លើយសារភាពរបស់ខ្លួននោះ? ខ្ញុំយល់ថា អ្វីៗត្រូវធ្វើតាមរយៈសុន សេន ។ ប៉ុន្តែ ចម្លើយរបស់លោកទៅលើសំណួរ ថាតើលោកអាចបញ្ជាក់បានទេថា ទៅតាមការយល់ដឹងរបស់លោក គឺពីចំណេះដឹងរបស់លោក មិនមែនពីការយល់ដឹងរបស់សុន សេន ឬក៏នរណាផ្សេងនោះទេ ។ មានន័យថា គឺចម្លើយឆ្លើយតបហ្នឹងឯងគឺជាចម្លើយដែលចេញមកពីលោក ។ តើលោកអាចបញ្ជាក់ត្រង់ចំណុចនេះបានទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំស្តាប់សួរលោកមិនទាន់បានស្រួលបួលទេ សូមមានប្រសាសន៍ម្តងទៀត ។

**លោក អាឡិចសាន់ឌឺ បេ៊ិត៖**

នៅពេលដែល ស៊ូ ម៉េត សួរសំណួរមកលោក ព័ត៌មានដែលលោកឆ្លើយតបទៅនឹងសំណួរនោះ គឺលោកជាអ្នកផ្ដល់ឲ្យ មិនមែនសុន សេន ជាអ្នកផ្ដល់ព័ត៌មានឲ្យនោះទេ ។ នេះគឺជាអ្វីដែលខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចនេះ ។

**ជនជាប់ចោទ៖**

អរគុណ ។ វាពិតណាស់ហើយ សុន សេន មេខ្ញុំទាំងអស់គ្នា ទាំងមេ គាត់ជាមេ ស៊ូ ម៉េតផង ជាមេខ្ញុំផង ។ ក៏ប៉ុន្តែ រឿងល្អិត រឿងជាក់ស្តែងខ្ញុំដឹង ។ ដូច្នេះ ខ្ញុំត្រូវរាយការណ៍ជូនគាត់ ជូន សុន សេន ដូចខ្ញុំបានជម្រាបព្រះរាជអាជ្ញា ហើយនិងអង្គជំនុំជម្រះ ហើយនិងចៅក្រមស៊ើបអង្កេតពីមុនមក យើងខ្ញុំជាមួយមេជួបគ្នាតាមទូរស័ព្ទ ។ អើនិយាយថារាល់ល្ងាចទៅចុះ ។ ដូច្នេះ គ្មានរឿងអីដែលឆ្ងាយគ្នាពេកទេរវាងខ្ញុំហើយនិងមេ ។ ជួបគ្នារាល់ល្ងាច រឿងស្អីក៏គាត់សួរខ្ញុំ រឿងស្អីក៏ខ្ញុំរាយការណ៍ជម្រាបគាត់ ។ ដូច្នេះ បើមេក្ដាប់បាន គង់មេប្រាប់ ស៊ូ ម៉េត នៅក្នុងករណីដែលមេយល់ថាចាំបាច់ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។ រឿងស្អីក៏ដោយ ក៏ខ្ញុំរាយការណ៍ជូនមេ ។

**លោក អាឡិចសាន់ឌឺ បេ៊ិត៖**

ឥឡូវនេះ យើងបន្តទៀត ។ តើលោកអាចបញ្ជាក់បានទេ នៅពេលដែលលោកបានទទួលសំណើពី ស៊ូ ម៉េត គឺមានពេលខ្លះដែលលោកបានស្នើអ្នកដែលនៅក្រោមបង្គាប់របស់លោក បើនិយាយថាអ្នកសួរចម្លើយនោះ គឺឲ្យសួរចម្លើយ មានន័យថា គឺលោកបានផ្ដល់ការណែនាំទៅឲ្យអ្នកសួរចម្លើយរបស់លោក អាស្រ័យទៅតាមសំណើដែល ស៊ូ ម៉េត បានស្នើ ។ ហើយប្រហែលជាលោកអាចយោងទៅលើឯកសារដែលចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ ដែលមានលេខយោង D56 ជាភាសាខ្មែរ មានលេខ 00175362 ហើយភាសាអង់គ្លេសគឺមានលេខ 00223921 ហើយជាភាសាបារាំងមានលេខ 0019 5957 ។ ខ្ញុំនិយាយសំណួរម្ដងទៀត តើលោកអាចបញ្ជាក់បានទេ បន្ទាប់ពី ស៊ូ ម៉េត បានធ្វើសំណើមកលោក លោកបានបញ្ជាអ្នកនៅក្រោមបង្គាប់របស់លោកឲ្យធ្វើការសួរចម្លើយទៅតាមសំណើនោះ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ការងារណាបន្ទាន់ ខ្ញុំណែនាំឲ្យគេសួរភ្លាម តាមការត្រូវការចាំបាច់នៃសភាពការណ៍ដែលមេណែនាំ ។ សូមបញ្ជាក់ថា អត្ថបទដែល ស៊ូ ម៉េត សរសេរនេះ វាតំណាងឲ្យសម្ដីដែលមេបានសម្រេច ហើយណែនាំមក គ្រាន់តែយកស្លាក ស៊ូ ម៉េត ឲ្យសរសេរ

ប៉ុននុំង។ បើសិនជាលោកប្រធាន និងលោកព្រះរាជអាជ្ញាចង់ឲ្យខ្ញុំបញ្ជាក់ថាម៉េចក៏ខ្ញុំ ហើយនិងលោកគ្រូ សុន សេន យកចិត្តទុកដាក់នឹង៥០២ យ៉ាងនេះ? ខ្ញុំនឹងបញ្ជាក់ជូន ។ ហ្នឹងខ្ញុំសូមចប់ប៉ុណ្ណេះ ។

[០៩:៣២:៥៥]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

តើលោកអាចបញ្ជាក់បានទេថា ស៊ូ ម៉េត ហ្នឹងក៏បាននិយាយផងដែរនៅក្នុងសំបុត្រនេះ បញ្ជាក់អំពីបញ្ជីជនក្បត់ គឺសំបុត្រដែលចុះនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧ ដែលមានលេខយោង D57 ភាសាខ្មែរមានលេខ 00002416 និងភាសាអង់គ្លេសមានលេខ 00178066 និងភាសាបារាំងមានលេខ 00242288 ។ តើលោកកាំង ហ្គេកអ៊ាវ ឯងអាចបញ្ជាក់បានទេថា ស៊ូ ម៉េត បាននិយាយអំពីបញ្ជីឈ្មោះជនក្បត់នោះ?

**ជនជាប់ចោទ៖**

ធម្មតា តែកាលណាគេសរសេរអ៊ីចឹងហើយគេបញ្ជូនទៅហើយ មនុស្សប៉ុន្មានតាមខ្ញុំមើល ដូចនៅនេះប៉ុន្មាន ម្ភៃប្រាំបួននាក់ ។ ដើមកំណើតវា ពួកនេះមកពីកងពល៣១០ និង៤៥០ ដូច្នេះគេបញ្ជូនទៅ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

អ៊ីចឹងបើសិនជាខ្ញុំយល់ដឹងមិនខុសនោះ គឺថាបញ្ជីជនក្បត់នេះ គឺបានចងក្រងឡើងដោយ ស៊ូ ម៉េត ដោយការចងក្រងនេះ គឺបន្ទាប់ពីលោកបានបញ្ជូនចម្លើយសារភាពរបស់អ្នកនៅកងពល៥០២ ដទៃទៀតដែរ ដែលជាខ្មាំងនោះ ។ មានន័យថានោះគឺជាចម្លើយសារភាពរបស់ ស-២១ ដែលលោកបានបញ្ជូនទៅនោះ ។

**ជនជាប់ចោទ៖**

ត្រឹមត្រូវហើយ ខ្ញុំគ្រាន់តែបញ្ជាក់ថា ចម្លើយដែលចេញពីស-២១ គឺខ្ញុំជូនអត់ទៅដៃ ស៊ូ ម៉េត ទេ គឺទៅដៃមេខ្ញុំ ។ មេខ្ញុំឲ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល៥០២ ប្រភពដើមមកពី៣១០ និង៤៥០ ទៅតាមសេចក្តីសម្រេចចិត្តរបស់មេ ។ ដូច្នេះ វាត្រូវតែឆ្លងអ៊ីចឹង ។ បើយើងកាត់អាកណ្តាលហ្នឹងចោល វាអត់បានការទេ ស្តាប់មិន ស្តាប់គ្នាមិនបានទេ ។ វាត្រូវមានកណ្តាលហ្នឹងមួយ គឺមេ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

យើងសន្មតថាឯកសារទាំងប្រាំបួន ដែលជាឯកសារដែលខាងសហព្រះរាជអាជ្ញាមាននេះ ដែលជាសំបុត្ររបស់ ស៊ូ ម៉េត ផ្ញើមកលោកនោះ គឺមិនមែនជាគ្រាន់តែជាសំបុត្រ ឬដែលលោក ស៊ូ ម៉េត ទាក់ទងលោកទេ មែនទេ? ពីព្រោះនៅក្នុងសំបុត្រដែលយើងពិនិត្យមើលនេះ ស៊ូ ម៉េត បាននិយាយយោងទៅលើបញ្ជីឈ្មោះជនក្បត់ ដែលគាត់រៀបរាប់ថា ត្រូវបានបញ្ជូនទៅឲ្យលោកនៅពីពេលមុន គឺនៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ១៩៧៧ ។ ឥឡូវនេះ ខ្ញុំចង់សួរលោកថា ថាតើក្នុងមួយសប្តាហ៍លោកទទួលបានការទាក់ទងពីសុន សេន ចំនួនប៉ុន្មានដង នៅពេលដែលពួកគេធ្វើការចាប់ផ្តើមបញ្ជូន ហើយនិងនៅពេលណាដែលគេបានបញ្ចប់ការទាក់ទងបែបនេះ ។ ខ្ញុំសូមទោស គឺទំនាក់ទំនងរវាង ស៊ូ ម៉េត មកលោក មិនមែន សុន សេន ទេ ។

[០៩:៣៧:៤៧]

**ជនជាប់ចោទ៖**

រឿង ស៊ូ ម៉េត និងខ្ញុំ សូមជម្រាបប្រសាសន៍លោកប្រធាន មិនមានជាមានកម្មវិធីអី ជួបគ្នាធ្វើការជាមួយគ្នាដោយមានកម្មវិធីច្បាស់លាស់ទេ ។ ឯចំណែកមេខ្ញុំ ហើយនិងខ្ញុំ ជួបគ្នារាល់ល្ងាចតាមទូរស័ព្ទ ស្ទើរតែរាល់ល្ងាចតាមទូរស័ព្ទ ។ ពីរបីថ្ងៃគាត់ហៅខ្ញុំទៅជួបម្តង ។ នេះជារឿងជាមួយមេ ។ ឯចំណែកជាមួយ ស៊ូ ម៉េត មេជួប ស៊ូ ម៉េត ប៉ុន្មានថ្ងៃម្តង ជួបតាមទូរស័ព្ទយ៉ាងម៉េច អានេះជារឿងមេហើយនិង ស៊ូ ម៉េត ។ ក៏ប៉ុន្តែ រឿងអីដែលមេត្រូវឲ្យខ្ញុំទទួលបញ្ជាពីគាត់ឲ្យជួយខាងកងពល៥០២ អាហ្នឹងមេបញ្ជាមកខ្ញុំ ទោះបីសំបុត្រនុំងចេញពី ស៊ូ ម៉េត ក៏ដោយ ក៏មេឲ្យ ស៊ូ ម៉េត សរសេរហើយស្រេច ។ នេះខ្ញុំបញ្ជាក់ដដែលហើយដដែលទៀត ។ រឿងវានៅត្រឹមប៉ុននុំង ។ យើងខ្ញុំទាំងពីរនាក់គ្មានការទាក់ទងទទឹងទេ ផ្ទាល់ទេ រវាងការងាររដ្ឋនិងការងារបក្ស ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ទៅតាមការលើកឡើងម្តងហើយម្តងទៀត រវាងលោក គឺដែលលោកបញ្ជាក់ថា អ្វីៗហ្នឹងទាក់ទងតាមរយៈមេរបស់លោក សុន សេន ហ្នឹងគឺច្បាស់លាស់ហើយ ប៉ុន្តែ សំណួររបស់ខ្ញុំនេះគឺថាតើភាពញឹកញាប់ហ្នឹងវាយ៉ាងម៉េចដែរ នៅពេលដែលលោកបានទទួលសំបុត្រពី ស៊ូ ម៉េត នោះ? ហើយនៅពេលណាទៅដែលសំបុត្រហ្នឹងបានចាប់ផ្តើម? តើនៅឆ្នាំ១៩៧៥ ឬ? ឬក៏ឆ្នាំ១៩៧៦? ហើយតើការប្រាស្រ័យទាក់ទងតាមរយៈសំបុត្រនេះ វាបន្តរហូតដល់ពេលណាដល់ចុងឆ្នាំ១៩៧៨ ឬក៏ដើមឆ្នាំ១៩៧៩?

ហើយតើ ស៊ូ ម៉េតបានសរសេរលិខិតនេះមកឲ្យលោកផ្ទាល់ហ្នឹងជាញឹកញាប់ដែរឬក៏អត់?

[០៩:៤០:០០]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះដូចជាស្រួលយល់ ។ សំបុត្រដែលខាងការិយាល័យចៅក្រមស៊ើបអង្កេតប្រគល់មកឲ្យខ្ញុំមាន៩ នេះ វាចាប់ផ្ដើមពីថ្ងៃ១ ខែមេសា ឆ្នាំ១៩៧៧ ។ ហើយវាចប់នៅថ្ងៃ៤ ខែតុលា ឆ្នាំ១៩៧៧ ។ សំបុត្រពីមុនៗមក ឬមាន ឬអត់ ខ្ញុំអត់ច្បាស់ទេ ក៏ប៉ុន្តែចុងបញ្ចប់សំបុត្រមាននៅថ្ងៃ៤ ខែ១០ នេះ ខ្ញុំអាចអធិប្បាយបាន ។ ខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រមស៊ើបអង្កេតហើយ មេខ្ញុំគឺលោកគ្រូ សុន សេន បែកពីខ្ញុំនៅថ្ងៃ១៥ ខែសីហា ១៩៧៧ ។ គាត់អញ្ជើញទៅសមរភូមិមុខ ។ ពូ នួន ចុះមកគ្រប់គ្រងខ្ញុំ ។ ខ្ញុំស្មានថាលោកគ្រូ សុន សេន ដាច់ពីការងារនគរបាល ការងារសន្តិសុខ ការងារនគរបាល ការងារសន្តិបាល ។ ក៏ប៉ុន្តែ ឯកសារដែលនៅសល់ជាពិសេសឯកសារជាចម្លើយសារភាពរបស់ឈ្មោះ ឡុង មុយ ហៅ ជួន ខ្ញុំឃើញមេខ្ញុំស៊ីញ៉េ នៅថ្ងៃ១១ ខែវិច្ឆកា ឆ្នាំ១៩៧៧ ។

ដូច្នេះ ការងាររបស់គាត់វានៅ ការងារខាងសន្តិបាលរបស់គាត់វានៅ ក៏ប៉ុន្តែគ្រាប់តែគាត់បែកពីខ្ញុំ នួន ជា, ពូ នួន ចុះមកជួបជំនួស ។ ដូច្នេះ លិខិតថ្ងៃ៤ ខែ១០, ៧៧ នេះប្រហែលជាសំបុត្រចុងក្រោយរបស់ ស៊ូ ម៉េត មកខ្ញុំមែន តាមរយៈលោកគ្រូ សុន សេន ហើយដែលផ្ញើតាម ពូ នួន មក ។ ហើយដល់ក្រោយមកមិនដឹងផ្លាស់ថ្នាក់ដឹកនាំយ៉ាងម៉េចទេ ខ្ញុំលែងបានទទួលសំបុត្ររបស់ ស៊ូ ម៉េត ទៀត ។

ដូច្នេះ សរុបមកសំបុត្រដែលយើងនៅសល់ គឺមានសំបុត្រពីថ្ងៃ១ ខែសីហា ១៩៧៧ រហូតមកដល់ថ្ងៃ៤ ខែតុលា ១៩៧៧ ។ នេះលិខិតដែលយើងនៅសល់ ដែលយើងយកមកជជែកគ្នានៅថ្ងៃនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ហាក់ដូចជាមិនបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទេ គឺខ្ញុំសូមលើកឡើងសំណួរនេះឲ្យបានស្រួលបន្តិច ។ យើងនៅសល់លិខិតចំនួនប្រាំបួន ដែលលិខិតនោះជារបស់ ស៊ូ ម៉េត ផ្ញើជូនលោក ។ សំបុត្រដែលយើងទទួលបានដំបូង គឺថ្ងៃ១ ខែមេសា ឆ្នាំ១៩៧៧ ។ សំណួរទីមួយ ថាតើលោកមានការទាក់ទងជាលាយលក្ខណ៍អក្សរ ទទួលការទាក់ទង លិខិតទាក់ទងជាលាយលក្ខណ៍អក្សរពី ស៊ូ ម៉េត មុនថ្ងៃ១ ខែមេសា ឆ្នាំ១៩៧៧ ដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបាននិយាយអំមិញដែរ ខ្ញុំអត់ចាំទេ មិនដឹងជាមាន ឬគ្មាន មិនចាំ ។ ប៉ុន្តែ ភស្តុតាងដែលនៅសល់ គឺវាចាប់ផ្តើមពីថ្ងៃ១ មេសា ១៩៧៧ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ដូចដែលលោកបានប្រាប់យើងច្រើនដងហើយថា សុន សេន ទៅសមរភូមិមុខនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ តើលោកអាចបញ្ជាក់ដែរឬទេថា លិខិតទាំងពីរដែលនៅសល់នេះ គឺបានចុះកាលបរិច្ឆេទក្រោយថ្ងៃ១៥ ខែ៨ ឆ្នាំ១៩៧៧ គឺបានន័យថា ចុះថ្ងៃទី៣ តុលា និង៤ តុលា ឆ្នាំ១៩៧៧ តើមែនដែរឬទេចំពោះលិខិតពីរនុ៎ង?

[០៩:៤៥:៣២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន, ខ្ញុំគិតថា យើងមិនគួរសួរសំណួរជាន់គ្នាដដែលៗនោះទេ ។ សហព្រះរាជាអាជ្ញាគឺបានសួរសំណួរបីដងដដែលៗ ហើយគឺគាត់រង់ចាំទៅលើចម្លើយ ប៉ុន្តែ សហព្រះរាជអាជ្ញាមិនអាចសរសេរប្រវត្តិសាស្ត្រឡើងដោយខ្លួនឯងនោះទេ ហើយលោកសួរថា តើមានលិខិតមុនថ្ងៃ១៥ ដែរឬទេ? មុនថ្ងៃ១ មេសា ដែរឬទេ? គាត់បានឆ្លើយហើយថា អត់ចាំ ហើយលោកសហព្រះរាជអាជ្ញាសួរឡើងវិញទៀត ។ ហើយជនជាប់ចោទនិយាយថា បញ្ជាក់លើបញ្ហានេះ ហើយជនជាប់ចោទបានបញ្ជាក់ហើយថា សុន សេន បានទៅសមរភូមិមុខនៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ ។ ហើយគឺបន្ទាប់ពីថ្ងៃហ្នឹង គឺគាត់បន្តការងារបន្តិចទៀត ហើយគាត់បានឆ្លើយតបទៅលើបញ្ហាទាំងអស់នោះហើយ ។ ហើយខ្ញុំហាក់ដូចជាមិនសូវយល់ សហព្រះរាជអាជ្ញាដូចជាបានដឹងរឿងហ្នឹង គឺហាក់ដូចជាបានដឹង ចោទសួរបញ្ហាហ្នឹងច្រើន ហើយគឺថា ជនជាប់ចោទគាត់អាចដឹងនៅលើ មិនអាចដឹងច្រើនដូចអ្វីដែលយើងចង់ដឹងនោះទេ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

គឺសូមធ្វើការថ្លែងអំណរគុណចំពោះពាក្យរបស់ខាងមេធាវីការពារក្តី និងការលើកទឹកចិត្តរបស់គាត់ ។ ខ្ញុំនឹងធ្វើការបន្តសំណួររបស់ខ្ញុំ ។ សំណួរដែលខ្ញុំហៀបនឹងសួរទៅកាន់ជនជាប់ចោទនោះ គឺថា លិខិតចំនួនពីរ បន្ទាប់ពី សុន សេន ទៅសមរភូមិមុខ គឺផ្ញើមកពី ស៊្វ ម៉េត គឺទៅកាន់ជនជាប់ចោទ គឺលិខិតទាំងពីរនោះ គឺបានចុះនៅថ្ងៃ៣ និងថ្ងៃ៤ ខែតុលា ។ ថាតើនេះគឺជាភស្តុតាងរបស់លោកដែរឬទេ ថាលិខិតទាំងពីរនេះវាត្រូវឆ្លងតាមរយៈ សុន សេន ដែរឬក៏យ៉ាងម៉េច?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានអត្ថធិប្បាយជម្រាបអំមិញហើយថា មេខ្ញុំ លោកគ្រូ សុន សេន អញ្ជើញទៅសមរភូមិមុខទៅមកៗ បែកពីខ្ញុំនៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ ហ្នឹងដែលគាត់បែកពីខ្ញុំ ។ ក៏ប៉ុន្តែ បើសិនជាយើងយកចម្លើយ ឡុង មុយ ហៅ ជួន យកមកពិនិត្យ ខ្ញុំឃើញហត្ថលេខាមេខ្ញុំនៅលើចម្លើយនេះ នៅថ្ងៃ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ដូច្នេះ មេខ្ញុំនៅតែកាន់កាប់កិច្ចការហ្នឹងហ្នឹងទីមួយ ។ ទីពីរ សម័យកាលស៊ើបអង្កេត ខ្ញុំបានរាយការណ៍ជូនចៅក្រមស៊ើបអង្កេត ហើយថាមេខ្ញុំទាក់ទងនឹងខ្ញុំតាមទូរស័ព្ទពីអ្នកលឿងមក កន្លះខែម្តង យ៉ាងយូរណាស់មួយខែម្តងជានិច្ច ។

ដូច្នេះ មេខ្ញុំអត់ដាច់ពីខ្ញុំ សួរថាមេខ្ញុំដាច់ពី ស៊ូ ម៉េត ទេ? ស៊ូ ម៉េត នៅក្នុងគណៈកម្មាធិការសេនាធិការ ។ រឿងការងារគេផ្សេង ទោះបីទៅដល់ណាក៏ដោយ គេមិនដាច់គ្នាទេ គណៈកម្មាធិការគេជាមួយគ្នា ។ ឯចំណែកខ្ញុំ ពូ នួន មកគ្រប់គ្រងខ្ញុំ ។ ដូច្នេះ សំបុត្រមកពី ស៊ូ ម៉េត ចូលទៅដល់ សុន សេន ក៏គង់តែចូលទៅដល់ ពូ នួន ។ ផ្ញើមកខ្ញុំតាមរយៈមិត្ត ទៀង តាមរយៈ មិត្តជីវ ។ និរសារពីរនាក់នេះមកផ្ទះខ្ញុំញ៉ឹកញាប់ ។ ពូ នួន ក៏ហៅខ្ញុំទៅធ្វើការញ៉ឹកញាប់នៅពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត ។ ដូច្នេះ យើងខ្ញុំទាំងពីរនាក់ គឺខ្ញុំ កាំង ហ្កេកអ៊ាវ ហៅ ឌុច ហើយនិង ស៊ូ ម៉េត គ្មានរឿងអីទាក់ទងគ្នា ទទឹងខ្សែបានទេ ។ នេះសូមបញ្ជាក់ម្តងទៀត ។

ដូច្នេះ សំបុត្រដែលមានលេខ ដែលចុះថ្ងៃទី៣ តុលា ហើយនិងសំបុត្រចុះថ្ងៃទី៤ តុលា គឺពិតជាមកបានខ្សែចាត់តាំងច្បាស់លាស់ គឺ សុន សេន, នួន ជា បានមកដល់ខ្ញុំ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំសូមត្រឡប់ទៅលើការពន្យល់ដែលលោកបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត ហើយដែលលោកបាននិយាយឡើងវិញនៅចំពោះមុខអង្គសវនាការ ។ ជាពិសេសនោះ គឺមានប្រយោគមួយដែលវាមានការចាប់អារម្មណ៍ចំពោះយើងខ្ញុំ ។ លោកបាននិយាយថា សុន សេន បានស្នើសុំ ស៊ូ ម៉េត ឲ្យធ្វើការព្រៀងលិខិតនោះ ដែលលិខិតនោះត្រូវបាន ស៊ូ ម៉េត ផ្ញើជូនលោកនៅក្រោយមក ។ ថាតើលោកនៅរក្សាការលើកឡើងដូច្នេះទេ នៅថ្ងៃនេះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានឃ្លាត្រង់នេះជាភាសាខ្មែរ ដែលមាននៅក្នុងកំណត់ហេតុសួរចម្លើយថ្ងៃទី២ មេសា ២០០៨ ហើយសុំបកប្រែម្តងទៀតចុះ ។ មិនមែនអីចឹងទេ អ្វីទាំងអស់

ត្រូវតែឆ្លងកាត់ សុន សេន ឬ នួន ជា នាពេលក្រោយមក ។ តាមពិតទៅនេះជាឧទាហរណ៍មួយនៃឧបាយកលប្រើប្រាស់ដោយ សុន សេន និង នួន ជា ដើម្បីលាក់ឈ្មោះរបស់ពួកគេតែប៉ុណ្ណោះ ។ សំបុត្រនេះត្រូវបានធ្វើឲ្យឃើញថា ត្រូវបានផ្ញើមកខ្ញុំដោយ ស៊ូ ម៉េត ពីព្រោះ សុន សេន បានប្រាប់ទៅ ស៊ូ ម៉េត ឲ្យសរសេរបែបនេះ ប៉ុន្តែ សំបុត្រនេះត្រូវបានបញ្ជូនមកឲ្យខ្ញុំដោយ សុន សេន ហើយខ្ញុំត្រូវតែបញ្ជូនចម្លើយសារភាពទៅ សុន សេន ដែរ ។

នេះខ្ញុំសូមអានឡើងវិញ ហើយខ្ញុំពិតជារក្សាសេចក្តីអះអាងរបស់ខ្ញុំជូនសហចៅក្រមស៊ើបអង្កេតដាច់ខាត អត់កែប្រែ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ។

[០៩:៥១:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីគោលបំណងនៃប្រតិចារឹកនៅក្នុងនីតិវិធីរបស់យើង លោកអាចលើកចំណុចឯកសារយោងទៅលើឯកសារដែលលោកបានលើកឡើង និងលេខERN បានដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម លេខកូដ D68 ឯចំណែក ERN ជាភាសាបារាំង 00195945 ដល់លេខ 00195958 ។ ជាអង់គ្លេសលេខ 00178058 ដល់ 00178070 ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងអាចផ្តល់លេខទំព័រដល់អស់លោក លោកស្រីផងដែរ ដែលវាអាចសំខាន់នៅត្រង់នេះដែរ ។ ទំព័រឯកសារបារាំង លេខERN នៅក្នុងទំព័រនោះគឺលេខ 00195947 គឺទំព័រលេខ៣ នៅក្នុងឯកសារបារាំង នៃឯកសារ D68 ។

**លោក អាឡិចសាន់ឌឺ ប៊ិត៖**

ដើម្បីឲ្យយើងយល់ឲ្យបានច្បាស់លាស់ និងពេញលេញនោះ លោក កាំង ហ្គេកអ៊ាវ លោកមិនបានស្នើឡើងថា លិខិតរបស់ ស៊ូ ម៉េត គឺត្រូវបានហៅឲ្យសរសេរដោយ សុន សេន ។ បានន័យថា សុន សេន ជាអ្នកហៅឲ្យសរសេរ ។ អ៊ីចឹងដែលខ្ញុំយល់ដែរឬទេ ទៅលើចំណុចហ្នឹង?

[០៩:៥៥:១០]

**ជនជាប់ចោទ៖**

បញ្ហានេះគឺគេ គេធ្វើការជាមួយនឹងគ្នា មុននឹងហៅខ្ញុំទៅធ្វើការ ដើម្បីនឹងជួយសម្រួលការងារខាងសន្តិបាល ។ ខ្ញុំជឿថាមិនមែនជាការហៅថាមួយម៉ាត់ទៅមួយម៉ាត់ ដូចយើងសរសេរតាមសូត្រនៅពីក្មេងទេគឺ សុន សេន គេឲ្យគំនិត ហើយ ស៊្វ ម៉េត អ្នកសរសេរ ។ ទន្ទឹមនេះ ខ្ញុំចង់ជូនភស្តុតាងមួយដល់លោកប្រធានដែរ ។ លោកប្រៀបធៀបមើលសំបុត្រដែល ស៊្វ ម៉េត សរសេរមកខ្ញុំ ។ សំបុត្រថ្ងៃ០១ ខែ០៦ ឆ្នាំ១៩៧៧ ថ្ងៃសំបុត្រសរសេរមកថ្ងៃនោះមានពីរ ។ សំបុត្រទីមួយវាយម៉ាស៊ីន វាយអង្គុលីលេខ សំបុត្រទីពីរ ស៊្វ ម៉េត សរសេរដៃ ចុះម៉េចក៏មួយថ្ងៃសំបុត្រដល់ទៅពីរ? នេះបញ្ហាចោទហើយ ។ នេះខ្ញុំគ្រាន់តែសូមពន្យល់ទៅតាមការយល់ដឹងរបស់ខ្ញុំទេ ។ សេចក្ដីសម្រេចពីមុនមកសំបុត្រ ស៊្វ ម៉េត ឲ្យគេវាយម៉ាស៊ីននៅការិយាល័យរបស់ ស៊្វ ម៉េត ។ ដល់ សុន សេន ហៅមកធ្វើការជួបបញ្ហាមួយទៀត មេណែនាំឲ្យ ស៊្វ ម៉េត សរសេរសំបុត្រមួយទៀត នៅវេលាម៉ោងពីរកន្លះ ខ្ញុំបានបញ្ជូន ស៊ុន ហេង តាមចម្លើយរបស់ ម៉ៅ ។ ដូច្នេះ បញ្ហាវាអ៊ីចឹង ។ វាមានបញ្ហា វាមានសេចក្ដីសម្រេច វាមានការណែនាំឲ្យសរសេរ ជូនអីសរសេរសំបុត្រមួយថ្ងៃពីរក៏មានដែរ ។ សូមជម្រាបជូនលោកប្រធាន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

នៅក្នុងបញ្ជីឈ្មោះអ្នកទោសរួម ហើយនៅក្នុងឯកសារវិភាគ ដែលបានធ្វើឡើងគឺវាបង្ហាញឃើញថា យ៉ាងហោចណាស់មានមនុស្សចំនួន២៩៩នាក់ ត្រូវបានចាប់ខ្លួនពីកងពល៥០២ ហើយត្រូវបានគេបញ្ជូនទៅស-២១ ។ ដើម្បីឲ្យខ្ញុំអាចយល់នោះ តើលោកនិយាយថាក្នុងចំណោម២៩៩នោះ គឺអ្នកទាំងនោះម្នាក់ៗគឺ សុន សេន ធ្វើការស្រាវជ្រាវអំពីខ្សែក្បត់ ហើយនិងមូលហេតុដែលត្រូវបញ្ជូនគេទាំងអស់នោះទៅស-២១ ឬក៏ សុន សេន ជាអ្នកធ្វើការយល់ស្របទៅលើសេចក្ដីសម្រេចរបស់លោក និងស៊្វ ម៉េត តែប៉ុណ្ណោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! របៀបធ្វើការនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសខាងការចាប់ចង សម្រេចចាប់ចង ខ្ញុំសូមជម្រាបរឿងជាក់ស្ដែង ដែលយើងខ្ញុំបានធ្វើដូចតទៅ៖

សេចក្ដីសារភាព ដែលខ្ញុំបានជូនទៅ សុន សុន, សុន សេន មើលពិចារណា ។ នេះជាខ្សែចាត់តាំងរបស់ខ្ញុំ ដែលខ្ញុំអនុវត្តន៍តាមសេចក្ដីសម្រេចអចិន្ត្រៃយ៍ប្រជុំថ្ងៃ០៩ តុលា មេខ្ញុំគឺ សុន សេន ។ ឯ

ចំណែក ស៊្វ ម៉េត ធ្វើការជាមួយ សុន សេន តាមគោលគារណ៍នៃសេចក្ដីសម្រេចចិត្តថ្ងៃ៣០ មីនា ដាច់ដោយឡែករបស់គេ ។ ដូច្នេះ ខ្ញុំបញ្ជូនទៅ ឯកសារខ្ញុំបញ្ជូនទៅ សុន សេន ពិនិត្យ ។ ពិនិត្យហើយហៅ ស៊្វ ម៉េត មកធ្វើការជាមួយ គួរយកអាណា មិនគួរយកអាណា គេរួមគ្នាសម្រេចនៅទីនោះ ។ ដូច្នេះ មូលដ្ឋានសម្រាប់ចាប់នោះគឺ កងពល៥០២ ឯណោះ អ្នកសម្រេចរួមពីលើគឺ សុន សេន ។ ឯអ្នកផ្ដល់ព័ត៌មានជាក់លាក់ឲ្យ សុន សេន ពិចារណាគឺ ស៊្វ ម៉េត ។ ឯចំណែកឯកសារពីស-២១ សម្រាប់ជូនជាព័ត៌មានថា ឥឡូវឈ្មោះនេះខ្លាំងឆ្លើយដាក់ហើយ នេះប៉ុន្នឹង នេះរបៀបធ្វើការរបស់យើងខ្ញុំ ។ នេះខ្ញុំសូមជូនពីរបៀបធ្វើការរបស់យើងខ្ញុំវិញ វាមិនចំនឹងចម្លើយដែលលោកសហព្រះរាជអាជ្ញាលោកសួរខ្ញុំទេ ។ ខ្ញុំសូមរាយការណ៍ជូនអំពីរបៀបធ្វើការដែលយើងខ្ញុំធ្វើ រាប់ឆ្នាំនៅមួយគ្នានេះ គឺរបៀបហ្នឹង ។

[១០:១៦:២១]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ឥឡូវនេះ យើងពិនិត្យមើលឯកសារចុងក្រោយមួយទៀត បើសិនជាយើងមើលមួយភ្លែតទៅយើង អាចនិយាយថា ស៊្វ ម៉េត បានមានគំនិតផ្ដួចផ្ដើម គឺខ្ញុំនិយាយអំពីសំបុត្រចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ៧៧ ដែលយើងមាននេះ ។ ឯកសារនេះមានលេខ D64 00002423 ជាភាសាខ្មែរ និងមានលេខ 00002409 ភាសាអង់គ្លេស និងមានលេខ 00238845 ជាភាសាបារាំង ។ ហើយខ្ញុំចង់ឲ្យដាក់ឯកសារនេះចាក់បញ្ចាំងតាមអេក្រង់ បើសិនជាលោកប្រធានអាចអនុញ្ញាត ដើម្បីបង្ហាញអំពីនូវឃ្លាមួយដែលយើងខ្ញុំចាប់អារម្មណ៍ ។ ខ្ញុំសូមឲ្យលោកប្រធានមេត្តាអនុញ្ញាតឲ្យខាងផ្នែកសោតទស្សន៍បញ្ចាំងអេក្រង់ដែលមានអត្ថបទនេះ តាមរយៈកុំព្យូទ័ររបស់ខាងសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាតឲ្យផ្នែកសោតទស្សន៍ ធ្វើការភ្ជាប់ប្រព័ន្ធមកកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ដើម្បីបញ្ចាំងនូវឯកសារមួយ ដើម្បីពិនិត្យទាំងអស់គ្នានៅក្នុងអង្គសវនាការនេះ តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន គឺយើងមានដាក់នៅក្នុងប្រអប់ពណ៌ក្រហមនូវអត្ថបទ ហើយអត្ថបទដែលយើងដាក់នេះ គឺនៅផ្នែកពាក់កណ្ដាលខាងក្រោមនៅក្នុងប្រអប់នេះ ប៉ុន្តែ ខ្ញុំឬក៏សហសេវិករបស់ខ្ញុំមិនអានជាភាសាខ្មែរ។ អ៊ីចឹងខ្ញុំមិនដឹងថាតើនឹងចាប់ផ្ដើមនៅពីពេលណាទេ ។ សូមឲ្យរង់ចាំមួយបន្តិចមួយភ្លែត។

សូមអរគុណ។ គឺថា យើងបានបញ្ជាក់ហើយ សូមលោកប្រធានអនុញ្ញាតឲ្យក្រឡាបញ្ជីធ្វើការអានអត្ថបទ ដែលមាននៅក្នុងប្រអប់ពណ៌ក្រហមនេះ ។

[១០:០៣:២២]

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី អាននូវអត្ថបទដែលមាននៅក្នុងបន្ទាត់រង្វង់ពណ៌ក្រហម មានចំនួនបីបន្ទាត់ជាផ្នែកមួយនៃអត្ថបទ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ឈ្មោះនេះ មិនទាន់ឃើញមានខ្មាំងណាម្នាក់សារភាពនៅឡើយដែរ ប៉ុន្តែ សកម្មភាពឈ្មោះនេះតាមខ្ញុំពិនិត្យផ្ទាល់ ថាវាជាខ្មាំងតែម្តង ព្រោះឈ្មោះនេះធ្លាប់រស់នៅក្នុងមន្ទីរកងពលមួយរយៈដែរ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សូមអរគុណ លោកប្រធាន ។ សូមលោកប្រធានអនុញ្ញាតឲ្យខាងផ្នែកសោតទស្សន៍បញ្ចាំងនូវរូបភាពធម្មតាលើអេក្រង់វិញ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកសោតទស្សន៍ត្រឡប់ទៅប្រក្រតីភាព នៃរូបភាពតាមធម្មតាវិញ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សំណួររបស់ខ្ញុំហ្នឹងគឺថា អត្ថបទដែលទើបតែបានអានអម្បាញ់មិញនេះ ដូចជាស្នើឡើងថា ស៊ូ ម៉េត បានធ្វើសេចក្តីសម្រេចចិត្តថា មនុស្សដែលគាត់បានពិនិត្យរួចហើយហ្នឹង គឺជាខ្មាំង ទោះបីជាមិនមានចម្លើយសារភាពណាឆ្លើយដាក់លើបុគ្គលនោះក៏ដោយ ។ តើលោកអាចបញ្ជាក់បានទេ នេះគឺជាវិធីឬក៏របៀបដែល ស៊ូ ម៉េត ឬក៏លោកអ្នកអនុវត្តនៅក្នុងការងាររបស់ខ្លួននោះ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! រឿង គឹប រ៉ឹក ដែល ស៊ូ ម៉េត សរសេរទៅនេះ វានៅតែជារឿងដដែលៗ គឺមេជាអ្នកសម្រេច ។ ឯចំណែករឿងនេះ វាគ្រាន់តែមានសេចក្តីរាយការណ៍របស់ ស៊ូ ម៉េត តាមការអនុញ្ញាតរបស់មេឲ្យផ្តល់ប្រវត្តិរូបច្បាស់លាស់ឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំស្រួលធ្វើការថា ឈ្មោះ គឹប រ៉ឹក នេះ គ្មាននរណាទាន់ឆ្លើយដាក់ទេ ។ ក៏ប៉ុន្តែ មនុស្សនេះធ្លាប់លេងភ្លេងជាមួយនឹង ថាច់ សាលី, ថាច់ សាលី ហ្នឹងជាអ្នកភ្លេងហ្សាស់ អ៊ំ ភ្លេង ន៉ៃ ញាក់ត្រគ្រាក់ត្រគ្រើកកាលពីជំនាន់មុន ។ នេះខ្ញុំសូមបន្ថែម

ថាច់ សាលី នោះខ្ញុំធ្លាប់ឮឈ្មោះ ។ ហើយក្រោយមក មករស់ជាមួយឈ្មោះ សំ អុន ៨០១ ក៏ជាសមាសភាពដែលគេចាប់អារម្មណ៍ ហើយចាប់រួចទៅហើយក៏មិនដឹង ។ ហើយសេរីណាស់ ដើរហើរក្ដាប់មិនបាន ។

[១០:០៦:៣៤]

ដូច្នេះ ការដែលសេរីនៅក្នុងអង្គភាពនេះគឺ ស៊្វ ម៉េត ត្រូវតែរាយការណ៍ជូនមេ ។ រឿងនេះ គឹប រ៉ឹក ចាប់ទៅហើយឬនៅ ខ្ញុំជឿថា ក្នុងសេចក្ដីសំបុត្រនេះបញ្ជាក់ថា គឹប រ៉ឹក ចាប់ហើយ ។ មេគ្រាន់តែបញ្ជាឲ្យ ស៊្វ ម៉េត សរសេរមកដើម្បីឲ្យខ្ញុំច្បាស់ស្រួលធ្វើការ ស្រួលជំរុញការសួរចម្លើយឲ្យឆាប់ ។

នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង តាមការយល់ឃើញ វិភាគលើឯកសារនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ប៉ុន្តែនេះមិនមែនជាអ្វី ដែលមាននៅក្នុងសំបុត្រនេះទេ លោក កាំ ហ្គេកអ៊ាវ ប៉ុន្តែក្នុងសំបុត្រនេះគេនិយាយថា ខ្ញុំ ស៊្វ ម៉េត បានពិនិត្យមើលជននេះហើយ ហើយបានសម្រេចថា គាត់ហ្នឹង គឺជាខ្មាំង ។ សំណួររបស់ខ្ញុំនោះគឺថា តើលោកអាចបញ្ជាក់បានទេ ថាតើនេះគឺជាវិធីដែល ស៊្វ ម៉េត ហើយនិងខ្លួនលោកផ្ទាល់បានប្រើ?

**ជនជាប់ចោទ៖**

ខ្ញុំបានបញ្ជាក់ជូនលោកសហព្រះរាជអាជ្ញារួចហើយ លោកប្រធាន ។ ការងារអីក៏ដោយ ខ្ញុំហើយនិង ស៊្វ ម៉េត មិនដែលនិយាយគ្នាទេ ។ រឿងដែលសម្រេចឲ្យចាប់ឈ្មោះ គឹប រ៉ឹក នេះមិនមែនជា ស៊្វ ម៉េត ម្នាក់ឯងប៉ានធ្វើទេ ត្រូវតែមានមេជាអ្នកសម្រេច ។ ឯចំណែករឿងសំបុត្រនេះសរសេរឲ្យខ្ញុំ ក៏ដើម្បីសម្រួលដល់ការងារសួរចម្លើយរបស់ខ្ញុំប៉ុននុ៎ង ។ ហើយខ្ញុំបានជម្រាប លោកចៅក្រមស៊ើបអង្កេតហើយ នេះជាវិធីដែល ស៊្វ ម៉េត អ៉ង្វែសុំទោស ដែល សុន សេន ហើយនិង នួន ជា លាក់ឈ្មោះរបស់គេកុំឲ្យវាយបែកធ្លាយ ។ នេះជាក្រឹត្យក្រមដែលយើងខ្ញុំធ្វើការងារ មេៗលាក់ឈ្មោះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ខាងសហព្រះរាជអាជ្ញាមិនមានសំណួរអីបន្តទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនដឹងថាតើនេះគឺជាបញ្ហាទាក់ទងទៅនឹងការបកប្រែ ឬក៏អត់ទេ ប៉ុន្តែ ខ្ញុំចង់ឲ្យមានការបញ្ជាក់មួយចំនួន។ ជនជាប់ចោទបាននិយាយកាលពីព្រឹកមិញថា គាត់បានទទួលសំបុត្រមួយចំនួនពីឈ្មោះ ស៊ូ ម៉េត ដែលជាលេខា ឬក៏ជាប្រធាននៅក្នុងកងពលមួយ ដែលមានការសម្រិតសម្រាំងជាច្រើនដង នៅក្នុងកងពលនោះ ។ ហើយខ្ញុំបានឮជនជាប់ចោទពន្យល់ថា សំបុត្រអស់ទាំងនេះ ឬក៏ទាក់ទងទៅនឹងសំបុត្រអស់ទាំងនេះ គឺថាគាត់មិនជំទាស់ទៅលើសំបុត្រនេះទេ ដែលថាសំបុត្រនេះត្រូវបានសរសេរដោយ ស៊ូ ម៉េត ប៉ុន្តែតាមពិតនេះគឺជាអ្វី ដែលជាការផ្ទុះបញ្ចាំងអំពីថ្នាក់លើ ។ ហើយខ្ញុំក៏បានឮជនជាប់ចោទនិយាយដែរថា ដោយវិធីណាមួយនោះ នេះគឺជា គ្រាន់តែជាការបិទបាំងតែប៉ុណ្ណោះ ជាមធ្យោបាយមួយសម្រាប់ឲ្យថ្នាក់លើ បិទបាំងខ្លួន ឬក៏ឈ្មោះរបស់ខ្លួន ។ ដូច្នេះ ពួកគេមើលទៅ ដូចថា មិនមែនជាអ្នកចេញបញ្ជានោះទេ ។ ប៉ុន្តែ ខ្ញុំត្រូវតែនិយាយថា ខ្ញុំមិនយល់សោះ ខ្ញុំមិនយល់បន្តិចណាសោះ ថាតើហេតុអ្វីបានជាមានការប្រើនូវវិធីបែបនេះ ។ តើថ្នាក់ដឹកនាំហ្នឹង គេចង់លាក់ឈ្មោះបាំងរបស់គេ លាក់អត្តសញ្ញាណរបស់គេដើម្បីអ្វី គឺលាក់បាំងពីខ្លួនលោកឬ? សម្រាប់ខ្ញុំ ខ្ញុំយល់ថាលោកបានទទួលចម្លើយសារភាពដែលមានចំណារផ្ទាល់ដៃពីមេរបស់លោក ។ ដូច្នេះ មេរបស់លោកបានសរសេរមកលោកផ្ទាល់ នៅពេលណាមួយនោះ ។ ដូច្នេះ ខ្ញុំមើលទៅដូចជាមិន ដឹងថាមានហេតុផលអ្វីនៃការលាក់បិទបាំងឈ្មោះរបស់មេរបស់ខ្លួននោះ ។ តើអ្វីទៅដែលជាគោលបំណងនៃការបិទបាំងឈ្មោះរបស់ខ្លួននោះ?

[១០:១១:១៥]

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! របៀបធ្វើការងាររបស់ពួកយើងខ្ញុំជំនាន់នុ៎ងគឺមិនសូវចេញឈ្មោះ មេមិនប៉ានចេញឈ្មោះមេ ។ ខ្ញុំសូមជូនឧទាហរណ៍ខ្លីមួយចុះ ។ ចំណារដែលខ្ញុំចារទៅលើទាំងប៉ុន្មានត្រឹមតែបងជាទីគោរពទេ អត់មានចេញឈ្មោះទេ ។ សុន សេន គាត់សរសេរទៅ ប៉ុល ពត ក៏អ៊ីចឹង “ជូនបង” ។ ដូច្នេះ យើងខ្ញុំពុះពារលាក់ឈ្មោះមេរហូត ។ ហើយមេខ្លួនឯងហ្នឹងក៏ចង់លាក់ឈ្មោះដែរ ។ ឧទាហរណ៍ដែលមានប្រយោជន៍គឺយ៉ាងនេះ ពេលដែលមេហៅខ្ញុំទៅធ្វើការ ទៅដល់គាត់និយាយពីរឿងសភាពការណ៍នៅ៥០២ ។ គាត់ថាសភាពការណ៍នៅ៥០២ វាអ៊ីចេះ ។ ឥឡូវនេះសំបុត្រ ម៉េត គេសរសេរមកមិត្តឯង គេតឿនមិត្តឯងហើយខំជួយគេបន្តិចទៅ ។ បើគាត់និយាយយ៉ាងនេះ វាមានឥទ្ធិពលលើខ្ញុំជាជាងគាត់បញ្ជាខ្ញុំខ្លួនឯងបន្តិចទៅទៀត ។ យើងនិយាយអ៊ីចឹងវាច្បាស់ណាស់ហើយ ហើយមេ

ក៏ជៀសវាងបញ្ហាផ្ទាល់មកដែរថា ឥឡូវមិត្តជួយ មិត្តម៉េត បន្តិចតទៅសភាពការណ៍របស់គេពិបាក ។ នេះផលប្រយោជន៍ដែលយើងខ្ញុំមើលទៅឃើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះគឺថាមានបំណងក្នុងការបិទបាំង ប៉ុន្តែបិទបាំងពីអ្នកណាគេ? លាក់បាំងពីនរណាគេ? មានន័យថាគឺមិនមែនលាក់បាំងពីលោកអ្នក ពីលោកទេ? ពីព្រោះលោកគឺជាអ្នកទទួលសំបុត្រនេះតែខ្លួនឯងម្នាក់គត់មែនទេ? តើលោកមានគិតថា មានអ្នកដទៃទៀតដែលចេញបញ្ហា ហើយមានអារម្មណ៍ថានឹងក្លាយទៅជាអ្នកទទួលខុសត្រូវនៅពេលក្រោយ ហើយដូច្នេះ ពួកគេធ្វើដូច្នេះដើម្បីជៀសវាងនៅក្នុងការទទួល នូវការទទួលខុសត្រូវនោះ តើអ្វីទៅជាហេតុផលនៃការបិទបាំង ឬក៏ភាពសម្ងាត់បែបនេះ?

[១០:១៤:៤៧]

**ជនជាប់ចោទ៖**

សូមជម្រាបលោកចៅក្រម បញ្ហារឿង ស៊ូ ម៉េត ដែលមេបញ្ជាឲ្យ ស៊ូ ម៉េត សរសេរមកខ្ញុំនេះគឺដើម្បីឲ្យខ្ញុំខំជួយ ស៊ូ ម៉េត ហើយមេជួយណែនាំខ្ញុំថែមតែប៉ុណ្ណឹង ។ បើសិនជាមេហៅខ្ញុំ ហើយប្រាប់ត្រង់ៗ អាហ្នឹងជាការខ្ញុំគោរពមេ ។ ប៉ុនដល់គាត់លេងស្នៀតនេះ វាទៅជាគាត់អំពាវនាវឲ្យខ្ញុំជួយ ស៊ូ ម៉េត ។ វាជារូបភាពមួយដែលគេប្រើ ។ ឯចំណែក ចំណារដែលខ្ញុំចារលើសេចក្ដីរាយការណ៍ជាចម្លើយរបស់ជនរងគ្រោះដែលទៅជាប់ទោសនៅនុ៎ង ខ្ញុំមិនដែលប៊ានសរសេរចេញឈ្មោះមេទេ ។ ខ្ញុំសរសេរ ថា “ជូនបង អ៊ំ បងជាទីគោរពៗ!” ខ្ញុំសរសេរតែប៉ុននុ៎ង ។ អានេះជាការគោរពដែលមិនប៊ានចេញឈ្មោះមេ ។ ខ្ញុំមិនប៊ានចេញឈ្មោះ សុន សេន ខ្ញុំមិនប៊ានចេញឈ្មោះ នួន ជា, សុន សេន ក៏មិនប៊ានចេញ ឈ្មោះ ប៉ុល ពត ដែរ ។ បើជាមួយ នួន ជា បង្ខំចិត្ត សុន សេន ត្រូវតែចេញឈ្មោះ ។ នេះជារបៀបដែលយើងខ្ញុំធ្វើការនៅក្នុងផ្ទៃបក្សជំនាន់នុ៎ង ។ ដូច្នេះ មួយជាការគោរព មួយជាការលាក់បិទបាំងឈ្មោះដើម្បីរក្សាទម្ងន់របស់គេ ដើម្បីរក្សាទម្ងន់សេចក្ដីណែនាំរបស់គេមកលើខ្ញុំ ។ នេះជាបញ្ហាពីរដាច់ដោយឡែកពីគ្នា ។ សូមលោកចៅក្រមជ្រាប ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ គឺយើងមានវិធីប្រតិបត្តិការ ហើយខ្ញុំបានសួរសំណួររបស់លោកទាក់ទងទៅនឹងហេតុផល ខ្ញុំមិនចង់និយាយសំណួររបស់ខ្ញុំឡើងវិញទេ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំសូមស្នើថា សំណួរហ្នឹងគួរតែសួរទៅលើអ្នកជំនាញផង ដើម្បីក្នុងសេចក្ដីសង្ឃឹមថា គាត់អាចនឹងធ្វើការឆ្លុះបញ្ចាំងអំពីការអនុវត្តវិធីបែបនេះនៅក្នុងកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងការរក្សានូវភាពសម្ងាត់ដ៏មុឹងម៉ាត់បែបនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធទៅនឹងឯកសារទាំងប្រាំបួនដែលលើកឡើងដោយសហព្រះរាជអាជ្ញា ហើយបានសាកសួរដល់ជនជាប់ចោទកន្លងមកនេះ តើមេធាវីខាងតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានអ្វីចង់មានសំណួរពាក់ព័ន្ធទៅនឹងជនជាប់ចោទទាក់ទិនទៅនឹងឯកសារទាំងប្រាំបួននេះដែរ ឬទេ?

[១០:២០:១៣]

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកចៅក្រម! គឺខាងក្រុមយើងខ្ញុំអត់មានសំណួរនោះទេ ។

**លោកស្រី ស៊ីលយ៉ីស្វូត ហ្សឺនស្ដ៖**

អរុណសួស្ដីលោក លោកស្រីចៅក្រម គឺខ្ញុំមានសំណួរទៅកាន់ជនជាប់ចោទ ។ ខ្ញុំនឹងចាប់ផ្ដើមទៅលើចំណុចចុងក្រោយគឺទាក់ទងទៅនឹងឈ្មោះមេរបស់លោកគឺអត់មានលាតត្រដាងនៅក្នុងលិខិតនោះទេ ។

ដូច្នេះ សំណួររបស់ខ្ញុំទាក់ទងទៅនឹងបញ្ហានឹងគឺថាតើគោលនយោបាយដូចគ្នានេះ ត្រូវបានគេយកទៅអនុវត្តចំពោះមាត៌ានៅជួរថ្នាក់ទីពីរដែរឬទេ? ឧទាហរណ៍ថាក្នុងតួនាទីរបស់លោកជាប្រធាន ស-២១ ឬក៏លេខាកងពល ថាតើ នៅក្នុងឋានៈអ្នកទាំងអស់នោះគឺគេយកគោលនយោបាយក្នុងការលាក់ឈ្មោះនោះមកអនុវត្តដែរឬទេ ចំពោះករណីអ្នកថ្នាក់ក្រោម ដូចជាលេខា ឬក៏ក្នុងនាមលោកជាប្រធាននោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន អ្នកក្រោមដែលសរសេរមកខ្ញុំច្រើនណាបង ទទេ ។ ប្លែកតែម្នាក់ពីរទេ ។ មិត្ត ប៊ុន គាត់សរសេរមកខ្ញុំគាត់ហៅតាំងពីជាតិណា ជាតិណីមកថា បងឌុច ហ្នឹងគាត់អត់ប្រែកើតទេ ។ ឯចំណែកបង ម៉មណៃ គាត់សរសេរមកខ្ញុំ មិត្តឌុច ក៏គាត់ប្រែមិនកើត ក្រៅពីនោះបងទាំងអស់ ។ ហើយបើគេហៅខ្ញុំពីក្រោយខ្នង បង២១ ឬក៏គេហៅ បងឯកើត មិត្តហ៊ី គេហៅបងឯលិច

អានេះគេនិយាយពីក្រោយខ្នង ក៏ប៉ុន្តែបើសរសេរ បើមានអ្នកសរសេរមកគឺបងទទេ ហ្នឹងគឺសំដៅមកខ្ញុំ។ បើសំដៅទៅមិត្តហ៊ បងហ៊ នេះខ្ញុំសូមបញ្ជាក់អំពីការប្រតិបត្តិនៅស-២១ ក៏ប៉ុន្តែវាអត់មានសំបុត្រអីហួរហែមកខ្ញុំដូចសំបុត្រខ្ញុំទៅ សុន សេន ទេ ។ ដូច្នេះ ពិបាកលើកយកហេតុផលមកបញ្ជាក់ណាស់ ។ វាមានតែពី ប៉ុន មកខ្ញុំទេដែលហួរហែជាងគេ ហើយនិងសំបុត្របង ម៉មណៃ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្វ៊ីនស្ដី៖**

តើលោកអាចបញ្ជាក់ទេថា វាជាគោលការណ៍ទូទៅគឺគោលការណ៍នោះជាបឋមគឺត្រូវតែលាក់ឈ្មោះ? ហើយទីពីរគឺបង្ហាញការគោរព គឺមិនតែចំពោះ នួន ជា, សុន សេន ឬក៏ ប៉ុល ពត នោះទេ តើលោកអាចបញ្ជាក់ដែរឬទេថា ដោយសារតែមូលហេតុនៃបញ្ហានេះហើយដែលថាខ្ញុំលើកឡើងវាជាគោលការណ៍ក្នុងការធ្វើដូច្នោះនោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! នេះជាគោលការណ៍ពីរដែលយើងខ្ញុំដើរទន្ទឹមគ្នា ក៏ប៉ុន្តែអត់មានអ្នកណាណែនាំអ្នកណាទេគឺធ្វើតាមៗ គ្នាជាទំលាប់ហួរហែអ៊ីចឹងមក ។ សរសេរទៅមេផ្ទាល់ដែលធំជាងគេនៅក្នុងអង្គភាពហ្នឹងគឺអត់ដែលប៊ានដាក់ឈ្មោះទេ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្វ៊ីនស្ដី៖**

ថាតើមានការដាក់ទណ្ឌកម្ម ឬមានការទិតៀនដែរឬទេ ប្រសិនបើបុគ្គលណាម្នាក់គាត់ធ្វើការលាតត្រដាង ឬក៏លើកឡើងអំពីឈ្មោះដែលវាផ្ទុយទៅនឹងគោលនយោបាយរួមនោះ?

[១០:២៥:០០]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ជាទូទៅយើងខ្ញុំមិនដឹងទេ ក៏ប៉ុន្តែនៅស-២១ យើងខ្ញុំអត់មានប្រកាន់ទោសកូនចៅអំពីបញ្ហានេះទេ ក៏ប៉ុន្តែ កូនចៅគេមិនដែលប៊ាននិយាយពីក្រោយខ្នងខ្ញុំថា បងស្អឹផង បងឌុចផង មានតែមួយទេ ដែលប៊ានហៅ បងឌុច គឺមិត្តប៉ុន ហើយនិងមិត្តហ៊ ពីរនាក់ ក្រៅបងឯកើតទាំងអស់ ព្រោះខ្ញុំនៅទិសខាងកើតគេ មិត្តហ៊ ខាងលិចខ្ញុំ គេហៅបងឯលិច ។ សុទ្ធតែស្នៀតនុំងហ្នឹងជំនាន់យើងខ្ញុំខ្លាចមេញាក់សាច់ ដូចគ្នា កូនចៅខ្ញុំក៏ខ្លាចខ្ញុំ ខ្ញុំក៏ខ្លាចមេតទៅទៀត ដូចគ្នា ។

**លោកស្រី ស៊ីលឃីស្ទូត ហ្វ៊ីនស្ដី៖**

ប្រសិនបើបុគ្គលណាម្នាក់ គាត់រំលោភទៅលើក្រឹត្យក្រមនេះ ហើយសរសេរលិខិតជូនលោក

ហើយដាក់ឈ្មោះលោកនៅក្នុងហ្នឹង ថាតើលោកអត់ទ្រាំនឹងបញ្ហាហ្នឹងដែរឬទេ? ឬក៏លោកធ្វើការដាក់ពិន័យទៅលើបញ្ហាហ្នឹង?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ។ យើងខ្ញុំមិនដែលបានអ្នកណា សរសេរសំបុត្រមកផង ប៉ុន្តែបើសិនជាមាន ក៏ខ្ញុំមិនទៅប្រកាន់អារឿងហ្នឹងដែរ អត់ប្រកាន់សោះ ។ ហ្នឹងប្រសិនបើមាន អត់ទេ អត់ប្រកាន់ទេ ។

ខ្ញុំសូមជូនរឿងមួយទៀតទៅទៀតចុះ ប្រពន្ធបង ម៉ម ណៃ អាយុដំណាលនឹងខ្ញុំ ពីដើមគាត់ហៅខ្ញុំប្អូន គាត់ទុកខ្ញុំដូចជាប្អូនថ្លៃអ៊ីចឹង ។ ដល់អាគេៗហៅ បងឯកើតលាន់ គាត់ប្រែមកហៅខ្ញុំបងខាងកើតដល់ខ្ញុំឮគាត់ហៅ បងខាងកើត ខ្ញុំសើច ។ បានគាត់និយាយថា អ្ហែ គេហៅបងឯកើតលាន់ហើយ ខ្ញុំក៏ហៅនឹងគេទៅ ។ ហ្នឹងអ៊ីចឹង អត់មានប្រកាន់ទោសអីទេ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

គឺចំពោះឯកសារប្រាំបួនដែលបានប្រឹក្សាដេញដោលព្រឹកមិញនេះ គឺនៅក្នុងជួរទីមួយ គឺវាមិនតាមត្រឹមតែសរសេរថា ជូនសមមិត្តបងនោះទេ ហើយមានការលើកឡើងនៅក្នុងគ្រប់ឯកសារនោះនៅឈ្មោះលោកថែមទៀត គឺមិនមែនឈ្មោះលោកទាំងស្រុងនោះ គឺមានតែលើកឡើងតែឈ្មោះ ឌុច តែប៉ុណ្ណោះ ។ គឺយើងឃើញមានដាក់ថា ជូនចំពោះសមមិត្តបងឌុច សូមជម្រាបជូនសមមិត្តបង ឌុច ...។ល។ តើលោកពន្យល់ទៅលើករណីនេះដែរឬទេ? ហេតុអ្វីបានជាមានគោលការណ៍បែបនេះ បានន័យថា មានគោលការណ៍ក្នុងការដាក់ឈ្មោះ របស់លោកបែបនេះនៅក្នុងលិខិតរបស់ ស៊ូ ម៉េត នោះ ។

[១០:២៨:១៥]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ។ ស៊ូ ម៉េត និងខ្ញុំអង្គភាពពីរខុសគ្នា កងពល៥០២ អង្គភាព មួយគេជាលេខា ឯចំណែកស-២១ ខ្ញុំអង្គភាពមួយ ខ្ញុំជាលេខា ។ បើនិយាយពីក្នុងផ្ទៃបក្ស ខ្ញុំទាបជាង ស៊ូ ម៉េត ។ ស៊ូ ម៉េត គេជាសមាជិកជំនួយការមជ្ឈិមបក្ស ។ ខ្ញុំបក្ខជនធម្មតា ក៏ប៉ុន្តែពីអាយុ ស៊ូ ម៉េត ប្អូនខ្ញុំ ប្អូនដល់៥ឆ្នាំ ៦ឆ្នាំអីទៅ ។ ដូច្នេះ ខ្ញុំជឿថាបើ ស៊ូ ម៉េត សរសេរទៅ សុន សេន ប្រហែលជាគោរពជូនបង ឬបងជាទីគោរព ដូចអង្គការអ៊ីចឹងជៀសមិនរួចទេ ។ ក៏ប៉ុន្តែ អត់ប៉ានបញ្ចេញឈ្មោះបងខៀវ ទេ នេះបើសិនជាគាត់សរសេរទៅ សុន សេន ក៏ប៉ុន្តែ គាត់សរសេរមកខ្ញុំមិនមែនមេគាត់

គាត់ត្រូវហៅសមមិត្តបងឌុច គេគោរពទាំងអាយុយើង គេគោរពទាំងអីសព្វគ្រប់របស់គេហើយ ដូច្នេះ ខ្ញុំមិនមែនមេ ស៊្វ ម៉េត ទេ ។ ហើយបើសិនជាខ្ញុំសរសេរទៅ ស៊្វ ម៉េត វិញ ក៏ខ្ញុំសរសេរថា ពូម៉េត ជាទីគោរព!។ ទាល់តែ ម៉េត ព្រោះអង្គភាពពីរខុសគ្នា ។ នេះសូមជម្រាបលោកប្រធានប៉ុណ្ណោះ ។

**លោកស្រី ស៊ីលឃីស្វត ហ្សីនស្តី៖**

សំណួរចុងក្រោយលើបញ្ហានេះ អ៊ីចឹងតើខ្ញុំអាចសន្និដ្ឋានដែរឬទេថា លោក រូ តើមានបញ្ហាទាក់ទងទៅនឹងការបកប្រែរបស់លោក ឬយ៉ាងម៉េច? ហើយបញ្ហាចុងក្រោយលើករណីនេះ តើលោកអាចបញ្ជាក់ដែរឬទេថា វាមិនមានភាពចាំបាច់ក្នុងការលាក់ឈ្មោះរបស់លោក និងមិនចាំបាច់ក្នុងការគោរពចំពោះលោក នៅពេលដែល ស៊្វ ម៉េត នោះគាត់ក្មេងជាងលោក? ដែលថា នៅពេលដែលសរសេរដាក់នៅលើជួរទីមួយនៃលិខិតនោះគឺ មិនចាំបាច់មានការគោរពថាត្រូវលាក់ឈ្មោះលោកនោះទេ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! កាលដែលមិនចេញឈ្មោះ គឺមិនចេញឈ្មោះចំឈ្មោះមេ កាលណាយើងសរសេរទៅមេយើងអត់ចេញឈ្មោះទេ នេះគឺពិត ។ ខ្ញុំសរសេរទៅមេអត់ដែលចេញឈ្មោះទេ ខ្ញុំក៏ជឿថា ស៊្វ ម៉េត សរសេរមកខ្ញុំក៏មិនដែលចេញឈ្មោះដែរ ។ ក៏ប៉ុន្តែ ស៊្វ ម៉េត អង្គភាពផ្សេង ខ្ញុំអង្គ-ភាពផ្សេង បើមិនដាក់ឈ្មោះខ្ញុំវារង្វេងវាមិនដឹងទៅឯណាទិសឯណាទេ ។ អង្គភាពពីរផ្សេងគ្នា ក៏ប៉ុនដែលសរសេរមករកគ្នាក៏ដោយសារការអនុញ្ញាត និងបទបញ្ជារបស់មេដែរ ។ ដូច្នេះ អង្គភាពពីរផ្សេងគ្នាត្រូវតែចេញឈ្មោះអ៊ីចឹងហើយ ។

[១០:៣១:៤០]

**លោកស្រី ស៊ីលឃីស្វត ហ្សីនស្តី៖**

លិខិតទាំងប្រាំបួននេះ គឺតាមការសន្និដ្ឋានរបស់ខ្ញុំ គឺវាពាក់ព័ន្ធ ប្រហែលជាពាក់ព័ន្ធទៅនឹងខ្នាំងប្រហែលជា៥០នាក់ ដូចដែលសហព្រះរាជអាជ្ញាបានដាក់ជូនហើយ ដកស្រង់ចេញពីបញ្ជីអ្នកទោសរួមគឺយើងឃើញមានយ៉ាងហោចណាស់មានអ្នកទោស២៩៩នាក់ដែលចាប់មកពីកងពល៥០២ ។

ប្រសិនបើ ខ្ញុំធ្វើការសន្និដ្ឋានពីលិខិតទាំងប្រាំបួននេះ គឺយើងឃើញមានមនុស្សចំនួន៥០នាក់ដែលត្រូវបានធ្វើការពិភាក្សារវាងលោក និង ស៊្វ ម៉េត ។ សំណួររបស់ខ្ញុំនោះគឺថា តើការនីតិវិធី ឬក៏ដំណើរការនៃការធ្វើការងារវាដូចគ្នាដែរឬទេ ចំពោះបុគ្គលអ្នកទោស២៩៩នាក់ផ្សេងទៀត ដែលត្រូវបានគេបញ្ជូនទៅស-២១ តើមានគោលនយោបាយអនុវត្តការងារដូចគ្នាដែរឬទេ ដូចដែលមានលើកឡើង

នៅក្នុងលិខិតទាំងប្រាំបួននេះ?

[១០:៣៣:២១]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ការចាប់អតីតយុទ្ធជន និងអតីតកម្មាភិបាលយោធាចេញពីកងពល៥០២ ខ្ញុំក្តាប់ចំនួនមិនបានទេ ក៏ប៉ុន្តែជឿថា វាដល់ទៅ២៩៩នាក់ហ្នឹងពិត ឯកិច្ចដំណើរការដដែលជាដដែលគ្រប់កងពល មិនមែនត្រឹមតែកងពល៥០២ ទេ ។ សេចក្តីសារភាពដែលយើងខ្ញុំបានយើងខ្ញុំជូនអីចារ ជាពិសេសច្រើនតែចារ ហើយជូនផ្ទាល់ទៅមេគឺ សុន សេន ។ ហើយ សុន សេន ហៅប្រធានអង្គភាពគេ ជាពិសេសបើកងពល៥០២ គឺហៅ ស៊ូ ម៉េត មកផ្ទាល់តែម្តង ដើម្បីសម្រេចជាមួយគ្នា នេះជាវិធីដែលធ្លាប់ធ្វើការ ។ ដូច្នេះ សម្រេច គឺគេសម្រេចក្នុងក្របខ័ណ្ឌ លេខាអគ្គសេនាធិការ និងលេខាកងពល ជាហូរហែគឺសម្រេចអ៊ីចឹង គ្មានតួនាទីរបស់ស-២១ ទៅរួមសម្រេចនឹងគេទេ ។

និយាយយ៉ាងដូច្នេះ តួនាទីរបស់ស-២១ ចំពោះបញ្ហាឧក្រិដ្ឋកម្មចាប់ចងអតីតយុទ្ធជន និងកម្មាភិបាលយោធាវាមានត្រឹមតែការដែលយើងខ្ញុំវ៉ៃគេសួរចម្លើយ ហើយបានចម្លើយបញ្ជូនទៅឲ្យមេសម្រេច។ នេះអត់បដិសេធទេ ក៏ប៉ុន្តែទៅចូលទៅរួមសម្រេចនឹងគេ គ្មានតួនាទីទេ ។ នេះខ្ញុំសូមបញ្ជាក់ម្តងទៀតកងពលណាក៏ដោយ ក៏ដូចកងពលណាដែរ ។ ដូច្នេះ មនុស្សទាំង២៩៩នាក់ ដែលចាប់ចេញពីកងពល៥០២ គឺសុទ្ធតែដំណើរការរបៀបនេះ កងពលផ្សេងទៀតក៏យើងខ្ញុំដំណើរការរបៀបនេះ ។ មេជាអ្នកសម្រេច តាមគោលការណ៍ដែលមានកំណត់នៅក្នុងសេចក្តីសម្រេចចិត្តថ្ងៃ៣០ មីនា ១៩៧៦ ។ គ្មានអ្នកណាប៉ានល្មើស នេះជារឿងពិត ។

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ជាក់ជូនអង្គសវនាការទាំងមូល ថាម៉េចក៏មានតែសំបុត្រ ស៊ូ ម៉េត ហើយនិងស-២១ ហ្នឹង ឯអង្គភាពផ្សេងទៀតក៏មិនមាន ។ ខ្ញុំចង់សូមអនុញ្ញាតបញ្ជាក់បញ្ហានេះជូន សូមបញ្ជាក់ថា កងពល៥០២ ជាកងពលអាកាស ។ មានគ្រូចិនទៅនៅហ្នឹង នេះលក្ខណៈទីមួយ ។ រឿងអីផ្ទុះនៅក្នុងកងពល៥០២ ប៉ុល ពត ខ្លាចចិន សុន សេន ខ្លាចចិន ស៊ូ ម៉េត ខ្លាចចិន ។ ស៊ូ ម៉េត ខ្លាចច្រើនជាងគេ គឺខ្លាច សុន សេន ផង ខ្លាច ប៉ុល ពត ផង ។ សុន សេន ក៏ខ្លាចច្រើនដែរ សុន សេន ខ្លាច ប៉ុល ពត ហើយនិងខ្លាចចិន ។ ដូច្នេះ ធ្វើម៉េចទាំងអស់គ្នាខំ ម្លោះហើយចេះតែមេរកវិធីដើម្បីគៀងគរខ្ញុំឲ្យខំជួយកងពលនេះឲ្យអស់សមត្ថភាព ហើយខ្ញុំជាមនុស្សដែលវាអើយកចិត្តគេដែលបារាំងហៅ *ឡឺ ស្អែរ្យល* ហ្នឹង ចេះតែខំតាមតែគេញាក់ហើយទៅហើយ ។ នេះជាបញ្ហាមួយដែល

មេខំ កងពល៥០២ ជាងគេ ។

[១០:៣៦:៤៥]

បញ្ហាទីពីរ នៅកងពល៥០២ ស្អីក៏ថ្លៃដែរ កាប៉ាល់ហោះមួយថ្លៃមិនដឹងប៉ុន្មាន? បើនិយាយពីសាំងវិញសុទ្ធតែម៉ែត្រគូប មិនមែនសាំងបើពីសេនាធិការមកជាពុយៗដូច ស-២១ ទេ ។ សាំងដែលកងពល៥០២ បើកពីសេនាធិការជាម៉ែត្រគូប នេះទីពីរ ។

ហើយបញ្ហាទីបី រឿងនេះវាអត់មាននៅក្នុងឯកសារនេះទេ ចាប់ចងទេ វាមិនមាននៅក្នុងបញ្ជីអ្នកទោសទេ ក៏ប៉ុន្តែ វាមាននៅក្នុងចម្លើយសារភាពរបស់ ហ៊ួ នឹម និយាយអំពីអតីតអ្នកបើកបរម្នាក់ឈ្មោះ ពេជ លឹមឃុន ហៅ តុល ដែលបើកឧទ្ធម្ភាគចក្ររត់ចេញពីពោធិចិនតុងទៅដល់ថៃ ។ គ្រូចិនឃើញទម្រាំនឹងយល់ថា អាហ្នឹងបើករត់ ឡើងឧទ្ធម្ភាគចក្រមួយទៀតដេញតាម ដេញមិនទាន់ អានោះទៅដល់ថៃបាត់ ។ ពេលហ្នឹងដែល ប៉ុល ពត ខ្មាសចិនខ្លាំង សុន សេន ខ្មាសចិនខ្លាំង ស៊្វ ម៉េត ខ្មាសចិនខ្លាំងទាំងអស់គ្នាខំ ដូច្នេះហើយបានជាមានតែកងពល៥០២ មួយគត់ដែល សុន សេន ប្រើវិធីរបៀបនេះដើម្បីជំរុញខ្ញុំឲ្យខំខ្នះខ្នែងជួយ ស៊្វ ម៉េត ព្រោះគាត់ក៏ខ្មាសចិនខ្លាំងណាស់ដែរ ។ ចង់ស្តារមុខមាត់ជាមួយ ប៉ុល ពត ផង នេះខ្ញុំសូមបញ្ជាក់មូលហេតុដែលនាំឲ្យមានតែសំបុត្រ ស៊្វ ម៉េត ឲ្យជ្រៅដល់បញ្ហាជាក់ស្តែង ។

**លោកស្រី ស៊ីលឃីស្ទត ហ្សីនស្តុី៖**

លោកប្រធានខ្ញុំគិតថា នេះជាលើកទីពីរហើយដែលជនជាប់ចោទគាត់ គឺឆ្លើយនឹងសំណួរខ្លួនគាត់ផ្ទាល់ ហើយតាមអ្វីដែលខ្ញុំយល់នូវនីតិវិធីនៅទីនេះ គឺមិនមែនជាកាតព្វកិច្ចគាត់ក្នុងឆ្លើយសំណួរខ្លួនឯងរបស់គាត់នោះទេ ។ ដូច្នេះ ខ្ញុំស្នើសុំលោកប្រធានធ្វើការបង្គាប់ជនជាប់ចោទទៅលើបញ្ហានេះ ឲ្យគាត់ឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ដែលខ្ញុំបានសួរគាត់តែប៉ុណ្ណោះ ហើយមិនត្រូវឲ្យគាត់បន្ថែម និងសួរសំណួរខ្លួនឯង ហើយឆ្លើយទៅនឹងសំណួរខ្លួនឯងនោះទេ ។

ខ្ញុំនឹងធ្វើការរៀបចំសំណួរចុងក្រោយរបស់ខ្ញុំសាជាថ្មី ។ នៅពេលដែលខ្ញុំសួរថា តើអ្នកទោស២៥០នាក់ផ្សេងទៀតតាមការស្មានរបស់ខ្ញុំនោះ ថាតើអ្នកទោស២៥០នាក់នោះ គឺស្ថិតនៅក្រោមការប្រព្រឹត្តិ ឬក៏ដំណើរការដូចគ្នាដែរឬទេនឹងអ្នកទោស៥០នាក់ផ្សេងទៀត?

សំណួររបស់ខ្ញុំថា អ្នកទោស២៥០នាក់នោះ គឺត្រូវបានយកមកធ្វើការពិភាក្សា ឬក៏និយាយនៅក្នុងលិខិតដូចជាលិខិត ស៊្វ ម៉េត ដែរឬទេ? ដូចថា លិខិត ស៊្វ ម៉េត ផ្ញើជូនមកលោក ។ សំណួររបស់ខ្ញុំ

គឺថាតើមានការដំណើរការនិងនីតិវិធីដូចគ្នាដែរឬទេ នៅក្នុងការលើកឡើង និងពិភាក្សាទៅលើអ្នកទោសផ្សេងៗ ដូចដែលមានលើកឡើងនៅក្នុងលិខិតរបស់លោក ស្វ៊ំ ម៉េត?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឆ្លើយរួចហើយ ។ ឥឡូវ ខ្ញុំគ្រាន់តែសុំបញ្ជាក់ឱ្យខ្លីថា ក្រឹត្យក្រមទូទៅ មិនមែនតែចំពោះកងពល៥០២ទេ កងពលណាក៏ដោយ គឺខ្ញុំជាអ្នកផ្តល់ចម្លើយសារភាពដែលទទួលបានពីទារុណកម្មទៅឱ្យមេខ្ញុំ គឺ សុន សេន ។ ឯចំណែក ចាត់ចែងសម្រេចយកអ្នកណាជាអ្នកណាគឺ សុន សេន សម្រេចជាមួយនឹងម្ចាស់អង្គភាពគេ នេះជាក្រឹត្យក្រមទូទៅ ។ ដោយឡែក កងពល៥០២ សំបុត្រដែលមានរូបភាពជាសំបុត្រ ស្វ៊ំ ម៉េត នេះទៅខ្ញុំវាប្លែកពីគេមែន សម្រាប់គ្នាហាសិបប្លាយនាក់នេះ ។ គឺពិតជាប្លែក ក្នុងគោលបំណងមេលើកទឹកចិត្តខ្ញុំឱ្យខំជួយ ស្វ៊ំ ម៉េត នេះខ្ញុំយល់ថា ចម្លើយនេះប៉ុណ្ណេះវាចំនឹងសំណួររបស់អ្នកសួរហើយ ។ សូមជម្រាបប្រសាសន៍លោកប្រធានប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំដូចជាសូមបញ្ជាក់សំណួរឡើងវិញ បើខ្ញុំមិនច្រឡំទេ សំណួរគាត់សួរថា ការចាប់ខ្លួនមនុស្សនៅកងពល៥០២ សរុបមានចំនួន២៩៩រូប បញ្ជូនមកស-២១ ហើយលោកក៏បានទទួលផងដែរថា យល់ស្របលើចំនួននេះ ។ ហើយបញ្ហាដែលសំណួរហ្នឹងសួរថា លិខិតប្រាំបួនដែលមានការឆ្លើយឆ្លងរវាងលោកតាមរយៈ សុន សេន ដែលលោកបានឆ្លើយបញ្ជូនមកលោកនេះ គឺពាក់ព័ន្ធជាមួយនឹងមនុស្សប្រហែល៥០នាក់ ។ សំណួរសួរថា ផ្សេងទៀតនេះ ៥០២ ដែលចាប់បញ្ជូនក្រៅពីចំនួន៥០នាក់ពាក់ព័ន្ធនឹងការប្រើប្រាស់លិខិតទាំងប្រាំបួនហ្នឹង សួរថាតើលោកមានប្រើប្រាស់ ស្វ៊ំ ម៉េត មានប្រើប្រាស់ទម្រង់បែបលិខិតដូចគ្នានឹងការប្រើប្រាស់សម្រាប់អ្នកមានចំនួនប្រហែល៥០នាក់ ពាក់ព័ន្ធជាមួយនឹងលិខិតទាំងបួននេះដែរឬទេ?

ច្បាស់ទេ? អាចអ៊ីចឹងទេ ឬក៏អាចកែខ្ញុំបានប្រសិនបើ អ៊ីចឹងគ្រាន់តែថា តើប្រើទម្រង់ហ្នឹងទេ អាអ្នកចាប់ផ្សេងទៀតក្រៅពី បានន័យថា២៩៩នាក់ ដកប្រហែល៥០នាក់ចេញ បានន័យថា អ្នកប្រហែល២៤០នាក់ទៀតហ្នឹង តើទម្រង់នៃបែបបទនៃការចាប់នេះ យើងអាចប្រើប្រាស់លិខិតឆ្លើយឆ្លងរបៀបហ្នឹងដែរឬក៏អត់? តែប៉ុណ្ណឹងទេ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ។ ខ្ញុំចាំអត់ច្បាស់ទេ ។ បើមានលើសនៅសល់សំបុត្រមួយ ពីរ ដែលយើងបានរកមិនឃើញ ។ បើសិនជាមានលើស គឺសំបុត្រមួយ ពីរទៀត ដែលយើងបាត់រកមិនឃើញ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ដី៖**

តើលោកអាចប្រាប់យើងខ្ញុំបានទេ តើវិធីណាដែលលោកទទួលសំបុត្រទាំងប្រាំបួននេះ? តើលោកទទួលតាមវិធីណា? បើតាមការយល់ដឹងរបស់ខ្ញុំ តាមវិធីមួយនោះគឺ សុន សេន បានប្រគល់លិខិតនោះផ្ទាល់មកឱ្យលោក នៅពេលដែលគាត់បានទទួលលិខិតទាំងនោះពី ស៊ូ ម៉េត ។ តើលោកអាចពន្យល់បានទេ ថាតើសំបុត្រអស់ទាំងនុ៎ង ត្រូវផ្ញើរមកតាមរយៈនីរសារដែល សុន សេន ផ្ទាល់បានយកមកឱ្យលោក ឬមួយតើមានវីធីសាស្ត្រណាផ្សេងទៀត ដែលត្រូវបានប្រើសម្រាប់ឱ្យលោកទទួលបាននូវសំបុត្រអស់ទាំងនោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន សំបុត្រទាំងអស់នេះ បើតាមខ្ញុំចាំគឺ សុន សេន ប្រគល់ឱ្យខ្ញុំនៅពេលដែលហៅខ្ញុំទៅធ្វើការណែនាំ ចំពោះករណីជាចំពោះដែលទាក់ទងទៅនឹងសំបុត្រ ស៊ូ ម៉េត នេះ ។ ដូច្នេះ អត់តាមរយៈនិរសាទេ នេះតាមខ្ញុំចាំ ហើយលទ្ធភាពគឺតែប៉ុណ្ណឹងឯង ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ដី៖**

តើពេលនេះដល់យើងឈប់សម្រាកហើយ ឬយ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មានសំណួរច្រើនទៀតទេ? ពីព្រោះ អ៊ីចេះបញ្ហានៅមានក្រុមមេធាវីជាច្រើនអាចតាំងសំណួរបញ្ហាទីមួយ ។ ទីពីរ សំណួរពាក់ព័ន្ធហ្នឹងវានឹងមានការពាក់ព័ន្ធជាមួយនឹងអ្នកជំនាញជាចម្បងគឺអ្នកជំនាញទេដែលធ្វើសវនាការ ប៉ុន្តែ ការបញ្ជាក់នេះ ដើម្បីឱ្យមានការពាក់ព័ន្ធដែលការទទួលយល់ព្រមផងដែរពីជនជាប់ចោទដើម្បីយកមកដេញដោល ពីព្រោះម្សិលមិញយើងមានការចម្រូងចម្រាសគ្នាពីបញ្ហានេះ ។ អ៊ីចឹងគោលបំណងនៃការសួរពាក់ព័ន្ធនេះ គឺយើងគោលបំណងរបស់យើងហ្នឹងភ្ជាប់ទៅនឹងៗសួរដល់អ្នកជំនាញ ដើម្បីឱ្យដូចលោកមេធាវីការពារក្ដី គាត់បានលើកឡើងហើយថា អ្វីទាំងអស់ឆ្លុះបញ្ចាំងគឺជាសក្ខីកម្មរបស់អ្នកជំនាញ ។ ហើយប្រសិនបើអាចមានសំណួរច្រើនទៀត អង្គជម្រះនឹងប្រកាស

ឈប់សម្រាក ពីព្រោះស៊ុរបគ្នាឌីសហ្វ៊ឹងជិតអស់ដែរ នៅសល់តែដប់មីនុតទេដែលអស់ ។

គោលបំណងដែលថា អូសបន្លាយពេលបន្តិចនេះ ដើម្បីអាចចប់រឿងរបស់លោកស្រីជាមេធាវីក្រុមពីរ ទៅអាចចូលវិញក្រុមបី, ក្រុមបួន ក្នុងប៉ុនប៉ងពន្លឿននៃការពិភាក្សាដេញដោល ។

តើនៅសំណួរច្រើនទៀតទេ?

[១០:៤៧:៣៦]

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្តី៖**

លោកប្រធាន ខ្ញុំមានសំណួរបន្ថែមទៀត ។ ប្រហែលជាខ្ញុំមិនអាចបញ្ចប់មុនសម្រាកបានទេ ពីព្រោះអីជនជាប់ចោទមិនបានឆ្លើយឲ្យចំសំណួររបស់ខ្ញុំទេ ។

ដូច្នេះ ខ្ញុំចង់សួរសំណួរបន្ថែមទៀតមិនច្រើនទេ ក៏ប៉ុន្តែ គឺមានសំណួរមួយចំនួនទៀតទាក់ទងទៅនឹងឯកសារទាំងប្រាំបួននេះ បន្ទាប់ពីយើងឈប់សម្រាកហើយ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង គឺស្របពេលដែល គឺដោយថា ត្រូវពេលឈប់សម្រាកផង ហើយឌីវីឌីដែលថតសំឡេងក៏អស់ដែរ ហើយត្រូវនឹងការផ្លាស់ប្តូរ ដូច្នេះអង្គជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយប្រាំនាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តដំណើរការសវនាការ ។ ហើយមន្ត្រីតុលាការរៀបចំសម្របសម្រួលឲ្យអ្នកជំនាញ ដើម្បីបានទទួលនៅកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១០:៤៩នាទី ដល់ម៉ោង ១១:១០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ ឈប់សិនមិនទាន់អាចដំណើរការបានទេ បង្អង់ពីរនាទី ដោយសារមានបញ្ហាបច្ចេកទេសខាងទូរទស្សន៍ ខាងសោតទស្សន៍ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ហើយមុននឹងប្រគល់វេទិកានេះទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ អង្គជំនុំជម្រះ សូមរំឭកមេធាវីក៏ដូចជាភាគីពាក់ព័ន្ធ សូមប្រឹងប្រែងជាបន្ត ដើម្បីរៀបចំសំណួរឲ្យខ្លី ឲ្យច្បាស់លាស់ ដើម្បីងាយស្តាប់បាន ហើយនឹងអាចឆ្លើយតបចំសំណួរដែលសួរនោះ ។

បញ្ហាទីពីរ ក្នុងករណីការដែលលើកឡើងដោយមេធាវី ស្ទូតហ្សីនស្គី ថា ជនជាប់ចោទឆ្លើយមិនចំសំណួរ ខ្ញុំគិតថានេះជាសិទ្ធិរបស់ជនជាប់ចោទក្នុងការឆ្លើយដោះសារ ឬក៏សិទ្ធិរបស់គាត់រហូតដល់មិនឆ្លើយផង នេះសិទ្ធិដែលមានជានិច្ចនៅក្នុងដំណើរការនីតិវិធី ។ ហើយការដែលអាចឆ្លើយៗមិនចំមិនត្រូវបានន័យថា ការសួរវាជាលំបាកដែរ ។ សំណួរដែលវៀបទៅវាលំបាក បើស្តាប់សំណួរមិនយល់នោះនឹងនាំឲ្យអាចជាមូលហេតុ ដែលនាំឲ្យឆ្លើយហ្នឹងមិនចំដែរ ។

បញ្ហាមួយទៀតដែលមេធាវី ស្ទូតហ្សីនស្គី បានលើកឡើងអំពីការដែលជនជាប់ចោទបាននិយាយនូវបញ្ហាមួយចំនួនដែលហួសពីសំណួរដែលសួរនោះ ។ អង្គជំនុំជម្រះសូមជម្រាបថា អម្បាញ់មិញនេះដោយសារមានការភ្លេច នៅខ្វះបច្ចេកទេស មានន័យថា អង្គជំនុំជម្រះគឺយើងខ្ញុំបានអនុញ្ញាតឲ្យគាត់និយាយដោយ ខ្ញុំបានងក់ក្បាលប៉ុណ្ណោះ ។ អ៊ីចឹងវាកំហុសលើបញ្ហានៃការកត់ត្រាប្រតិចារឹកដែលមិនបានបញ្ជាក់ទទួលយល់ព្រម ឬក៏អនុញ្ញាតដោយការចុចប៊ូតុងនិយាយនេះ ។ ហើយដោយសារកត់សម្គាល់ឃើញថា វាពាក់ព័ន្ធនឹងសំណួរដែលសួរ ហើយនិងចម្លើយដែលគាត់ឆ្លើយ គឺជាការឆ្លើយបញ្ជាក់បន្ថែមទៀតរំលេច ឬក៏ភាពឲ្យកាន់តែច្បាស់នូវអ្វីដែលជាចម្លើយនោះ ។ ប្រសិនបើ ឆ្លើយខ្លីទៅវាមិនអាចគ្រប់គ្រាន់ ឬក៏មិនពិបាកយល់ ។

អ៊ីចឹង សូមមានការរៀបចំទាំងអស់គ្នាដើម្បីប្រឹងប្រែង ដើម្បីឲ្យដំណើរការពិភាក្សាដេញដោលហ្នឹងបានច្បាស់លាស់ ហើយយើងចំណាយពេលវេលាតិច ដោយសារយើងពិតទទួលស្គាល់ទាំងអស់គ្នាកន្លងមកហើយថា មានការលំបាកផ្នែកខាងបច្ចេកទេសនៃការបកប្រែនោះ ។

ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ ក៏យើងនឹងប្រឹងប្រែងដើម្បីកាត់បន្ថយនៃការលំបាកនេះ ឲ្យបានល្អដែរ ដោយបច្ចេកទេសនៃការសួរសំណួរឲ្យចំនេះ ។

សូមអញ្ជើញលោកស្រី ស្ទូតហ្សីនស្គី ដើម្បីអាចបន្តសំណួរសួរដល់ជនជាប់ចោទ ពាក់ព័ន្ធនឹងឯកសារទាំងប្រាំបួន តទៅទៀត ។ សូមអញ្ជើញ ។

[១១:១៥:១៨]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គីៈ**

សូមអរគុណលោកប្រធាន ។ មុនពេលយើងឈប់សម្រាក ខ្ញុំបានសន្និដ្ឋានថា លោកបានឆ្លើយថា សំបុត្រទាំងប្រាំបួននេះ ត្រូវបានប្រគល់ជូនលោកដោយផ្ទាល់ពី សុន សេន ។ តើអ្វីដែលខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ។ សម្ដីរបស់មេធាវី ស្ទួតហ្សឺនស្គី ត្រឹមត្រូវហើយ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្គី៖**

នៅពេលដែលលោកធ្វើការឆ្លើយតបទៅនឹងសំណើអស់ទាំងនុ៎ង តើលោកធ្វើការឆ្លើយតបទៅសំណើជាលាយលក្ខណ៍អក្សរឬ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់ដែលឆ្លងឆ្លើយជាមួយ ស៊ូ ម៉េត ទេ ជាលាយលក្ខណ៍អក្សរក៏ដោយ ជាពាក្យសម្ដីទៅរក ស៊ូ ម៉េត ក៏ដោយ ។ រឿងយ៉ាងម៉េចៗ ដែល ស៊ូ ម៉េត សួរមកនេះខ្ញុំរាយការណ៍ជូនមេ ។ ខ្ញុំដោះស្រាយបានប៉ុនណា ខ្ញុំធ្វើការបានប៉ុណា គឺរាយការណ៍ជូនមេ អត់មានឆ្លើយត្រង់ទៅរក ស៊ូ ម៉េត ទេ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្គី៖**

ឥឡូវនេះ ខ្ញុំនិយាយឡើងវិញម្ដងទៀត តើលោកបានផ្ញើសំបុត្ររបស់លោកតាមរយៈ សុន សេន ទៅឲ្យ ស៊ូ ម៉េត ដែរ ឬទេ? នៅពេលដែលលោកធ្វើការឆ្លើយតបទៅនឹងសំបុត្រដែលលោកបានទទួលពី ស៊ូ ម៉េត តាមរយៈ សុន សេន នោះ ។

**ជនជាប់ចោទ៖**

ខ្ញុំអត់ឆ្លើយតបតាមសំបុត្រទៅ ស៊ូ ម៉េត ទេ ។ ខ្ញុំជម្រាបរាយការណ៍គ្រប់បញ្ហាជូនមេខ្ញុំ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្គី៖**

តើគ្រប់ពេលទាំងអស់ សុន សេន នៅពេលដែល សុន សេន ជាមេរបស់លោកនោះ មានន័យថាគឺថាគាត់មានវត្តមានជារៀងរាល់ថ្ងៃនៅពេលដែលលោកធ្វើការរាយការណ៍ទៅជូនគាត់នោះឬ?

**ជនជាប់ចោទ៖**

តាមធម្មតាល្ងាចម៉ោងបួន ម៉ោងប្រាំ គាត់តែងតែហៅខ្ញុំសួរសាកបញ្ហាតាមទូរស័ព្ទ ។ ខ្ញុំត្រូវនៅកន្លែងជាប់ជានិច្ចរង់ចាំជួបគាត់មិនដែលប៊ានដើរទៅណាទេ គឺពេលវេលាជួបគ្នា គាត់ជាអ្នកកំណត់ គាត់ជាអ្នកបញ្ហា គាត់ជាអ្នកហៅ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្គី៖**

ឯកសារខ្លះ ក្នុងចំណោមឯកសារទាំងនេះដែលយើងកំពុងតែនិយាយ គឺនិយាយអំពីព្រឹត្តិការណ៍

នៅថ្ងៃតែមួយ ។ ជាឧទាហរណ៍ ឯកសារចុះថ្ងៃទី៣០ ខែឧសភា តើខ្ញុំត្រូវអានលេខ ERN ឡើងវិញទេ ឬក៏មិនចាំបាច់ទេ? ពីព្រោះឯកសារហ្នឹង ត្រូវបានអាន ត្រូវលើកឡើងដោយសហព្រះរាជអាជ្ញារួចទៅហើយ ។

**ប្រធានអង្គជំនុំ៖**

អានឡើងវិញឲ្យច្បាស់ទៅ ដើម្បីឲ្យចៀសវាងមិនច្បាស់ទាំងអស់គ្នា ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

គឺឯកសារចុះថ្ងៃ៣០ ឧសភា ឆ្នាំ១៩៧៧ ដែលបានភ្ជាប់ទៅនឹងឯកសារលេខ៥៧ នៅក្នុងភាសាខ្មែរលេខERN គឺមានលេខ 0002416 , លេខ ERN ជាភាសាអង់គ្លេស គឺលេខ 00178066 និងក្នុងភាសាបារាំងគឺ00242288 ។

នៅក្នុងឯកសារនេះ យើងមើលឃើញមានការប្រកាសលើកឡើងជាច្រើននៅថ្ងៃតែមួយ ហើយនៅយប់តែមួយការលើកឡើងនោះ ។ គឺថា អ្នកទោសត្រូវបានបញ្ជូនទៅស-២១ គឺនៅក្នុងវាក្យខណ្ឌពីរ គឺយប់នេះម៉ោងប្រាំពីរ ខ្ញុំនឹងបញ្ជូនជនក្បត់ពីមុន ជនក្បត់បួននាក់ថែមទៀត ហើយថ្ងៃនេះនៅម៉ោងដប់មួយយប់ខ្ញុំនឹងបញ្ជូនជនក្បត់បន្ថែមទៀត ។

សំណួររបស់ខ្ញុំនោះ គឺទាក់ទងទៅនឹងលិខិតនេះដែលលោកទទួលបានមុនពេលដែលការមកដល់ការបញ្ជូនមកដល់នៃអ្នកទោស ។ ខ្ញុំគិតថា នេះជាករណីបន្ទាន់ ថាតើវាមានការរៀបចំយ៉ាងម៉េច? ថាតើមានការរៀបចំយ៉ាងម៉េចនៅពេលដែលលោកទទួលលិខិតមួយនេះ ដែលចុះកាលបរិច្ឆេទថ្ងៃទី៣០ ខែឧសភា ដែលលិខិតនេះជម្រាបលោកអំពីការបញ្ជូននៃអ្នកទោសនៅថ្ងៃតែមួយ? ថាតើវាមានការរៀបចំយ៉ាងម៉េចបន្ទាប់ពីមានការបញ្ជូនលិខិតនេះមក? នៅពេលនោះថា តើលិខិតនេះត្រូវបានបញ្ជូនតាមរយៈដូចម្តេច? ហើយមានការរៀបចំយ៉ាងម៉េច? តាមរយៈ សុន សេន ឬក៏លោកធ្វើការឆ្លើយតបដោយភ្លាមៗ?

[១១:២៥:០០]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន នៅមន្ទីរ ស-២១ មានកន្លែងរង់ចាំទទួលជនជាប់ចោទ ដែលគេបញ្ជូនមក ។ មកដល់ថ្មើរណា ក៏មានអ្នកនៅចាំទទួលដែរ គឺពួកកងពិសេស ។ បើសិនជាយើងរំឭកដល់ទៅផែនទីស-២១ ភ្នំពេញដែលខ្ញុំគូរជូន កន្លែងរង់ចាំទទួលនេះ ខ្ញុំសរសេរអក្សរ “R” មិត្តហ៊ុយ នៅគ្រប់គ្រងចាំកន្លែងហ្នឹង ។ មកថ្មើរណា ក៏ទទួលបានៗដែរ ។ អង្គភាពណាបញ្ជូនមក ក៏បានដែរ ប៉ុន្តែ ឲ្យបាន

អនុញ្ញាតគេដឹងមុនពីខ្ញុំ បើកាលណាគេមិនដឹងមុនពីខ្ញុំទេ គេអត់ទទួលទេ ។

ដូច្នេះ ការរៀបចំ វាត្រៀមជាប់ជាប្រចាំសម្រាប់ទទួលមនុស្សគ្រប់អង្គភាពដែលគេបញ្ជូនមកកុំថាតែកងពល៥០២ ។ កងពលណាបញ្ជូនមកថ្មើរណាក៏បានដែរ ទទួល ឲ្យតែបានទទួលបញ្ជាពីខ្ញុំ គេរង់ចាំទទួលទាំងអស់ ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្តី៖**

តើលោកនិយាយថា វាមិនមានភាពចាំបាច់ ដែលលោកត្រូវតែទទួលលិខិតនេះ នៅថ្ងៃតែមួយ នៅពេលដែលមានការបញ្ជូន គឺនៅថ្ងៃតែមួយនៅម៉ោង៧នោះ ឬក៏យ៉ាងម៉េច? វាទាក់ទងទៅនឹងការទទួលលិខិតមួយនោះ នៅថ្ងៃនោះ ឬក៏យ៉ាងម៉េច?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! មេហៅទៅធ្វើការ ដល់បានលិខិតនេះមក មកដល់វិញ ខ្ញុំគ្រាន់តែហុចលិខិតនេះ ឬក៏ប្រាប់ឲ្យ មិត្តហ៊័ ឲ្យគេរង់ចាំទទួល ។ មួយថ្ងៃមកប្អូនប្រាំជើងក៏បានប៉ុណ្ណឹង ។ ម្តងបីប្អូននាក់ ពីរបីនាក់បាន គេចងហើយស្រេច ឬក៏គេដាក់ខ្នោះមកហើយស្រេច បាន អត់អីទេ អត់មានការរៀបចំអីជាពិសេសទេ ។ ស-២១ ត្រៀមខ្លួនរៀបចំទទួលទាំងអស់ ឲ្យតែមានបញ្ជាពីមេ ប៉ុន្តែបើគ្មានបញ្ជាពីមេ អត់ទទួលទេ ។

**លោកស្រី ស៊ីលឃី ស្វូតហ្សីនស្តី៖**

ខ្ញុំសន្និដ្ឋានទៅនឹងចម្លើយនេះ គឺថាមានមែន ។ ថាតើមានការរៀបចំពិសេសណាមួយក្នុងការទទួលអ្នកទោសមកពីកងពល៥០២ នៅពេលយប់ដែរឬទេ? អ្វីដែលយើងមើលឃើញនៅក្នុងលិខិតនេះ គឺវាពាក់ព័ន្ធនៅពេលយប់ ។ អ៊ីចឹងថា តើមានការរៀបចំពិសេសសម្រាប់ការទទួលនៅពេលយប់ពីកងពល៥០២ ដែរឬទេ?

[១១:២៨:៣៦]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន អ្នកទោសដែលគេបញ្ជូនមក ទោះយប់ក៏ដោយ ថ្ងៃក៏ដោយ ឲ្យតែដាក់ខ្នោះពីនាយមក ថ្មើរណាក៏មកបានដែរ ។ ឲ្យតែកងពិសេសគេបានទទួលបញ្ជាពីខ្ញុំរង់ចាំទទួល បើគ្មានបញ្ជាពីខ្ញុំទេ កុំចូល គេអត់ឲ្យចូលទេ ។ ដូច្នេះថ្មើរណាក៏បានដែរ គេមានមនុស្សចាំទទួលឲ្យតែដាក់ខ្នោះពីនាយឲ្យហើយមក ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី៖**

ដូច្នេះ វាមិនចាំបាច់ក្នុងការឲ្យលោកដឹងថា នៅថ្ងៃនោះ គឺមានពេលពីរ នៅថ្ងៃនោះពីរដង គឺក្នុងអំឡុងពេលម៉ោងប្រាំពីរទៅម៉ោងប្រាំបី ហើយនឹងក្នុងអំឡុងពេលពីម៉ោងដប់ទៅដប់មួយ គឺថានៅពេលនោះ គឺមានការបញ្ជូនអ្នកទោសទៅលោក ។ ដូច្នេះ វាមិនចាំបាច់ក្នុងការផ្តល់ព័ត៌មានទៅលោក អំពីការបញ្ជូនអ្នកទោសនោះទេ នៅពេលយប់នោះ ដែលមានការបញ្ជូនពីរដងនោះ ។ តើខ្ញុំលើកឡើងនេះត្រឹមត្រូវដែរឬទេ?

**ជនជាប់ចោទ៖**

សំបុត្រនេះ វាមកដល់ខ្ញុំមុនម៉ោង៧យប់ ។ ខ្ញុំប្រាប់គេឲ្យចាំទទួលម៉ោងប្រាំពីរយប់ ហើយនិងម៉ោងប្រាំបីយប់ ម៉ោង១១យប់ ។ គេចាំទទួលហើយ ក៏ប៉ុន្តែមិញ ក៏ចាំបាច់ពីរលើក? នេះគឺរឿងការរៀបចំខាង៥០២ទេ ដែលគេត្រូវបែងចែកជាពីរសង្វាក់យ៉ាងដូច្នេះ ។ ស-២១ រង់ចាំទទួលទាំងពីរសង្វាក់នេះដូច្នេះ បែងចែកជាពីរពេល ពីរលើកនេះ គឺខាង៥០២ទេ គេសុំបែងចែកអ៊ីចឹង ។ ឯចំណែក ស-២១ ម៉ោងដប់មួយយប់ក៏ទទួលបាន ម៉ោងមួយយប់ក៏ទទួលបាន ម៉ោងប៉ុន្មានក៏ទទួលបាន ឲ្យតែគេបានទទួលបញ្ជាពីខ្ញុំ គេត្រៀមខ្លួនចាំ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី៖**

ខ្ញុំកត់សម្គាល់ឃើញថា ចម្លើយរបស់លោកនៅពេលនេះ គឺវាមានលក្ខណៈផ្ទុយបន្តិចទៅនឹងអ្វីដែលលោកលើកឡើងមុនហ្នឹងបន្តិចនោះ ។ ដូច្នេះ គឺខ្ញុំសូមត្រឡប់ទៅនឹងសំណួរដំបូងរបស់ខ្ញុំមួយវិញថាតើមានការរៀបចំភ្លាមៗ ឬក៏រៀបចំយ៉ាងម៉េច នៅពេលលោកទទួលលិខិតថ្ងៃទី៣០ ខែឧសភា? គឺថាអាចទទួលលិខិតនេះមុនម៉ោងប្រាំពីរយប់ ។ អ៊ីចឹងវាអាចធ្វើឲ្យយើងយល់ទៅលើបញ្ហាហ្នឹង ។ ថាតើលោកអាចរៀបចំភ្លាមៗ ដើម្បីទៅជួបលោក សុន សេន ដើម្បីទទួលយកលិខិតនោះតាមរបៀបណា?

**ជនជាប់ចោទ៖**

ជាមួយមេ ហៅភ្លាមទៅភ្លាម ខ្ញុំអត់ឲ្យយូរលើសពីប្រាំមីនុតទេ ។ មេហៅស្លៀកពាក់ខោអាវយ៉ាងច្រើនប្រាំមីនុត ជិះម៉ូតូទៅដល់ហើយ មិនដែលឲ្យបានយូរទេ ហៅយប់បានយប់ ហៅថ្ងៃបានថ្ងៃ ។ ដូច្នេះ ហៅទៅដល់ ធ្វើការប្អូនដប់មីនុត ម្ភៃមីនុតយ៉ាងយូរ គាត់ហុចសំបុត្រនេះមក ខ្ញុំយកសំបុត្រនេះមកវិញ បញ្ជាឲ្យគេ ។ ដូច្នេះ គឺមេហៅខ្ញុំទេ ហៅទៅដល់ទទួលសំបុត្រ មកវិញចាត់ចែងភ្លាមៗ ឲ្យខាងនេះគេរៀបចំ ។ នេះដំណើរការធម្មតាដែល ស-២១ ចាត់ចែងកិច្ចការតាមបញ្ជារបស់មេ ។

[១១:៣៣:២០]

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សំណួរបន្ទាប់ទៀតរបស់ខ្ញុំ ហេតុអ្វីបានជា ស៊ូ ម៉េត ស្នើសុំលោកឲ្យមកធ្វើការ សុំលោកចំពោះចម្លើយសារភាព ហេតុអ្វីបានមិនសុំ សុន សេន ទៅលើចម្លើយសារភាព ដែល សុន សេន ជាអ្នកទទួលចម្លើយសារភាពនោះ? ហេតុអ្វីបានជាលោក ស៊ូ ម៉េត នោះ គាត់សុំចម្លើយសារភាពពីលោក? ហើយដោយសារតែលោកបានលើកឡើងថា លោកជាអ្នករៀបចំចម្លើយសារភាព?

**លោក ហ្រ្វង់ស្វ័រ រូ៖**

សំណួរនេះ គឺជាសំណួរដែលសួរជាន់គ្នា ហើយយើងបានលើកឡើងតាំងពីថ្ងៃដំបូង ។ ហើយតើមានគោលបំណងអ្វីក្នុងការសួរសំណួរបែបនេះ? គឺហាក់ដូចជាមិនមានការសួរច្បាស់លាស់ទៅលើចំណុចនេះ?

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព ហើយនឹងសំណួរនេះ គឺជនជាប់ចោទមិនបាច់ឆ្លើយទេ មេធាវីអាចប្តូរសំណួរផ្សេង ហើយប្រឹងប្រែងឲ្យមែនទែន បញ្ចៀសនូវសំណួរដែលច្រំដែល ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សំណួរបន្ទាប់របស់ខ្ញុំនោះគឺក្នុងចំណោមលិខិតទាំងប្រាំបួននេះ គឺយើងឃើញមានឯកសារលិខិតនេះចំនួនបី ដែលមានចំណារ ហើយនិងការលើកឡើងអំពីអង្គការ ហើយលិខិតឯកសារប្រាំមួយផ្សេងទៀតនោះ គឺមិនបានលើកឡើងអំពីអង្គការ ឬក៏មិនបានលើកឡើងអំពីថ្នាក់លើណាមួយនោះឡើយ ។

ខ្ញុំចង់សួរថា តើវាមានន័យថា ប្រសិនបើអង្គការមិនស្នើសុំឲ្យមានការយល់ព្រមនោះទេ ឬក៏ស្នើសុំការអនុញ្ញាតនោះទេ ដោយសារតែខ្ញុំឃើញអត់មានការនិយាយអំពីអង្គការនៅក្នុងឯកសារប្រាំមួយផ្សេងទៀត ។ បានន័យថា នៅពេលដែលមិនមានការស្នើសុំឲ្យមានការយល់ព្រម បានន័យថា ការយល់ព្រមនោះ មិនមានភាពចាំបាច់ទេ តើត្រឹមត្រូវដែរ០ឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន គ្រប់សេចក្តីសម្រេចក្នុងរឿងឃាត់ខ្លួន គ្រប់សេចក្តីសម្រេចក្នុងរឿងបញ្ជូនទៅ ស-២១ គឺអង្គការជាអ្នកសម្រេច ។ និយាយឲ្យចំ គឺ សុន សេន ឯចំណែកសំបុត្រដែលបានសរសេរឈ្មោះថាអង្គការ ឬមិនសរសេរ អាហ្នឹងវាជាបញ្ហាមួយផ្សេងទៀត ។ ក៏ប៉ុន្តែ គ្រប់

បញ្ហាទាំងអស់ ដែលបញ្ជូនទៅស-២១ ឃាត់ខ្លួនយ៉ាងម៉េចអី យ៉ាងម៉េច គឺសុន សេន ជាអ្នកសម្រេច ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមអរគុណ គឺខ្ញុំអស់សំណួរក្នុងការចោទសួរទៅកាន់ជនជាប់ចោទទៀតហើយ ។

[១១:៣៧:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បើមានសំណួរអ្វីត្រូវសួរ អាចសួរបានសូមអញ្ជើញ បាទ ។

**លោកស្រី រ៉ាបេសាន់ដ្រាតាណា៖**

សូមអរគុណលោកប្រធាន ។ ជនជាប់ចោទបានប្រាប់យើងមុនហ្នឹង ថាមេរបស់គាត់ គឺសុន សេន ហៅគាត់ក្នុងពេលទៀងទាត់ ក្នុងរយៈពេលម៉ោងប្រាំ ទៅម៉ោងប្រាំមួយ ជារៀងរាល់ថ្ងៃ គឺហៅគាត់ជាញឹកញាប់ ។ ថាតើការធ្វើដូច្នេះ គឺវាមានគោលបំណងនៅក្នុងការសន្ទនា ឬការនិយាយគ្នាជាមួយនឹងមេនោះ តើវាមានគោលបំណងយ៉ាងម៉េច?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! មេខ្ញុំយកចិត្តទុកដាក់ចំពោះការសួរចម្លើយមនុស្សសំខាន់ៗ ដែលគាត់ប្រគល់ឲ្យយើងខ្ញុំសួរចម្លើយ ។ នេះជារបៀបវារៈទីមួយនៃការសន្ទនារវាងខ្ញុំហើយនិងគាត់ ។ ហើយទីពីរ គាត់តែងតែសួរខ្ញុំអំពីមនុស្សផ្សេងទៀត ដែលមានសារសំខាន់ដែរ តែមិនបន្ទាន់ ។ ហើយរបៀបវារៈទីបី គាត់ចូលចិត្តសួរខ្ញុំពីសភាពការណ៍ទូទៅនៅស-២១ ។

ឧទាហរណ៍ ខាងកងពលនេះ ដែលគាត់សម្រេចឲ្យបញ្ជូនមក គេបញ្ជូនមកដល់ហើយនៅ ។ ហើយពេលខ្លះក៏វាមានបញ្ចប់ដោយការសន្ទនា របៀបនិយាយគ្នាឲ្យបានជិតស្និទ្ធបន្តិចដែរ រវាងខ្ញុំហើយនិងគាត់ ។ នេះខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណោះ ។

[១១:៤១:០៥]

**លោកស្រី រ៉ាបេសាន់ដ្រាតាណា៖**

សូមអរគុណ ។ នេះគឺជាអ្វីដែលលោកបាននិយាយ គឺថាលោកត្រូវរាយការណ៍ទៅប្រធានរបស់លោក ។ តើលោកជឿថានៅក្នុងបរិបទនៃការសន្ទនាគ្នានោះ ដែលកើតឡើងជាញឹកញាប់ និងការសន្ទនាតាមការទូរស័ព្ទដែលជាមានលក្ខណៈសាមញ្ញ ហើយដែលថាមិនទុកនូវបន្សល់នូវស្លាកស្នាមអ្វីទេនោះ

តើលោកគិតថាសេចក្តីសម្រេចរបស់ប្រធានរបស់លោកហ្នឹង គឺត្រូវបានបង្កើតឡើង ហើយក្រោយមកត្រូវបានបញ្ជូនទៅតាមអង្គភាពពាក់ព័ន្ធនានា មានន័យថាគឺបញ្ជូនទៅលេខាឈ្មោះស៊ូ ម៉េត ជាដើមនោះ?

**ជនជាប់ចោទ៖**

លោកប្រធានខ្ញុំស្តាប់សំណួរគាត់អត់ទាន់បានច្បាស់ទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីរៀបចំសំណួរម្តងទៀត សំណួរនេះជនជាប់ចោទស្តាប់មិនយល់ទេ ។ អ៊ីចឹង គាត់មិនអាចឆ្លើយនឹងសំណួរមេធាវីបានទេ រៀបចំសំណួរសាជាថ្មី បញ្ហាទីមួយ ។ បញ្ហាទីពីរ អង្គជំនុំជម្រះសូមរំឭកសូមឲ្យភាគីទាំងអស់ដែលពាក់ព័ន្ធបង្វែរអារម្មណ៍ឲ្យចំនឹងអង្គហេតុ និងបញ្ហាដែលត្រូវលើក គឺពិភាក្សាលើខ្លឹមសារពាក់ព័ន្ធជាមួយនឹងលិខិតចំនួនប្រាំបួន ដែលចម្រូងចម្រាសកាលពីម្សិលមិញ ។ នេះជាទម្ងន់នៃគោលដៅ ឬក៏មុខសញ្ញាត្រូវពិភាក្សាដេញដោលនាពេលនេះ ។

**លោកស្រី វ៉ាំបេសាន់ជ្រាតាណា៖**

ខ្ញុំនឹងនិយាយឡើងវិញ ។ សំណួររបស់ខ្ញុំ គឺទាក់ទងទៅនឹងអ្វីដែលលោកទើបតែបាននិយាយ ។ ខ្ញុំចង់ដឹងថា តើដំណើរការនៃការធ្វើសេចក្តីសម្រេចនោះវាកើតឡើងយ៉ាងម៉េច? ហើយជនជាប់ចោទបានពន្យល់ប្រាប់ថា សេចក្តីសម្រេចហ្នឹង គឺចេញមកពីប្រធានរបស់គាត់ គឺចេញមកពី សុន សេន ។ មានន័យថា គឺត្រូវតែមានការពិភាក្សាគ្នាមុននឹងចេញសេចក្តីសម្រេចចិត្តនោះ ។ តើលោកជឿថា នៅពេលដែលលោកធ្វើការរាយការណ៍ទៅប្រធានរបស់លោកហ្នឹង សេចក្តីរាយការណ៍ហ្នឹងឯង គឺនឹងអាចមានឥទ្ធិពលទៅលើការសម្រេចចិត្តរបស់គាត់ឬ? ឬមួយតែរបាយការណ៍របស់គាត់នោះមាន ឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្តរបស់គាត់?

[១១:៤៣:៤៨]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន ។ សេចក្តីរាយការណ៍របស់ខ្ញុំ វាពិតជាមានឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់មេមែន ។ ក៏ប៉ុន្តែ ខ្ញុំពេលសន្ទនាជាមួយនឹងគ្នាហ្នឹង គឺជាអ្នកឆ្លើយនឹងសំណួររបស់គាត់ ដូច្នេះ វាមានការកែតម្រូវរបស់គាត់មកលើខ្ញុំផងដែរ ដើម្បីជំរុញការងារឲ្យកាន់តែលឿន ឲ្យកាន់តែល្អ ឲ្យកាន់តែរហ័សតទៅទៀត ។

**លោកស្រី វ៉ាំបេសាន់ជ្រាតាណា៖**

សូមអរគុណ ។ សំណួរចុងក្រោយរបស់ខ្ញុំ លោក សុន សេន តើលោក សុន សេន ជឿទុកចិត្ត ទៅលើលោកដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមឆ្លើយមួយម៉ាត់ទេ មេខ្ញុំហាក់ដូចជាជឿទុកចិត្តខ្ញុំៗមែន ទែន ខ្ញុំក៏ដូចជា នេះជារឿងពិត ។

**លោកស្រី វ៉ាំបេសាន់ជ្រាតាណា៖**

លោកប្រធាន ខ្ញុំមិនមានសំណួរទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងដើមបណ្តឹងក្រុមបួន តើមានសំណួរអ្វីឬទេ ពាក់ព័ន្ធជាមួយនឹងឯកសារទាំងប្រាំបួន នេះចំពោះជនជាប់ចោទ? បើមានសូមអញ្ជើញ!

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមានសំណួរខ្លះៗមិនជាវែងទេ ហើយក៏ទាក់ទងជាមួយ នឹង សំណួរលោកចៅក្រម លោកព្រះរាជអាជ្ញាខ្លះដែរ ដែលខ្ញុំបាទស្តាប់ទៅដូចជាមិនយល់ ។ អ៊ីចឹងទាក់ទង នឹងសំណួរទៅលើលិខិត ឬឯកសារទាំងប្រាំបួន ដែលលោកព្រះរាជអាជ្ញាបានដាក់ស្នើដើម្បីធ្វើការជជែក នេះ ។ ខ្ញុំបាទចាប់អារម្មណ៍ទៅលើលិខិតដែលយើងកំពុងជជែកនេះ ។ អម្បាញ់មិញ ខ្ញុំបាទបានឮសួរ លោក ឌុច បានជម្រាបទៅលោកប្រធាននិងអង្គសវនាការ ថាលោក ស៊ូ ម៉េត ហ្នឹង មានការទទួលខុស ត្រូវ ឬក៏មានឋានៈដូចជាធំជាងគាត់ តើខ្ញុំសួរនេះស្តាប់បានទេ ត្រឹមត្រូវដែរឬទេ?

[១១:៤៧:១៩]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ទីមួយ ស៊ូ ម៉េត ធំជាងខ្ញុំ ពីព្រោះក្នុងផ្ទៃបក្ស ស៊ូ ម៉េត ជាសមាជិក ជំនួយការមជ្ឈិម ឯចំណែកខ្ញុំជាសមាជិក អ៊ូ! ជាបក្ខជនធម្មតា នេះទីមួយ ។ ទីពីរ គណៈកម្មាធិការ កងពល វាធំជាងគណៈកម្មាធិការមន្ទីរ ដើម្បីស្រួលយល់ទាំងអស់គ្នា ខ្ញុំសូមលោកពិនិត្យមើលគណៈ កម្មាធិការស-២១ ប្រៀបធៀបទៅនឹងគណៈកម្មាធិការស-៧១ ដែលខ្ញុំសរុបជូនរួចហើយ ។ គណៈ កម្មាធិការស-៧១ មានដប់បី គណៈកម្មាធិការនៅពីក្រោម ។ ឯចំណែកគណៈកម្មាធិការ ស-២១ មាន

តែមួយទេ ។ ដូច្នេះ ប្រៀបធៀបលើផ្លូវបក្ស ស៊ូ ម៉េត ធំជាងខ្ញុំ ។

**លោក ហុង គីមសួន៖**

បាទ, សូមអរគុណ ។ សំណួរដែលខ្ញុំសួរនេះ គឺចង់ដឹងទាក់ទងជាមួយនឹងលោក ឌុច តែងតែអះអាងថា មេរបស់គាត់មាន វន វ៉េត មាន សុន សេន ។ អ៊ីចឹង ក្នុងនេះ គឺខ្ញុំបាទចង់សួរទាក់ទងថា រាល់លិខិតស្នាមដែលយើងកំពុងជជែកនេះ ផ្ញើមកមន្ទីរស-២១ គឺមានន័យថាផ្ញើមកឲ្យប្រធានមន្ទីរ ស-២១ គឺលោក ឌុច នេះឯង ។ អ៊ីចឹង ដែលគាត់អះអាងថា រាល់លិខិតស្នាម ដូចជាយើងលើកឡើងនេះ ទាក់ទងជាមួយលិខិតផ្ញើចូលស-២១ ដើម្បីឲ្យសាកសួរទៅលើមនុស្សដែលចាត់ទុកថាជាខ្មាំង តើមនុស្សទាំងអស់និយាយអំពីអ្នកដែលបញ្ជូនមក ស-២១ ត្រូវតែឆ្លងកាត់ សុន សេន ឬ ត្រូវតែ សុន សេន ពិនិត្យមើលសិនដែរឬទេ?

**ជនជាប់ចោទ៖**

សូមជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះទូលាយ ។ ដូច្នេះ ខ្ញុំសូមញែកបញ្ហាតាមក្របខ័ណ្ឌអង្គភាពនីមួយៗ ។ នៅក្នុងក្របខ័ណ្ឌកងទ័ពមជ្ឈិម ដែល សុន សេន គ្រប់គ្រង ។ សុន សេន ជាអ្នកសម្រេចៗ ឲ្យចាប់និងមិនឲ្យចាប់ សម្រេចឲ្យបញ្ជូនមកស-២១ ពេលណា ទៅប៉ុន្មាននាក់គាត់ជ្រាប ដោយគាត់ធ្វើការជាមួយនឹងប្រធានអង្គភាពរបស់គេ នេះខ្ញុំនិយាយអំពីក្របខ័ណ្ឌកងទ័ពមជ្ឈិម ព្រោះគាត់ជាសេនាធិការក្នុងក្របខ័ណ្ឌកងទ័ពមជ្ឈិម គាត់ទទួលសិទ្ធិឲ្យមានសិទ្ធិសម្រេចកម្ទេច មានចែងនៅក្នុងឯកសារថ្ងៃ៣០ មីនា ១៩៧៦ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ អ៊ីចឹង ខ្ញុំបញ្ជាក់បន្តិច មានន័យថា សុន សេន គ្រាន់តែសម្រេច ទៅតាមអ្នកដែលស្នើទៅ គាត់ជឿឬមិនជឿតែប៉ុណ្ណោះអ៊ីចឹងមែនទេ?

**ជនជាប់ចោទ៖**

ទីមួយ បញ្ហាម្ចាស់អង្គភាពគេស្នើ តើគាត់ឲ្យឬមិនឲ្យ ឧទាហរណ៍ដូចក្នុងនេះអ៊ីចឹងឈ្មោះស្អីអំមិញ ម្ចាស់អង្គភាពគេស្នើដោយវាមានបាតុភាពនៅក្នុងអង្គភាព តើគាត់ព្រម ឬមិនព្រម ។ ទីពីរ កាលណាមានឯកសារទៅពីស-២១ គាត់យកទៅពិនិត្យ ដល់គាត់ពិនិត្យហើយ គាត់ហៅម្ចាស់អង្គភាពគេ មកពិគ្រោះ ដើម្បីឯកភាពគាត់ហើយនិងគេ ជាពិសេសគេទេ គេចង់ទុកប៉ុន្មាននាក់ អីប៉ុន្មាននាក់អាហ្នឹងជាសិទ្ធិរបស់គេ ។ គាត់ទុកសិទ្ធិឲ្យគេមួយកន្លែងហ្នឹងដែរ នេះក្នុងកងទ័ពមជ្ឈិម ។ សូមបញ្ជាក់ថា ក្រៅពី

កងទ័ពមជ្ឈិមគាត់គ្មានសិទ្ធិសម្រេចទេ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ សំណួរមួយទៀត ខ្ញុំសួរទាក់ទងអំពីដែលលិខិត ក្នុងនេះយើងឃើញលិខិតចេញពីឈ្មោះ ស៊ូ ម៉េត ច្រើន ខ្ញុំសូមសួរទាក់ទងនឹងសម្តីរបស់លោក ឌុច ជម្រាបលោកប្រធានអម្បាញ់មិញថា ទាក់ទងនឹងកងពលលេខ៥០២ ជាកងទ័ពអាកាស ឬក៏ខាងអាកាសចរណ៍ស៊ីវិល ឬក៏យោធានោះ ខ្ញុំមិនទាន់បានសួរដល់ទេ ។ តែសួរថា ក្នុងនាមគាត់ដូចជាអ្នកយកចិត្តគេ ឬយកចិត្តមេ ហើយគាត់បាននិយាយភាសាបារាំងថែមបន្តិចទៀតដែលខ្ញុំស្តាប់អត់បាននោះ ។ អ៊ីចឹងពាក្យថា ពេលទទួលលិខិតពី ស៊ូ ម៉េត ក៏ដោយ ឬក៏ធ្វើអ្វីផ្សេងក៏ដោយ ប៉ុន្តែ ក្នុងនេះខ្ញុំនិយាយពីរឿងលិខិត ស៊ូ ម៉េត ឲ្យសាកសួរទាក់ទងនឹងលិខិតលេខ ERN ជាភាសាខ្មែរ 00002423 ភាសាអង់គ្លេសខ្ញុំអត់មានទេ ។ អ៊ីចឹង អម្បាញ់មិញលោកព្រះរាជអាជ្ញាក៏បានសុំអនុញ្ញាតលោកប្រធានដាក់បញ្ចាំងដែរ ប៉ុន្តែក្នុងនេះខ្ញុំសួរគាត់គ្រាន់តែបញ្ជាក់ទេ ដូចនៅក្នុងចំណុចទីបី ដែលឈ្មោះ--

**ប្រធានអង្គជំនុំ៖**

ចេះដាក់ៗចុះថ្ងៃផង លិខិតនុ៎ងចុះថ្ងៃណា ថ្ងៃ២ ខែ៦ ៧៧ មែនទេ? ១៩៧៧? ដើម្បីព្រោះខាងភាសាបរទេសយើងអត់បានឲ្យលេខ ERN គាត់ទេ អ៊ីចឹងឲ្យលេខលិខិតហ្នឹង ហើយនិងលេខលិខិតចុះថ្ងៃទី២ ខែ៦ ១៩៧៧ ណ៎ា អ៊ីចឹងមែនទេ?

[១១:៥៣:៥០]

**លោក ហុង គីមសួន៖**

បាទ, ត្រឹមត្រូវលោកប្រធាន ។ បាទអ៊ីចឹងខ្ញុំសូមអានម្តងទៀត លេខ ERN អំមិញហ្នឹងខ្ញុំបាទបាន ជម្រាបហើយ អ៊ីចឹងលិខិតនេះធ្វើនៅថ្ងៃទី២-៦-៧៧ ប្រហែលមានន័យថា ថ្ងៃទី២ ខែ៦ ឆ្នាំ១៩៧៧ ជ.គណៈបញ្ជាការកងពល៥០២ ម៉េត និងហត្ថលេខា ។ អ៊ីចឹង នៅក្នុងចំណុចលេខបី ដែលមានឈ្មោះ គឹប រ៉ុក ដែលនិយាយអំពីឈ្មោះនេះមិនទាន់ឃើញមានខ្មាំងណាម្នាក់សារភាពនៅឡើយដែរ ។ ប៉ុន្តែ សកម្មភាពឈ្មោះនេះ តាមខ្ញុំពិនិត្យផ្ទាល់ ថាវាជាខ្មាំងតែម្តង ។ អ៊ីចឹង ក្នុងន័យនេះខ្ញុំបាទចង់សួរតាមរយៈលោកប្រធានឲ្យលោក ឌុច បញ្ជាក់បន្តិចមកវិញ ព្រោះអំមិញនេះយើងបានស្តាប់ បានឮខ្ញុំមិនទាន់ច្បាស់ ។ ទាក់ទងនឹងការសរសេរជម្រាបមកសមមិត្តបងឌុច ស្នេហាសូមជ្រាបនេះ លោកឌុច បាន ជម្រាបថា គឺជាគំនិត ឬជាការបិទបាំងឈ្មោះរបស់មេតែប៉ុណ្ណោះ ។ អ៊ីចឹង គឺមេឲ្យអ្នកណាសរសេរ

មក? មានន័យថា ក្នុងនេះលោក ម៉េត ឬក៏សមមិត្ត ស៊្វំ ម៉េត សរសេរមក ក្នុងនាម សុន សេន បង្គាប់បញ្ជាក៏មិនដឹង ។ ប៉ុន្តែ ក្នុងន័យនេះ ខ្ញុំសួរមិញទាក់ទងថា តើឈ្មោះដែលចាត់ទុកថាជាខ្មាំង ដែលគ្រាន់តែ ស៊្វំ ម៉េត សរសេរមក សុន សេន ហើយ សុន សេន បញ្ជូនឯកសារនេះមក ស-២១ ឬក្នុងនេះមិន ស-២១ មួយទេ ដាក់សមមិត្តបង ឌុច ចប់ ។

អំមិញលោក ឌុច មានប្រសាសន៍ថា កងពល ឬក៏អង្គភាពគេនីមួយៗមានសិទ្ធិសម្រេចទៅតាមសេចក្តីសម្រេចរបស់មជ្ឈិមបក្សស្តីពីការកម្ទេចនោះ ។ តើចំណុចប៉ុណ្ណឹង ខាងស-២១ ដែលមានលោក ឌុច ជាប្រធាន សួរយកចំណុចណាដើម្បីទៅផ្គាប់ចិត្តមេ ដូចលោកបានមានប្រសាសន៍ ដូចលោកបានមានប្រសាសន៍ថា ក្នុងនាមគាត់អ្នកយកចិត្តមេ? សូមលោកបំភ្លឺបន្តិចកន្លែងហ្នឹង ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ទីមួយអំពីការសម្រេចចាប់មនុស្សម្នាក់ ។ របៀបសម្រេចចាប់មនុស្សម្នាក់មានពីរយ៉ាង ។ ទីមួយ គឺអង្គភាពគេរាយការណ៍ មេពិចារណាជាមួយម្ចាស់អង្គភាពគេគាត់យល់ស្រប ដែលគាត់ត្រូវការជាបន្ទាន់ គាត់ឲ្យស-២១ រត់ឲ្យគាត់ ដោយប្រើពាក្យទន់ភ្លន់ គាត់មិនបញ្ជាចំទេ ។ គាត់ថាមិត្តជួយនិយាយបន្តិចទៅ អាហ្នឹងដូចជាសាហាវណាស់ ថែមទៀតមក ហ្នឹងហើយបានៗវាចេញអាលិខិតឲ្យម្ចាស់អង្គភាពគេរាយការណ៍ ។ ក៏ប៉ុន្តែ មិនមែនថារាយការណ៍ទៅឲ្យគាត់គាត់ស៊ីញ៉េជាផ្លូវការអីទទឹងទទែងទេ គឺធ្វើរបៀបនេះ ដើម្បីជំរុញការខ្នះខ្នែងរបស់ខ្ញុំ ឲ្យខ្ញុំខិតទៅទៀត ។ គាត់ទម្លាក់ការទទួលខុសត្រូវឲ្យរកចម្លើយឲ្យឆាប់បាន មកលើខ្ញុំ នេះគឺរបៀបធ្វើការរបស់មេ ។

ដូច្នេះ មូលដ្ឋានប៉ុណ្ណេះ វាមិនមានអីធ្ងន់ធ្ងរសម្រាប់ជាប្រភពឲ្យកម្មាភិបាលសួរចម្លើយគេសួរទេ ។ ក្នុងកាលណាបានមនុស្សទៅ កម្មាភិបាលសួរចម្លើយយើងខ្ញុំ ខ្ញុំស្គាល់កម្រិត ។ អ្នកណាដែលអាចបម្រើការងារនេះបានរហ័ស ខ្ញុំឲ្យទៅអ្នកនុ៎ង ។ មាគ៌ាសម្រាប់សួរចម្លើយខ្ញុំបានកំណត់ហើយ មនុស្សដែលបក្សចាប់មក ត្រូវសន្មតថាខ្មាំង បើអ្នកឯងមិនសន្មតថាខ្មាំងទេ សួរចម្លើយមិនចេញទេ ។ ខ្ញុំនិយាយប៉ានិយាយត្រង់តែប៉ុននុ៎ងទេ ។

ដូច្នេះ ព័ត៌មានប៉ុណ្ណេះ វាមិនជាប្រភពអីច្រើនណាស់ណាសម្រាប់សួរចម្លើយទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ ខ្ញុំសូមលើកយកឯកសារលេខ ERN ជាភាសាខ្មែរចុះថ្ងៃទី១៦ ខែ៩ ឆ្នាំ១៩៧៦

ម៉ោងដប់ប្រាំមួយនិងដប់ប្រាំនាទី ដែលជាកំណត់នៃការប្រជុំសមមិត្តតាល់ កងពល២៥០ និងកងពល ១៧០ ដែលពីម្សិលមិញនោះ ខ្ញុំបាទស្ដាប់ទៅមិនទាន់បានយល់ច្បាស់ ។ ទាក់ទងនឹងការបដិសេធរបស់លោកៗ ឌុច ត្រង់ទំព័រទីពីរ ដែលមានលេខ ERN00002234 កន្លែងបន្ទាត់ទីពីរ ដែលសរសេរថា សមមិត្ត ឌុច មានមតិ ។ សូមអនុញ្ញាតលោកប្រធានឲ្យគាត់ពន្យល់ឡើងវិញ ព្រោះលោក ឌុច បដិសេធម្សិលមិញថា គាត់ឥតមានមតិទេ ពីព្រោះនេះជាមតិរបស់ បង៨១ ។ អ៊ីចឹង សូមឲ្យគាត់ពន្យល់ឡើងវិញបន្តិចទាក់ទងថា នៅទំព័រទីមួយ ហេតុអ្វីមានដាក់សរសេរថា "ប្រជុំបន្ត" នៅក្នុងបន្ទាត់ចុងក្រោយ "បង៨១ បើកការប្រជុំ" ហើយជាចំណុចបន្តបន្ទាប់ វាមានន័យថាជាសម្ដីរបស់ ៨១ ។ ដល់មកដល់ទំព័រទីពីរមានតែសមមិត្ត ឌុច មានមតិ ហើយគ្រដូចគ្នា មិនឃើញបើកវង់ក្រចកថា គ្មានមតិទេ ។ ប៉ុន្តែបន្ទាប់ពីពាក្យនេះមក លោកឌុច ឆ្លើយថា ជាមតិរបស់លោក ៨១ ដដែល ។ អ៊ីចឹងសូមឲ្យគាត់បញ្ជាក់បន្តិច ព្រោះកន្លែងហ្នឹងវាទាក់ទងស្ដីពីក្រោយប្រជុំមកសមមិត្ត តាត សមមិត្តសុខ អីហ្នឹងសម្រេចឯកភាពគ្នា ដើម្បីយកមនុស្ស១៥នាក់ ក្នុងនេះ ។ អ៊ីចឹងសូមឲ្យបញ្ជាក់អំពីចំណុចបន្ទាត់ទីពីរ ដែលលោកថា អត់មែនជាមតិរបស់លោកចូលរួមសម្រេច និងទំព័រទីមួយដែលមានសរសេរដាក់មតិ៨១ ប៉ិានដាក់ ដល់ទំព័រទីពីរមិនដាក់ ។ សូមអញ្ជើញ ។

**ប្រធានអង្គជំនុំ៖**

នៅក្នុងចំណោមលិខិតទាំងប្រាំបួននេះទេ? នៅក្នុងចំណោមលិខិតទាំងប្រាំបួនដែលកំពង់តែលើកជាកម្មវត្ថុនៃកិច្ចពិភាក្សានាពេលនេះទេ?

**លោក ហុង គឹមសួន៖**

ក្នុងនេះខ្ញុំបានទទួលមករួមគ្នាមក មិនដឹងមួយណាជាទីមួយ, ទីពីរ, ទីបី, ទីបួននោះទេ ។ ព្រោះម្សិលមិញនេះ ដែលខ្ញុំមិនយល់ហ្នឹង តើវាប់បញ្ចូលទៅក្នុងលិខិតទាំងប្រាំបួនដែរឬទេ?

[១២:០១:១២]

**ប្រធានអង្គជំនុំ៖**

លិខិតដែលលោកលើកឡើងមិនទាន់ទិនជាមួយនឹងលិខិតទាំងប្រាំបួនទេ ហើយដូចរបៀបវារៈនៃការជជែកពិភាក្សាពេលនេះ គឺជុំវិញលើលិខិតទាំងប្រាំបួន ។ ដូច្នេះ ជនជាប់ចោទមិនបាច់ឆ្លើយនឹងសំណួរនេះទេ ។ មេធាវីអាចតាំងសំណួរផ្សេងទៀត ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ដែលបានណែនាំខ្ញុំបាទ ។ អ៊ីចឹងខ្ញុំបាទសូមបង្វែរមកសំណួរផ្សេងទៀត ។ ខ្ញុំបាទសូមបន្តសំណួរទាក់ទងជាមួយនឹង លោក ស៊ូ ម៉េត ដដែល ដែលការចង់បានឲ្យ ស-២១ សាកសួរជំនួសដែលត្រូវចាប់បញ្ជូនមក ។

ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យខ្ញុំថា នេះចូលសំណួរមុនបន្តិច គ្រាន់តែចង់បញ្ជាក់ថា លោកដឹងទេថាមូលហេតុអ្វីដែល ស៊ូ ម៉េត ជាប្រធានកងពលមួយមានសិទ្ធិសម្រេចមួយ មិនសួរខ្លួនឯង បែរជាបញ្ជូនមកឲ្យស-២១ សួរ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! អង្គភាព៥០២ របស់ ស៊ូ ម៉េត ជាអង្គភាពទ័ពអាកាស ភារកិច្ចរបស់គេគឺការពារដែនអាកាសកម្ពុជា ហ្វឹកហ្វឺនអ្នកបើកបរយន្តហោះ គ្រប់គ្រងអង្គភាពនេះកុំឲ្យខ្មាំងបំផ្លាញបាន ។ ឯចំណែក រឿងស្រាវជ្រាវដោយសួរចម្លើយ គឺជាជំនាញរបស់ស-២១ ដែលស្ថិតនៅក្រោមមេតែមួយជាមួយគ្នាគឺ សុន សេន ។

**លោក ហុង គឹមសួន៖**

សូមអរគុណ ។ អ៊ីចឹងជាសំណួរចុងក្រោយ ហើយក៏ទាក់ទងជាមួយនឹងរាល់លិខិត ស៊ូ ម៉េត ដដែល ។ ទាក់ទងនឹងពាក្យថា ក្នុងនាមលោកជាអ្នកយកចិត្តមេ ឬក៏យកចិត្តគេ ការណ៍ដែលលោកបង្គាប់បញ្ជាឲ្យកូនចៅ ឬអ្នកក្រោមបង្គាប់សាកសួរចម្លើយនោះ ដូចអម្បាញ់លោកថា ត្រឹមលិខិតប៉ុណ្ណឹងនេះ ចេញមកវាអត់ទាន់គ្រប់គ្រាន់ទេ វាអត់មានន័យទេ ។ លោកអ្នកកំណត់ចំណុចឲ្យកូនចៅលោកសួរដើម្បីយកជាចម្លើយសារភាពជូនទៅមេវិញ ឬមួយយ៉ាងម៉េច? កន្លែងនេះសូមបញ្ជាក់បាទ ។ នេះជាសំណួរចុងក្រោយ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! មនុស្សដែលបញ្ជូនទៅស-២១ មួយភាគត្រូវគេចាប់ដោយសារចម្លើយរបស់ស-២១ តែមួយភាគផ្សេងទៀត គេចាប់មកដោយមិនដឹងមូលដ្ឋានស្អីទេ ។ ម្ល៉ោះហើយស-២១ ត្រូវពុះពារសួរ ។ ហើយរបៀបសួរដដែលជាដដែលទេ ធ្វើប្រវត្តិសកម្មភាពក្បត់ ។ ដូច្នេះ យើងខ្ញុំអត់បានព័ត៌មានអីពីក្រៅមក ដើម្បីឲ្យផ្តល់ឲ្យកូនចៅទេ ពឹងពាក់ឲ្យកូនចៅខំស្រាវជ្រាវប្រវត្តិសកម្មភាពក្បត់របស់បុគ្គលដែលគេចាប់បញ្ជូនមកហ្នឹង ប៉ុណ្ណឹង ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំមានតែប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

លោកហ្វ្រង់ស្វ័រ រូ មានសំណួរអ្វីពាក់ព័ន្ធជាមួយនឹងជនជាប់ចោទជាកូនក្តីរបស់លោក ពាក់ព័ន្ធទៅនឹងឯកសារប្រាំបួននេះដែរឬទេ? លោកមេធាវីការពារក្តី តើមានដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! មេធាវីការពារក្តីចំណែកខាងខ្ញុំ ជាមេធាវីជាតិ មិនមានអ្វីដែលជាសំណួរសម្រាប់សួរទៅជនជាប់ចោទទេ ។ ពីព្រោះឯកសារទាំងប្រាំបួននេះ ទាំងសហព្រះរាជអាជ្ញា ទាំងមេធាវីជាតិ ទាំងមេធាវីអន្តរជាតិ បានដាក់នៅចៅក្រមស៊ើបអង្កេត បានសួរគ្នាដេញដោលគ្នា ពីព្រោះស៊ើបអង្កេតនោះវារយៈពេលជាងមួយឆ្នាំ ។ ដូច្នេះ មេធាវីខាងខ្ញុំនេះមិនមានអ្វីនឹងសួរជាបន្តទៅទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកហ្វ្រង់ស្វ័រ រូ តើមានទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំធ្វើការកត់សម្គាល់មួយទៅលើបញ្ហានេះ លោកប្រធាន ។ ខ្ញុំសង្កេតឃើញថា យើងចំណាយពេលមួយព្រឹកហើយ សួរជនជាប់ចោទ អំពីលិខិតដែលបញ្ជូនមកគាត់ដោយបុគ្គលមួយរូប ។ វាបង្ហាញថា វាសមហេតុផលចំពោះខ្ញុំ ប្រសិនសហព្រះរាជអាជ្ញាសួរទៅកាន់បុគ្គលដែលបញ្ជូនលិខិតនោះ ។ យើងចំណាយពេលរយៈពេលបីម៉ោងសួរសំណួរទៅកាន់ ឌុច ដោយផ្អែកទៅលើលិខិតដែលគាត់ទទួលបានពី ស៊ូ ម៉េត ហើយមិនឃើញមានលិខិតពីលោក ឌុច ផ្ញើទៅកាន់លោក ស៊ូ ម៉េត នោះទេ ។ ដូច្នេះសំណួរដែលសួរទៅកាន់ ឌុច គួរតែសហព្រះរាជអាជ្ញាសួរទៅកាន់លោក ស៊ូ ម៉េត ទៅវិញទេ ។ វាមានលក្ខណៈសមហេតុសមផលចំពោះខ្ញុំ ហើយវាមានលក្ខណៈងាយស្រួល ។ ហេតុអ្វីបានជា ឌុច នៅទីនេះ? ហើយនៅទីនេះតែម្នាក់ឯងទេ ។

[១២:០៧:២៤]

ហើយប្រសិនបើគាត់មិនត្រូវបានគេនិយាយលាបមាត់ដាក់ទេនោះ ជាអ្នកទទួលថ្នាក់ទេនោះ គឺខ្ញុំគួរតែទុកបញ្ហានេះឲ្យធ្វើការពិចារណាទៅលើចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីឈប់ពិសាអាហារថ្ងៃត្រង់រហូតដល់សវនាការត្រូវលើកទៅបន្តនៅម៉ោងមួយកន្លះ នារសៀលនេះ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយនិងឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅវេលាម៉ោងមួយកន្លះរសៀលនេះ ។ ហើយលោកបណ្ឌិត អេតធេសាន់ គឺអង្គជំនុំជម្រះអរគុណនូវការអត់ធ្មត់របស់លោក ដោយសារមូលហេតុការបារម្ភ និងការគិតទុករបស់អង្គជំនុំជម្រះថា អាចមានសំណួរពាក់ព័ន្ធទៅ អាចឆ្លើយឆ្លងគ្នាពាក់ព័ន្ធជាមួយនឹងលិខិតទាំងឡាយដែលលើកឡើងដោយភាគីនៅក្នុងការសួរដេញដោលនេះ ទើបទុកឲ្យមានវត្តមានលោកនៅទីនេះ ដើម្បីអាចជាយថាហេតុក្នុងការឆ្លើយតប ប៉ុន្តែមួយព្រឹកហើយអត់មានទេ ។ អ៊ីចឹង គឺអរគុណនៃការអំណត់អត់ធ្មត់របស់លោក ដែលអង្គុយស្ងៀមពេញមួយព្រឹកនេះ ។ ហើយអង្គជំនុំជម្រះសង្ឃឹមថា លោកនឹងបន្តមករសៀលនេះ ដើម្បីបំពេញតួនាទីផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីពាក់ព័ន្ធជាមួយនឹងលិខិត ឯកសារដែលបានលើកឡើង ពាក់ព័ន្ធជាមួយអង្គហេតុដែលបានធ្វើសវនាការនេះ ។ អ៊ីចឹង សូមលោកអញ្ជើញមកកាន់សាលសវនាការជាថ្មីម្តងទៀត នៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:០៩ ដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើបណ្ឌិត ក្រេក អេតធេសាន់ អ្នកជំនាញជាបន្តទៀត ហើយកាលពីមុនយើងបានធ្វើការពិភាក្សាដេញ ដល់ខាងសហព្រះរាជអាជ្ញា ។ ហើយតាមការយល់របស់ខ្ញុំ គឺសហព្រះរាជអាជ្ញានៅមានសំណួរពាក់ព័ន្ធជាមួយនឹងអ្នកជំនាញរូបនេះមួយចំនួនទៀត ។ អ៊ីចឹង ជាកិច្ចបន្តនេះ សូមអញ្ជើញសហព្រះរាជអាជ្ញា ដើម្បីធ្វើការតាំងសំណួរពាក់ព័ន្ធជាមួយនឹងអ្នកជំនាញ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ ខ្ញុំនៅសល់តែមួយសំណួរប៉ុណ្ណោះសម្រាប់លោកក្រេក អេតធេសាន់ ។

**ស៖** លោកបណ្ឌិត អេតឆេសាន់ យើងបានឮព្រឹកមិញនេះនៅក្នុងពេល និងចំណុចមួយចំនួន គឺយើងឮអំពីលិខិតដែលបានបញ្ជូនពី ស៊្វ ម៉េត ទៅកាន់ ឌុច ។ ហើយយើងឮអត្ថបទដំណកស្រង់មួយចំនួននោះ ដែលបានពិភាក្សាដេញដោលដោយយ៉ាងពិស្តារ ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេក្នុងការយល់ឃើញជាអ្នកជំនាញ? តើអត្ថបទ ឬក៏លិខិតនេះ វាបានបង្ហាញទៅលើ បង្ហាញជាពន្លឺយ៉ាងម៉េចទៅលើរចនាសម្ព័ន្ធទំនាក់ទំនង និងគោលនយោបាយនៃការកម្ទេចនៅក្នុងជួរយោធា?

**ឆ៖** សូមអរគុណ លោកសហព្រះរាជអាជ្ញា គឺខ្ញុំអាចរៀបរាប់បាន ។ ការពិភាក្សាដេញដោយព្រឹកមិញនេះទាក់ទងទៅនឹងលិខិតចំនួនប្រាំបួន ដែលបញ្ជូនមកពី ស៊្វ ម៉េត ទៅជនជាប់ចោទ ហើយខ្ញុំសូមបន្ថែមទៅលើចំណុចនេះថា ជនជាប់ចោទគឺគាត់ឆ្លើយតបទៅនឹងលិខិតទាំងប្រាំបួននេះ គឺវាបានបង្ហាញឲ្យយើងឃើញទៅលើសំណួរទាំងឡាយ ដែលសហព្រះរាជអាជ្ញាលោកបានសួរ ។

ជាបឋម ទាក់ទងទៅនឹងការទំនាក់ទំនងរវាងប្រធានកងពល ទាក់ទងនៅរឿងក្តីនេះគឺ ស៊្វ ម៉េត នេះ ហើយនិងរវាងកងពល ស៊្វ ម៉េត និងលេខាស-២១ គឺវាតម្រូវឲ្យធ្វើតាមរយៈខ្សែបណ្តោយឡើងទៅលើ ហើយវាមិនតម្រូវឲ្យធ្វើការទំនាក់ទំនងផ្ទាល់រវាងបុគ្គលនិងបុគ្គលតាមខ្សែទទឹងនោះទេ ។ ហើយតាមការយល់របស់ខ្ញុំនោះ គឺវាបានបង្ហាញអំពីមជ្ឈិមបក្ស ធ្វើការគ្រប់គ្រងផ្តាច់មុខទៅលើការទំនាក់ទំនងនៅក្នុងជួរបក្សនៅក្នុងរបបនេះ ហើយក៏នៅក្នុងជួរយោធាផងដែរ ។

ទីពីរ គឺថាបេក្ខជនសមាជិកបម្រុង ដែលត្រូវសម្រិតសម្រាំងនោះ គឺត្រូវស្នើសុំសិទ្ធិអនុញ្ញាតពីថ្នាក់លើ ហើយក៏វាពាក់ព័ន្ធទៅនឹងបញ្ហាដែលយើងពិភាក្សាកាលពីអាទិត្យមុនផងដែរ ជាពិសេសនោះគឺឯកសារចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា “សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន” ។ ហើយប្រសិនបើខ្ញុំអាចធ្វើការរំឭកអង្គសវនាការ គឺមានលេខ ERN ឯកសារនេះជាភាសាអង់គ្លេសគឺលេខ 00182809 រហូតដល់លេខ 00182814 ។ ឯកសារនេះជាភាសាបារាំងដែលមានលេខ ERN00224363 ដល់លេខ 00224367 ។ លេខERN សម្រាប់ភាសាខ្មែរដែលជាឯកសារដើមនោះគឺមានលេខ ERN00003136 ដល់លេខ 00003142 ។

[១៣:៤១:០៣]

ផ្នែកទីមួយនៅក្នុងឯកសារនេះគឺ ទាក់ទងទៅនឹងសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ ។ នៅក្នុងនេះគឺមានការលើកឡើងថា តើសមាសធាតុណានៅក្នុងអង្គការ ដែលមានសិទ្ធិសម្រេចទៅលើការកម្ទេចនៅក្នុងជួរ សមាជិកក្នុងជួរនិងសមាជិកក្រៅជួរ ។ ការដកស្រង់ចេញពីសម្តីចេញពីឯកសារនេះគឺថា គឺ

កងទ័ពមជ្ឈិមត្រូវលេខាសេនាធិការធ្វើការសម្រេច ហើយការពិភាក្សាដេញដោលដែលយើងបានស្តាប់ព្រឹកមិញនេះគឺទាក់ទងទៅនឹងដំណើរការបញ្ជូនបុគ្គលិក ពីកងពល៥០២ ទៅស-២១ គឺវាស្របគ្នាទៅនឹងសេចក្តីសម្រេចដែលធ្វើឡើងដោយគណៈមជ្ឈិមមួយនេះ ។ ប៉ុន្តែ ឯកសារមួយនេះ ហើយខ្ញុំជឿថា ការពិភាក្សាព្រឹកមិញរបស់ជនជាប់ចោទលើឯកសារនេះ គឺក៏បានលើកឡើងអំពីប្រតិបត្តិការជ្រៅជាងនេះទាក់ទងទៅនឹងការសម្រេច ការកម្ទេច ដែលវាក្រៅពីការសុំការអនុញ្ញាតទាក់ទងទៅនឹងការកម្ទេចនៅក្នុងជួរ និងនៅក្រៅជួរ ។

នៅក្នុងការផ្តល់សក្ខីកម្មរបស់ខ្ញុំកាលពីអាទិត្យមុន ខ្ញុំបានធ្វើការលើកឡើងអំពីរបៀបដែលមជ្ឈិមឲ្យធ្វើការបញ្ជាក់ ហើយនិងមានការប្រុងប្រយ័ត្ននៅក្នុងការកំណត់រកខ្មាំង ។ ហើយបានជួយទៅដល់ថ្នាក់ផ្សេងៗឲ្យរក្សាជំហរដាច់ខាតក្នុងការបោសសំអាតខ្មាំងស៊ីរូងផ្ទៃក្នុង ហើយខ្ញុំពិភាក្សា ការពិភាក្សាព្រឹកមិញនេះបានបង្ហាញជាពន្លឺមួយសម្រាប់បញ្ហានេះ ។ ដូច្នេះ ដូចដែលវាបានបង្ហាញនៅទីនេះ លេខាកងពល ស៊ូ ម៉េត គឺគាត់រកសត្រូវនៅក្នុងអង្គភាពរបស់ខ្លួន ហើយវាក៏បានបង្ហាញថាលេខាស-២១ តាមរយៈដំណើរការពិនិត្យ និងវិភាគទៅលើចម្លើយសារភាពលេខាស-២១ នឹងរៀបចំបញ្ជីអ្នកទោសដែលបានស្នើឡើង ។ ហើយក្រោយមកបញ្ជូនទៅថ្នាក់លើដើម្បីសុំការអនុញ្ញាត ដើម្បីធ្វើការសុំការអនុញ្ញាតធ្វើការចាប់ខ្លួន សួរចម្លើយ និងកម្ទេចចោល ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណ លោកបណ្ឌិត ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ គឺយើងខ្ញុំខាងសហព្រះរាជអាជ្ញាសូមបញ្ចប់ការតាំងសំណួរត្រឹមនេះ ។ សូមអរគុណ ។

[១៣:៤៤:២៧]

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ ជូនវេទិកានេះទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ដែលមានការពាក់ព័ន្ធនឹងសំណួរជាមួយនឹងអ្នកជំនាញរូបនេះដែរទេ? បើមានសូមអញ្ជើញ, លោក ហុង គឹមសួន។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធាន សូមគោរពលោកស្រី លោកចៅក្រមអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ជាទីគោរព! ខ្ញុំបាទមានសំណួរទាក់ទងទៅនឹងលោកជំនាញ ក្រេក អេតឆេសាន់ ទាក់ទងជាមួយនឹងកំណត់ត្រារបស់លោក។ ទីមួយជាភាសាខ្មែរដែលខ្ញុំបាទមាន នៅក្នុងលេខERN00314781

ឬឯកសារ D2-15 ជាភាសាខ្មែរដែរ ។ ទាក់ទងនឹងបញ្ហាបុគ្គលិក និងបញ្ហានៃការចាត់តាំង ដែលឯកសាររបស់លោកមានតាំងដោយអក្សរ “ក” សម្គាល់មន្ទីរ ឬអង្គការ ។ កន្លែងនេះវាជាចម្ងល់របស់ខ្ញុំបាទ វាឃើញ ក១, ក៣ តែវាបាត់ ក២ តើនេះជាកំហុសនីតិវិធី កំហុសបច្ចេកទេស ឬក៏ជាភាពច្បាស់លាស់ដែលឥតមាន ក២ ហើយតើវាមានន័យយ៉ាងម៉េច? ទីមួយសូមសួរអ៊ីចឹងសិន ។

**ឆ៖** សូមអរគុណលោកមេធាវី ខ្ញុំអាចរៀបរាប់បាន ។ មូលហេតុដែលខ្ញុំមិនបានកំណត់ពិស្តារទៅលើបញ្ហានេះ គឺការចាត់តាំង ឬការកំណត់លេខ ក២ នេះគឺសំដៅទៅលើក្រសួងកិច្ចការសង្គមរបស់ អៀង ធីរិទ្ធ គឺក្រសួងសង្គមកិច្ចនេះ គឺវាទាក់ទងទៅនឹងនៅក្នុងជួរ ស-៧១ នៃអង្គការនេះ ដែលយើងបានកំណត់អក្សរ “ក” នៅទីនេះ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ក២ ដែលយើងបានដឹងថា ដែលយើងបានដឹងនេះ គឺជាក្រសួងសង្គមកិច្ចរបស់ អៀង ធីរិទ្ធ ។

**ស៖** សូមអរគុណ ។ អម្បាញ់មិញលោកបានជម្រាបលោកប្រធាននិងអង្គសវនាការរួចហើយ ទាក់ទងអំពីការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទាក់ទងនឹងផ្នែកយោធា ខ្ញុំសូមសួរលោកដោយសារ នេះក៏ទាក់ទងនៅក្នុងឯកសារដែលមានទាក់ទងគ្នាដែរ ដើម្បីកុំឲ្យមានការភ័ន្តច្រឡំខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន តើឯកសារលេខ000 ERN ជាភាសាខ្មែរ ស្តីពីកងទ័ពបដិវត្តន៍កម្ពុជា ស្ថិតិកម្លាំងរួម ។ ក្រែងខ្ញុំមិនច្បាស់លាស់ តើឯកសារនេះស្ថិតនៅក្នុងឯកសារនៃរបាយការណ៍របស់លោក ក្រេក អេតធេសាន់ ដែរឬទេ? គឺលេខ ERN00052319 មានតែមួយទំព័រទេ ។

**ឆ៖** សូមអភ័យទោសលោកមេធាវី តើលោកអាចផ្តល់លេខ ERN ឲ្យខ្ញុំសាជាថ្មីបានដែរឬទេ?

**ស៖** ខ្ញុំមានតែឯកសារជាភាសាខ្មែរ ដែលមានលេខ ERN00052319 ទាក់ទងនឹងស្ថិតិកម្លាំងរួមកងទ័ពបដិវត្តន៍កម្ពុជា សេនាធិការ ប្រចាំខែ៣-៧៧ ។

[១៣:៥០:០៥]

**ឆ៖** សូមអរគុណ លោកមេធាវី ។ លេខ ERN ជាភាសាអង់គ្លេសសម្រាប់ឯកសារនោះគឺ 00183956 រហូតដល់លេខ 00183956 ។ ហើយតាមពិតឯកសារនេះ ដែលមានតែមួយទំព័រតែមួយប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ត្រឹមត្រូវហើយ ភាសាខ្មែរក៏មួយទំព័រដែរ ។ ក្នុងឯកសារនេះ ខ្ញុំចង់សួរការស្រាវជ្រាវ ឬការបង្ហាញរបស់លោក ក្នុងឯកសារនេះនិយាយពីអង្គភាពដែលជាចំណុះឲ្យសេនាធិការផ្នែកយោធា ទាំងពីលេខរៀងទី១ ដល់ ១៥ នេះ ឬក៏ជាគ្រាន់តែការបង្ហាញអំពីចំនួនអង្គភាពផ្សេងៗ

ដែលទាក់ទងនឹងយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ, លោកមេធាវី ។ ទៅតាមការយល់ដឹងរបស់ខ្ញុំលើបញ្ហានេះ គឺឯកសារនេះ រៀបរាប់អំពីការបែងចែករបស់យោធា របស់កងទ័ពបដិវត្តន៍កម្ពុជា ដែលត្រូវបានចាត់ទុកជាកងពលមជ្ឈិម គឺស្ថិតនៅក្រោមការបញ្ជាផ្ទាល់របស់សេនាធិការ ។ ហើយឯកសារនេះ ក៏មានរាប់អំពីកងពលផ្សេងៗ ដែលស្ថិតនៅខាងក្រោមបង្គាប់នោះដែរ ដែលនៅក្នុងចំណោមនោះគឺមន្ទីរស-២១ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង បើខ្ញុំស្តាប់មិនច្រឡំទេ អំមិញលោកមានប្រសាសន៍ថា មន្ទីរទាំងអស់នេះ ស្ថិតនៅក្រោមអគ្គសេនាធិការកងទ័ព ប៉ុន្តែទាក់ទងនឹងស-២១ នេះ នៅក្នុងចំណុចលេខ១៣ តើមន្ទីរ ឬក៏អង្គភាព ឬក៏កងពលចាប់ពីលេខ១ មកដល់លេខ១៥ ដោយដកចេញលេខ១៣ ដែលនិយាយអំពីមន្ទីរស-២១ តើអង្គភាពទាំងអស់នោះ គេមានអំណាចគ្រប់គ្រាន់ ដូចលោកលើកឡើងទាក់ទងជាមួយនឹងសេចក្តីសម្រេច នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ថាតើគេមានសិទ្ធិសម្រេចស្រាវជ្រាវ ឬក៏កំណត់មុខសញ្ញាខ្មាំង និងអនុវត្តផ្ទាល់ដោយខ្លួនគេដែរឬទេ?

**ឆ៖** សូមអរគុណលោកមេធាវី ។ ទៅតាមការយល់ដឹងរបស់ខ្ញុំ កងពលនានានិងកងវរសេនាធំឯករាជ្យ ដែលមានចុះនៅ ដែលមានឈ្មោះនៅក្នុងបញ្ជីនេះ គឺមានអំណាចប្រហាក់ប្រហែលគ្នាទៅនឹងអំណាច ដែលកងពល៥០២មាន ដែលខ្ញុំទើបតែបានពិភាក្សានៅក្នុងបរិបទនៃសំណួរ ដែលខាងសហព្រះរាជអាជ្ញាបានសួរខ្ញុំអម្បាញ់មិញនេះ ដែលមានន័យថា កងពលអស់ទាំងនេះ ហើយនិងកងវរសេនាធំឯករាជ្យអស់ទាំងនេះ គឺមានអំណាចដែលអាចមានកម្រិតក្នុងការដាក់វិន័យនៅក្នុងជួររបស់ខ្លួន ។ ហើយពួកគេក៏មានអំណាចក្នុងការកំណត់ខ្មាំងនៅក្នុងជួររបស់ខ្លួន ព្រមទាំងរាយការណ៍អំពីខ្មាំង អស់ទាំងហ្នឹងទៅថ្នាក់លើ ។ ប្រសិនបើមានហេតុផលដែលនាំឲ្យជឿថា គឺវាអាចប៉ះពាល់ដល់ផលប្រយោជន៍របស់មជ្ឈិមបក្ស ។

[១៣:៥៥:១៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

មានបញ្ហាបន្តិចបន្តួចនៅក្នុងការបកប្រែ យើងបានឮថាកងពល៥០២ ប៉ុន្តែ តាមពិតគឺយើងនិយាយអំពីកងពល៥០២ ទេបាទ ។ អ៊ីចឹង គឺកងពល៥០២ មែនទេ? បាទ ដូច្នេះ នៅក្នុងការបកប្រែជាភាសាបារាំង ក្នុងប្រតិចារឹកហ្នឹង គឺត្រូវកែពីកងពល៥៥២ មកកងពល៥០២ វិញ ។ ដូច្នេះ សូមចាំថា យើងនិយាយអំពីកងពល៥០២ មិនមែនកងពល៥២ទេ ។ សូមអរគុណ ។

**លោក ហុង គីមសួន៖**

សូមអនុញ្ញាត សួរលោកបន្តទៅទៀត ។ នៅក្នុងឯកសារស្រាវជ្រាវ និងការគូសជាគំនូសបង្ហាញរចនាសម្ព័ន្ធ នៅក្នុងទំព័រលេខ៥៧ ជាភាសាខ្មែរ ដែលមានលេខ ERN00314834 ក្នុងឯកសារ D2-15 ។ លោកបានគូសជាគំនូសរចនាសម្ព័ន្ធ ក្រសួងនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ សូមឲ្យលោកបញ្ជាក់ថា លោកប្រធាន សូមអនុញ្ញាត ដោយសារគំនូសនេះមានតែលើឯកសារនៃយើងទាំងអស់គ្នា ។ តើអនុញ្ញាតឲ្យបញ្ចាំងជារូបភាពដើម្បីឲ្យលោក គ្រេក អេតឆេសាន់ គាត់ងាយនឹងបង្ហាញប្រៀបធៀប ក្នុងប្រឡោះមួយៗបានឬទេបាទ?

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេស សូមភ្ជាប់ទៅប្រព័ន្ធជាមួយនឹងអ្នកជំនាញកុំព្យូទ័ររបស់អ្នកជំនាញ ដើម្បីបង្ហាញបញ្ចាំងនូវរចនាសម្ព័ន្ធ ដែលលោកមេធាវីបានស្នើសុំអម្បាញ់មិញនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន បើសិនជាខ្ញុំអាចជួយបាន គឺថាយើងមានឯកសារហ្នឹង នៅលើអេក្រង់កុំព្យូទ័ររបស់ខ្ញុំ ហើយអាចភ្ជាប់បានលឿន គឺទាក់ទងទៅលើទំព័រ ដែលលោក ហុង គីមសួន ដែលចង់លើកឡើងបញ្ចាំងលើអេក្រង់នោះ ប្រសិនបើលោកប្រធានអាចឲ្យខាងផ្នែកសោតទស្សន៍ភ្ជាប់កុំព្យូទ័រខាងសហព្រះរាជអាជ្ញាវិញ ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទបានឃើញហើយ ។ ហើយខ្ញុំបាទសុំអនុញ្ញាតសួរបន្តទៅទៀត ។

អម្បាញ់មិញខ្ញុំបានសួរលោក អេតឆេសាន់ ទាក់ទងនឹងស្ថិតិកម្លាំងរួចដែលលោកមានប្រសាសន៍អំមិញថា កងពល ឬអង្គភាពទាំងអស់ហ្នឹង មានអំណាចប្រហាក់ប្រហែលគ្នា នេះខាងផ្នែកកងទ័ព ។ អ៊ីចឹងទាក់ទងនឹងក្រសួងនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដូចកំពុងបញ្ចាំងបង្ហាញនេះ នៅក្នុងគំនូសបង្ហាញរបស់លោកមន្ទីរស-២១ ដែលមានដាក់ឈ្មោះ ឌុច ពីលើ យើងមើលទៅលើអេក្រង់នេះមាននូវរូបខាងស្តាំដៃទល់មុខយើង បែរទៅស្តាំដៃក្រោមគេបង្អស់ ជាខ្សែបន្ទាត់ចេញពី ជួន ជឿន (ស្លាប់ ២០០៦) សុខភាព ។ ហើយបន្ត (សុំទោស) នៅក្នុងគំនូសនេះ ខុសពីលើឯករាជ្យនេះលោកប្រធាន ។ នៅក្នុងអេក្រង់នេះខុស គំនូសដែលគូសបង្ហាញ អ៊ីចឹង ខ្ញុំបាទឆ្ងល់នេះ ឆ្ងល់ថាតើការគូសនៅក្នុងក្រដាស និងក្នុងអេក្រង់មួយណាជាផ្លូវការសិន? ជាភាសាអង់គ្លេស និងភាសាខ្មែរ គូសខុសគ្នា តើយកមួយណា

ជាលទ្ធផល លោកប្រធានបាទ?

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី, សូមយកឯកសារជាភាសាខ្មែរនេះទៅជូនលោក ក្រេក អេតធេសាន់ ដើម្បីពិនិត្យផ្ទៀតផ្ទាត់មើលអំពីគំនូសរចនាសម្ព័ន្ធហ្នឹង ត្រង់ចំណុចពី ដួន ជឿន ចុះមកក្រោមហ្នឹង ហើយមានការគូសហ្នឹងខុសគ្នា គឺមួយពី សុន សេន ចុះមកក្រោម ហើយចំណែកឯ ខ្មែរ គឺមាន សុខ សេន ឆ្លងតាមរយៈ ដួន ជឿន ហើយមានតែពី ដួន ជឿន ទមកចុះមកអគ្គសេនាធិការចុះមក ឌុច ស-២១ ។

ក្រឡាបញ្ជីយកឯកសារនេះទៅបង្ហាញគាត់ ហើយធៀបជាមួយនឹងឯកសារ ដែលសួរគាត់មើលថាតើគំនូសនេះមួយណាដែលត្រឹមត្រូវ?

**លោក ក្រេក អេតធេសាន់៖**

លោកប្រធាន ប្រសិនបើខ្ញុំអាចនិយាយ ខ្ញុំមិនបានឃើញឯកសារបកប្រែជាភាសាខ្មែរនេះ ពីមុនមកទេ ។ ឥឡូវនេះ ទើបតែឃើញ ហើយខ្ញុំឃើញថា មានកំហុសមួយ ហើយយើងត្រូវចាត់ទុកឯកសារជាភាសាអង់គ្លេសហ្នឹង គឺជាឯកសារគោល ពីព្រោះហ្នឹងឯកសារហ្នឹងត្រូវបានធ្វើឡើង ជាភាសាអង់គ្លេស ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងយើងសម្រេចយកឯកសារជាភាសាអង់គ្លេស ជាឯកសារមូលដ្ឋាននៃការពិភាក្សានេះ ពីព្រោះ ឯកសារជាភាសាអង់គ្លេសនេះ ជាឯកសារដើមនៃសំណេរដែលរៀបចំឡើងដោយអ្នកជំនាញនៅក្នុងការបង្ហាញនេះ ។ ហើយចំណែកឯ ភាសាខ្មែរនេះជាការបកប្រែពីភាសាអង់គ្លេសទេ ។

[១៤:០៣:០៤]

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមអរគុណ លោកប្រធាន ។ អ៊ីចឹង ខ្ញុំបាទសូមអនុញ្ញាតសួរបន្តទៅទៀត ។

ទាក់ទងជាមួយនឹងក្រសួងរបស់រដ្ឋាភិបាល ជាមួយនឹងរចនាសម្ព័ន្ធដែលគូស ស្តីអំពីការគ្រប់គ្រងនៅក្នុងជួរបក្សវិញ ។ គំនូសបង្ហាញរបស់លោកនៅក្នុងក្រសួងនានា របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាមួយនឹងរចនាសម្ព័ន្ធរបស់បក្ស ។ ខ្ញុំចង់សួរថា តើនៅក្នុងជួររដ្ឋាភិបាលអំណាចរបស់បក្សដើរតួលើអំណាចរបស់រដ្ឋាភិបាលដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយលោកមេធាវី ។ នៅក្នុងគ្រប់ករណីទាំងអស់អំណាចរបស់បក្ស គឺមានឥទ្ធិពលឥតគណនា ។

**ស៖** បាទ សូមអរគុណ ។ សំណួរបន្តទៅទៀត នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា តាមការយល់ឃើញ និងការសិក្សារបស់លោកចាប់ពីថ្នាក់គណៈអចិន្ត្រៃយ៍បក្ស ឬមជ្ឈិមបក្ស ឬយើងហៅថា ថ្នាក់ខ្ពស់បំផុត និងមកដល់បក្ខជនពេញសិទ្ធិនៃបក្សកុម្មុយនីស្តកម្ពុជា តើអំណាចដែលមានឥទ្ធិពលច្រើនដែលមានសិទ្ធិសម្រេច និងសិទ្ធិអនុវត្តគោលនយោបាយបក្ស ចាប់ត្រឹមកម្រិតកំពូលចុះមកក្រោម ត្រឹមណាដែលមានអំណាចច្រើន? គឺថាចង់មានអំណាចច្រើនដែល អនុវត្តគោលការណ៍សិទ្ធិសម្រេចរបស់សេចក្តីសម្រេចមជ្ឈិមបក្ស ។ ខ្ញុំសួរឡើងវិញក្រែងលោច្រឡំ ។ នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាពីថ្នាក់កំពូលមកថ្នាក់ក្រោម តើកម្រិតណាមួយ ពីកំពូលមកដល់ក្រោម ដែលមានអំណាចអនុវត្តគោលការណ៍ដាច់ខាតសិទ្ធិសម្រេចទៅតាមសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦? មានន័យថា សម្រេចកម្ទេចសម្រេចចោទ សម្រេចចាប់ សម្លាប់ ។

**ឆ៖** បាទ, ត្រឹមត្រូវហើយលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ, សម្រាប់គោលបំណងក្នុងការបកប្រែ គឺយើងនិយាយអំពីសេចក្តីសម្រេចដែលចុះថ្ងៃទី៣០ ខែ៣ ឆ្នាំ១៩៧៦ មិនមែនខែឧសភានោះទេ ។

[១៤:០៦:៤៤]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ខ្ញុំបាទដូចជានិយាយពីខែមីនា ៣០ មីនា ១៩៧៦ ។ បើសិនខ្ញុំបាទច្រឡំសូមកែមកវិញថា គឺ ៣០ មីនា ១៩៧៦ ហ្នឹងឯងបាទ ខុសខាងអ្នកបកប្រែខ្ញុំអត់ដឹងដែរ ។

**ឆ៖** បាទ សូមអរគុណ។ ពិតមែនហើយជាទូទៅ គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា គឺជាអ្នកដែលមានអំណាចខ្ពង់ខ្ពស់ជាងគេនៅក្នុងជួរបក្សកម្ពុជា ។ ក៏ប៉ុន្តែ ជាទ្រឹស្តី គឺមានតែជាទ្រឹស្តីតែប៉ុណ្ណោះ មិនមែននៅក្នុងការអនុវត្តនោះទេ ។ ពីព្រោះថា អំណាចពិតប្រាកដ និងអ្នកដែលមានអំណាចពិតប្រាកដនោះ អ្នកដែលមានអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺមាននៅជាមួយនឹងគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ គណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម ។ នោះគឺជាហេតុផលមួយដែលនាំឲ្យខ្ញុំជឿថា ឯកសារនេះ ដែលមានចំណងជើងថា “សេចក្តីសម្រេចរបស់គណៈមជ្ឈិម”ទាក់ទងទៅលើបញ្ហាមួយ

ចំនួន តាមពិតនោះ គឺចេញមកពីគណៈអចិន្ត្រៃយ៍ឯវិញនោះទេ ។ ទោះបីជាឯកសារនេះនៅត្រង់ចំណុចណាមួយនោះត្រូវបានបញ្ជាក់ដោយកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ។ នៅក្នុងឯកសារនេះ អំណាចឬក៏សិទ្ធិក្នុងការកម្ទេចនោះ គឺផ្តល់ទៅឲ្យស្ថាប័នមួយចំនួនរបស់បក្ស ។

ដំបូងឯកសារបញ្ជាក់ថា នៅក្នុងគ្រោងមូលដ្ឋាន សេចក្តីសម្រេចដើម្បីកម្ទេចនុ៎ង គឺអាស្រ័យទៅលើគណៈអចិន្ត្រៃយ៍ភូមិភាគ។ មានន័យថា គណៈភូមិភាគ និងលេខាបក្សភូមិភាគជាពិសេសនោះ គឺមានអំណាចឯករាជ្យក្នុងការសម្លាប់ ។

ទីពីរ ឯកសារនេះ បានបញ្ជាក់ថា នៅជុំវិញមន្ទីរមជ្ឈិមសេចក្តីសម្រេចក្នុងការកម្ទេច គឺត្រូវកំណត់ដោយគណៈកម្មាធិការមន្ទីរមជ្ឈិម ។ ហើយទៅតាមឃ្លានេះ គឺថាគណៈមន្ទីរមជ្ឈិមនោះ គឺសំដៅទៅលើមន្ទីរ៨៧០ ។

ទីបី ហើយប្រសិនបើលោកមេធាវីនៅចាំ នៅពេលដែលខ្ញុំបានពិភាក្សាអំពីរចនាសម្ព័ន្ធរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះ បន្ថែមពីលើភូមិភាគទាំងប្រាំមួយ ដែលកម្ពុជាប្រជាធិបតេយ្យត្រូវធ្វើការបានបែងចែកនោះ ក៏នៅមានតំបន់ឯករាជ្យមួយចំនួនទៀតដូចជា ១០៣, ១០៦, ៥០៥ ។ល។ បើយើងយោងតាមឯកសារនេះ នៅក្នុងតំបន់ឯករាជ្យការកម្ទេចត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍ ហើយនៅទីបញ្ចប់ដូចដែលខ្ញុំបានកត់សម្គាល់មុននេះបន្តិចនៅក្នុងតំបន់របស់យោធា គឺត្រូវសម្រេចដោយអគ្គ-សេនាធិការ ដល់សេនាធិការ តើអ្វីដែលខ្ញុំឆ្លើយហ្នឹងវាស៊ីគ្នាទៅនឹងអ្វីដែលលោកចង់បាននោះទេ លោកមេធាវី?

**ស៖** សូមអរគុណលោក ខ្ញុំបាទយល់ហើយ ។ អ៊ីចឹងខ្ញុំសុំសួរលោកទៅទៀត ។ នេះយោងអ្វីដែលខ្ញុំបានសួរ គឺទាក់ទងជាមួយនឹងអំណាចនៃបក្សកុម្មុយនីស្តកម្ពុជាដែលមានថ្នាក់ដឹកនាំបន្តបន្ទាប់ ។ អ៊ីចឹងសំណួរខ្ញុំសួរដោយសារខ្ញុំសុំឲ្យបញ្ជាំងរូបភាពនេះ តើរូបគំនូរបង្ហាញនៃរចនាសម្ព័ន្ធរដ្ឋាភិបាលនេះក្នុងន័យអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា តើក្រសួងនានាមានសិទ្ធិអនុវត្តសេចក្តីសម្រេចរបៀប និងគណបក្សកុម្មុយនីស្តកម្ពុជា ឬមជ្ឈិមបក្សដែរឬទេ?

**ឆ៖** សូមអរគុណលោកមេធាវី ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺមិនត្រូវបានរៀបចំឡើងឬក៏ប្រតិបត្តិការនៅក្នុងជួរ ឬក៏ខ្សែតាមលក្ខណៈរបស់គេនោះទេ ។ ជាការពិតនៅក្នុងករណីមួយចំនួនអ្វីដែលយើងហៅថា ក្រសួងនោះ គឺក្រសួងមិនបានដំណើរការជាក្រសួងចំតែម្តងនោះទេ។ ប៉ុន្តែ ក្រសួងទាំងអស់នោះជាជំរំទៅវិញទេសម្រាប់គណៈមជ្ឈិម ដែលបានផ្តល់អំណាចធ្វើការគ្រប់គ្រងទៅលើគ្រប់

ផ្នែក គ្រប់វិស័យទាំងអស់ ។ ហើយដោយសារតែបញ្ហានេះនៅក្នុងក្រសួងនីមួយៗ យើងមិនអាចធ្វើការមិនអាចឃើញស្វែងយល់អំពីរចនាសម្ព័ន្ធ ស្ថាប័នក្រសួងដែលបានបង្ហាញអំពីដំណើរការប្រតិបត្តិការរបស់ក្រសួងទាំងអស់នោះទេ ឬក៏យើងមិនអាចរកឃើញលក្ខណៈ នៃលក្ខណៈរៀបចំនៃក្រសួងទាំងអស់នោះដូចរដ្ឋនាពេលបច្ចុប្បន្ននេះទេ ។

[១៤:១៣:២៩]

ផ្ទុយមកវិញ អំណាចទាំងអស់នោះគឺមាននៅលើបុគ្គលនីមួយៗ ដែលនៅក្នុងបក្ស ហើយដែលបុគ្គលទាំងអស់នោះ គឺទទួលខុសត្រូវលើគោលនយោបាយ ឬក៏ផ្នែករបស់ខ្លួន។ តារាងដែលលោកមេធាវីបានចង្អុលបញ្ជាក់នេះ គឺយើងអាចបង្ហាញ យើងអាចយល់ថា វាជាការបង្ហាញមួយជាលក្ខណៈដ៏ល្អ ដែលថាបុគ្គលនីមួយៗ គាត់មានអំណាចនៅក្នុងផ្នែករបស់ខ្លួន និងលើគោលនយោបាយរបស់ខ្លួន ។ ហើយយើងមិនគួរយល់ច្រឡំទៅលើបញ្ហានេះទេ ថាវាចំណុចនេះ គឺវាមិនមានរដ្ឋាភិបាលដែលមានលក្ខណៈធ្វើការតាមការិយាល័យធិបតេយ្យនោះទេ ។ ដូច្នេះ គឺអំណាចដែលវាមិនមាននៅក្នុងក្រសួងនោះ គឺអំណាចទាំងអស់នោះតាមពិតទៅគឺវាស្ថិតកាន់កាប់ដោយបុគ្គលនីមួយៗ នៅក្នុងបក្សដែលទទួលខុសត្រូវក្នុងការអនុវត្តនៅក្នុងទិដ្ឋភាព ឬក៏វិស័យផ្សេងៗ ដោយស្របទៅតាមមាគ៌ារបស់បក្ស ។

**ស៖** សូមអរគុណ ។ សំណួរមួយទៀតទាក់ទងនឹងគំនូសបង្ហាញនេះដែរ គូសចេញពីចំណុចរង្វង់ខាងលើថា ប៉ុល ពត នាយករដ្ឋមន្ត្រី បើយើងមើលចុះឱ្យត្រង់មកក្រោម ក្នុងប្រអប់ទីពីរ អៀង សារី ឧបនាយករដ្ឋមន្ត្រីការបរទេស ហើយចុះមកក្រោមទៀត ដាក់ B-32 បឹងត្របែក ។ តើជាក្រសួងមួយឬក៏ជាអ្វី? សូមលោកបង្ហាញបន្តិចបាទ?

**ឆ៖** បាទ,លោកមេធាវី គឺពិតជាដូច្នោះ ។ B-32 គឺជាផ្នែកមួយនៅក្នុងក្រុមនៃអង្គការចាត់តាំងនេះ ដែលវាមានទីតាំងនៅពេលបច្ចុប្បន្ននេះ គឺវាជាទីតាំងបឹងត្របែកនៅពេលបច្ចុប្បន្ននេះ ទីតាំងរបស់វាគឺស្ថិតនៅសាលាបឹងត្របែកនាពេលបច្ចុប្បន្ន ។ B-32 គឺមានភារកិច្ចទទួលអ្នកការទូត និស្សិត បញ្ញវន្តនិងបុគ្គលផ្សេងទៀតដែលត្រឡប់មកពីបរទេស ។ វាគឺជាជំរំកសាងខ្លួន លុតដំខ្លួនរបស់បក្ស ដែលបក្សនោះ គឺមានការព្យាយាមធ្វើការពិនិត្យទៅលើបុគ្គលទាំងឡាយដែលត្រឡប់មកពីបរទេស ហើយត្រូវបានគេរក្សានៅទីនោះ ។ ហើយថាតើអ្នកណាខ្លះគួរតែធ្វើការសម្លាប់ចោល?

ពីដំបូងជំរំនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស ។ ហើយនៅពេលមួយនោះនៅក្នុងរបបនេះអំណាចនៅក្នុងស្ថាប័ននេះ គឺត្រូវបានផ្ទេរទៅឱ្យលោក អៀង សារី ដែលជាឧបនាយករដ្ឋ

មន្ត្រីការបរទេស ។

**ស៖** សូមអរគុណ ។ នៅក្នុងរង្វង់នៃប្រអប់ទាំងអស់តាមការគូរបង្ហាញរបស់ ដូចដែលខ្ញុំបានឃើញរបស់លោកនេះ សុទ្ធតែមានឈ្មោះហាក់ដូចជាប្រធាន ឬក៏រដ្ឋមន្ត្រីប្រចាំប្រអប់នីមួយៗ ។ អ៊ីចឹងអ្វីដែលខ្ញុំសួរអម្បាញ់មិញចង់ដឹងថា តើប្រអប់និយាយអំពី B-32 បឹងត្របែកនេះជាក្រសួង ឬក៏ជាមន្ទីរសំណួររបស់ខ្ញុំហ្នឹង ដោយសារខ្ញុំចង់ដឹងថា តើក្នុងនោះមានប្រធានឈ្មោះអីដែរឬទេ? ព្រោះនៅ ខាងស-២១ ដាក់មន្ទីរ ស-២១ មានឈ្មោះ ឌុច តើនៅក្នុង B-32 បឹងត្របែកមិនទាន់មានដាក់ឈ្មោះ ប្រធានទេ តែលោកបានជម្រាបអង្គសវនាការមិញថា ក្រោមការត្រួតត្រា ឬក៏ដឹកនាំដោយ អៀង សារី ។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេ?

[១៤:១៨:២៣]

**ឆ៖** សូមអរគុណលោកមេធាវី។ គឺខ្ញុំអាចធ្វើការបំភ្លឺទៅលើបញ្ហានេះបាន ។ B-32 មិនមែនជាក្រសួងនោះទេ ដូច្នេះ B-32 នេះគឺមិនមានមេប្រធានដែលត្រូវបានតែងតាំងដោយបក្សដូចដែលយើងបានឃើញក្រសួងពាណិជ្ជកម្មនោះទេ ។ ហើយពីដំបូងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ B-32 គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុគ្គលម្នាក់ដែលយើងបានពិភាក្សាមុននឹង គឺ ផេង គឺ ប៉ង់ គឺគាត់នៅក្នុងមន្ទីរ កគឺក១ ។ ហើយ ប៉ង់ នេះគឺគ្រប់គ្រង B-32 ហើយនិងទីតាំងដែលនៅជាប់នឹងកន្លែងនេះដែលជាជំរំលត់ដំខ្លួនទៅលើបុគ្គលផ្សេងៗ ។ ហើយនៅពេលជាមួយគ្នានោះដែរ បុគ្គលទាំងអស់នោះដែលត្រូវបានគេឃុំនៅក្នុងជំរំលត់ដំខ្លួននេះ គឺទាមទារឲ្យ គឺឲ្យគេបានបង្កើតជាក្រុមអ្នកជាប់ឃុំនៅទីនោះ ដើម្បីធ្វើការចាត់ទៅលើការងាររបស់ពួកគេរៀងៗខ្លួន ។ ការធ្វើដូច្នោះ ដើម្បីទទួលបាននូវភារកិច្ចរបស់គេហើយអ្នកទោសនៅទីនោះគឺត្រូវបានគេតែងតាំងឡើង ហើយប្រធានមួយចំនួននៅក្នុង B-32 នេះ គឺត្រូវបានគេសម្លាប់ចោលនៅស-២១ ។

[១៤:២០:៤១]

**ស៖** សូមអរគុណ ។ ជាសំណួរចុងក្រោយ ខ្ញុំសូមសួរលោកថា នៅក្នុងការបញ្ជូនមនុស្ស ឬក៏ដែលក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាត់ទុកថា ជាខ្មាំងនោះ នេះខ្ញុំមិនមានឯកសារចាំលេខទេ តែខ្ញុំបានអានជូនហើយ ខ្ញុំមិនពិបាករកបន្តិច ។ ចង់សួរលោកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានស្រាវជ្រាវដឹងដែរទេ ទាក់ទងនឹងការបញ្ជូនមនុស្សឆ្លងប្រទេស? ដូចជាមកពីវៀតណាម មកពីថៃមុននឹងចូលមកដល់មន្ទីរស-២១ នេះ ។

**ឆ៖** បាទ,គឺមានលោកមេធាវី ។ ខ្ញុំមិនមានចំនួនស្ថិតិច្បាស់លាស់នោះទេ ប៉ុន្តែ និយាយតាមអ្វីដែលខ្ញុំអាចបញ្ជាក់បាន គឺតាមខ្ញុំចាំតាមចុងៗមាត់របស់ខ្ញុំ គឺអ្នកមួយចំនួនត្រូវបានគេសម្លាប់នៅស-២១ ហើយនៅក្នុងនោះគឺមានអ្នកដែលមកពីបស្ចិមប្រទេសដូចជា ខាងសហរដ្ឋអាមេរិក ខាងអូស្ត្រាលី ប្រទេសញូវហ្សេឡែន ដែលអ្នកទាំងនោះ គឺក្លាយជាជនរងគ្រោះនៅស-២១ ហើយយើងឃើញមានអ្នកមិនមកបស្ចិមប្រទេសមួយទៀតដែលរួមមាន វៀតណាម ថៃ ហើយនិងមកពីទីកន្លែងផ្សេងៗទៀតត្រូវបានគេសម្លាប់ចោលនៅមន្ទីរស-២១ ។ នៅក្នុងឆ្នាំ១៩៧៥ ដែលខ្មែរក្រហមទទួលបានជ័យជម្នះ ហើយក្តោបក្តាប់យកប្រទេសនេះ នៅពេលនោះយើងឃើញមានអ្នកធ្វើការងារតាមកុងត្រា ដែលធ្វើឡើងតាមលក្ខណៈកុងត្រានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ហើយដែលគាត់ធ្វើការនៅក្នុងរបប លន់ នល់ អ្នកទាំងនោះ ក៏ត្រូវបានជាប់ឃុំនៅស-២១ ផងដែរ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ សូមអនុញ្ញាតបង្វែររូបភាពទៅភាពដើមវិញដែរ ។ ហើយខ្ញុំបាទក៏អស់សំណួរនៅពេលនេះដែរ សូមបញ្ចប់ត្រឹមនេះ ។

[១៤:២៣:៤៤]

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍បង្វែររូបភាពទៅស្ថានភាពធម្មតាវិញ ។ ជាបន្តសូមអញ្ជើញមេធាវីក្រុមបី ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី តើមានសំណួរអ្វីពាក់ព័ន្ធ នឹងត្រូវសួរដល់ទៅអ្នកជំនាញរូបនេះដែរឬទេ?

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

លោកប្រធាន!សហសេវិករបស់ខ្ញុំនឹងធ្វើការតាំងសំណួរ តាងនាមឲ្យក្រុមទីបីរបស់យើងខ្ញុំនេះ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** សូមគោរពលោកប្រធាន! ខ្ញុំមានសំណួរមួយសួរទៅលោកបណ្ឌិតទាក់ទងទៅនឹងមន្ទីរស-២១ ក្នុងការអនុវត្តមាគ៌ានយោបាយរបស់បក្ស ។ នៅក្នុងរបាយការណ៍របស់លោកបានសរសេររៀបរាប់ថា មានការបញ្ជូនមន្ត្រីពីបណ្តាលក្រសួងនានា របស់កម្ពុជាប្រជាធិបតេយ្យដើម្បីយកទៅកម្ទេចចោលនៅមន្ទីរស-២១ ។ តាមទស្សនៈរបស់លោក តើមន្ទីរស-២១ ត្រូវបានចាត់ទុកថាជាមន្ទីរសន្តិបាល

តែមួយគត់ដែលមានសិទ្ធិកម្ទេចមន្ត្រីក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមែនដែរឬទេ?

**ឆ៖** សូមអរគុណលោកមេធាវី ។ តាមការយល់ឃើញផ្ទាល់របស់ខ្ញុំ ស-២១ មានលក្ខណៈពិសេសនៅក្នុងចំណោមមន្ទីរសន្តិសុខផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ហើយខ្ញុំជឿថា នេះករណីនេះ គឺពិតមែន ។

ទីមួយ ស-២១ គឺជាមន្ទីរសន្តិសុខ ដែលត្រូវបានប្រគល់ភារកិច្ចឱ្យកម្ទេចបុគ្គលផ្សេងៗពីមជ្ឈិមបក្សនៃកម្ពុជាប្រជាធិបតេយ្យនិងបក្សកុម្មុយនីស្តកម្ពុជា ។ ហើយយើងឃើញមានថា នៅក្នុងនេះគឺមានការប្រគល់សិទ្ធិឱ្យកម្ទេចបុគ្គលសំខាន់ៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយក៏រួមទាំងសមាជិកផ្សេងៗនៃគណៈអចិន្ត្រៃយ៍ ។ ស-២១ គឺជាមន្ទីរសន្តិសុខតែមួយគត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានសិទ្ធិអំណាចក្នុងឃុំខ្លួន ធ្វើទារុណកម្ម និងធ្វើសម្លាប់បុគ្គលទាំងឡាយដែលមកពីទីតាំងទាំងអស់នៅក្នុងប្រទេសកម្ពុជា ។

ចំណុចទីបី ខ្ញុំសូមមើលលើឯកសារមួយ ដែលយើងពិភាក្សាអម្បាញ់មិញ ដែលយើងហៅឯកសារនេះថា "ស្ថិតិកម្លាំងរួម" ដែលរៀបចំឡើងប្រចាំខែ៣ ឆ្នាំ១៩៧៧ ។ លោកប្រធាន តើខ្ញុំគួរតែអានលេខ ERN របស់ឯកសារនេះ ឬក៏វាគ្រប់គ្រាន់ហើយដែរថា យើងមានលេខ ERN នេះរួចហើយយើងបានអានរួចហើយនោះ?

**ប្រធានអង្គជំនុំ៖**

បានពិភាក្សាអម្បាញ់ទេ ដូចជាមិនចាំបាច់អានឡើងវិញទេ ពីព្រោះថ្មីៗដែរទេ ។

[១៤:២៨:២៤]

**លោក គ្រេក អេតធេសាន់៖**

សូមអរគុណលោកប្រធាន ។ នៅក្នុងការងារស្រាវជ្រាវរបស់ខ្ញុំនៅលើបញ្ហានេះ ក្នុងរយៈពេល ៣០ឆ្នាំ ខ្ញុំសង្កេតឃើញថា នៅក្នុងស្រុក ឬក៏នៅផ្នែកផ្សេងៗ គឺបុគ្គលិកនៅក្នុងមន្ទីរសន្តិសុខផ្សេងៗគឺមានប្រហែលជាដប់ទៅដប់ប្រាំនាក់គឺយើងឃើញថា បុគ្គលិកដែលមាននៅក្នុងមន្ទីរសន្តិសុខនៅក្នុងតាមតំបន់នោះ គឺវាមានលក្ខណៈច្រើនជាង ដែលយើងឃើញមានចំនួននោះរហូតដល់ម្ភៃទៅសាមសិបនាក់ ។ នៅតាមភូមិភាគមន្ទីរសន្តិសុខ គឺមានលក្ខណៈ មានបុគ្គលិកច្រើនជាងខាងស្រុកនិងតំបន់ ហើយបុគ្គលិកនោះអាចមានចំនួនរហូតទៅដល់ ៥០នាក់ឡើងទៅ ។

យោងតាមឯកសារមួយនេះ ដែលលើកឡើងអំពីស្ថិតិកម្លាំងរួម ស-២១ គឺវាមានបុគ្គលិករបស់

ខ្លួន ហើយឯកសារមួយនេះគឺបានបង្ហាញថា នៅក្នុងខែមីនា ឆ្នាំ១៩៧៧ ស-២១ មានបុគ្គលិក ២៣២៧ នាក់ ។ នេះគឺជាការចង្អុលបង្ហាញមួយសម្រាប់ខ្ញុំ ដែលថា ស-២១ គឺជាអង្គការនិងមន្ទីរមួយដ៏ពិសេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** សូមអរគុណនូវចម្លើយរបស់លោក ។ ខ្ញុំមានសំណួរមួយទៀត ទាក់ទងទៅនឹងទំនាក់ទំនង រវាងមន្ទីរស-២១ ។ កន្លងមកមន្ទីរស-២១ ដែលដឹកនាំដោយលោក ឌុច លោកបានអះអាងថា មិន មានទំនាក់ទំនងជាខ្សែបណ្តោយរវាងមន្ទីរសន្តិសុខផ្សេងទៀតទេនៅក្នុងតំបន់ ។ មានន័យថា មន្ទីរនេះ ទទួលតែអំណាចអំពីថ្នាក់លើតែមួយគត់ ។

សំណួររបស់ខ្ញុំសួរថា តើយោងទៅតាមសេចក្តីសម្រេចរបស់លោកដែលលើកឡើងនៅថ្ងៃ៣០ ខែមីនា ក្នុងឆ្នាំ១៩៧៦ នោះ អាចបង្ហាញថា គាត់មានអំណាចទំនាក់ទំនងត្រឹមតែថ្នាក់លើ ឬក៏អាច មានន័យផ្សេងថា គាត់អាចមានទំនាក់ទំនងខាងខ្សែបណ្តោយ ឬក៏មានសេចក្តីសម្រេចណាផ្សេងទៀត ដែលអាចបង្ហាញថា មានទំនាក់ទំនងខ្សែបណ្តោយ ឬក៏ខ្សែទទឹង? (សុំទោស) គឺខ្សែទទឹង។

**ឆ៖** សូមអរគុណលោកមេធាវី ។ ឯកសារដែលលោកលើកឡើងនោះ គឺឯកសារដែលមាន កាលបរិច្ឆេទថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ គឺសេចក្តីសម្រេចចិត្តរបស់គណៈមជ្ឈិម ដែលយើងបានពិភាក្សា គ្នាពីពេលមុនមកហើយនោះ ។មានបង្កើតនូវរបបនៃការរាយការណ៍ជាប្រចាំទៅកាន់មន្ទីរ៨៧០ ។ ក៏ប៉ុន្តែ នៅក្នុងឯកសារនេះ មិនមានការនិយាយអំពីមន្ទីរស-២១ នោះទេ ។ ហើយឯកសារនេះក៏មិនមានពណ៌នា អំពីការប្រាស្រ័យទាក់ទង ឬក៏ទម្រង់នៃការប្រាស្រ័យទាក់ទងសម្រាប់មន្ទីរស-២១ ដែរ ។ ដូច្នេះ តាម ទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ ឯកសារជាក់លាក់មួយនេះ មិនអាចឆ្លុះបញ្ចាំងទៅលើសំណួរដែលលោកមេធាវី សួរខ្ញុំនេះទេ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរសួរទៅលោកបណ្ឌិត ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញមេធាវីក្រុមពីរ តើមានសំណួរអ្វីសួរទៅលោកបណ្ឌិត ក្រេក អេតឆេសាន់ ដែរឬទេ?

សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** សូមអរគុណលោកប្រធាន ហើយសូមគោរពលោកប្រធាន ព្រមទាំងអង្គជំនុំជម្រះ ។ ខ្ញុំមានពីរបីសំណួរ ដើម្បីសួរទៅលោកបណ្ឌិត គ្រេក ។ ទាក់ទងទៅនឹងរចនាសម្ព័ន្ធដែលបញ្ចាំងអម្បាញ់មិញ ដែលលោក ហុង គឹមសួន សូមឲ្យលោកប្រធានបញ្ចាំងហ្នឹង គឺថាខ្ញុំនៅមានចម្ងល់ខ្លះ ដើម្បីសួរទៅលោកបណ្ឌិត ។ អំពីបញ្ហាមួយចំនួនទាក់ទងទៅនឹងប្រអប់មួយដែលដាក់ថា សុន សេន នាយករដ្ឋមន្ត្រីការពារជាតិ ។ ពីប្រអប់ហ្នឹងហើយមកខាងស្តាំចុះមកខាងក្រោមមកមាន អគ្គសេនាធិការ បើតាមដែលខ្ញុំយល់ពីការអធិប្បាយកន្លងមក គឺថា សុន សេន គឺជាអគ្គសេនាធិការ ។ ចុះពីប្រអប់ពីឧបនាយករដ្ឋមន្ត្រីមក និងអគ្គសេនាធិការមកកន្លែងនេះ តើទំនាក់ទំនងការងារហ្នឹង យ៉ាងម៉េចដែរ?

[១៤:៣៥:០០]

**ឆ៖** សូមអរគុណលោកមេធាវី ។ ខ្ញុំបានគូរតារាងរចនាសម្ព័ន្ធនេះ ដើម្បីព្យាយាមបង្ហាញថា គឺបង្ហាញនូវចំណុចចំនួនពីរ ស្តីអំពីអំណាចរបស់ សុន សេន នៅក្នុងតារាងនេះ ។

ទីមួយ គឺគាត់ដែលជាមនុស្សដែលមានអំណាចស៊ីវិលក្នុងនាមជាឧបនាយករដ្ឋមន្ត្រីការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ហើយតារាងនេះ គឺដើម្បីបង្ហាញផងដែរ ថាបើនិយាយពីផ្នែកយោធាវិញ គឺគាត់មានអំណាចយោធាក្នុងនាជាលេខា ឬក៏ប្រធានសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ។

ខ្សែនៃការប្រាស្រ័យទាក់ទងគ្នានោះ គឺមានន័យថា មានមនុស្សតែម្នាក់តែប៉ុណ្ណោះ គឺ សុន សេន ខ្លួនឯងជាអ្នកត្រួតត្រាផ្ទាល់មកលើអគ្គសេនាធិការ ។ ហើយដូច្នេះហើយគាត់អាចរាយការណ៍ផ្ទាល់ទៅមេរបស់គាត់ អំពីបញ្ហាទាំងអស់ដែលមានពាក់ព័ន្ធដល់បដិវត្តន៍ ដល់កងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ។ តើចម្លើយរបស់ខ្ញុំនេះវាឆ្លើយទៅនឹងសំណួររបស់លោកដែរ ឬទេ លោកមេធាវី?

[១៤:៣៧:១៣]

**ស៖** សូមអរគុណលោកបណ្ឌិត ។ អ៊ីចឹងនៅក្នុងប្រអប់អគ្គសេនាធិការហ្នឹង លោកចង់បញ្ជាក់ថាជាលោក សុន សេន ដែរ មិនអ៊ីចឹង?

សូមអរគុណ អ៊ីចឹងខ្ញុំសូមបន្តសំណួរទៅទៀត ។ ខ្ញុំឃើញប្រអប់ទាំងពីរហ្នឹងកន្លងមកបានលើកឡើងជាច្រើនមកហើយថា ទំនាក់ទំនងរវាងស-២១ហើយនិងអគ្គសេនាធិការហ្នឹងលោក ឌុច ក៏គាត់បានលើកឡើងដែរ ប៉ុន្តែលោកគូរប្រអប់នេះហាក់បីដូចជានៅជិតគ្នាណាស់ ។ អ៊ីចឹងខ្ញុំចង់បានយោបល់

ពីលោកវិញថា តើប្រអប់អគ្គសេនាធិការ ហើយនិងមន្ទីរស-២១ នេះ តើអំណាចទាំងពីរហ្នឹងខ្ពស់ទាបជាងគ្នាប៉ុនណាដែរ នៅក្នុងការប្រតិបត្តិការការងារ? សូមអរគុណ ។

**ឆ៖** ខ្ញុំអាចពិពណ៌នាបានអំពីចំណុចនេះ ។ ជាថ្មីម្តងទៀត ទំនាក់ទំនង គឺវាធ្វើតាមរយៈលក្ខណៈបុគ្គលយ៉ាងហោចណាស់ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ ជនជាប់ចោទនៅក្នុងតួនាទីរបស់គាត់ជាលេខាមន្ទីរស-២១ គាត់ធ្វើការរាយការណ៍ផ្ទាល់ទៅ សុន សេន ហើយដូចដែលយើងទើបតែបាននិយាយនុំង គឺគាត់មានតួនាទីចំនួនពីរ គឺជាឧបនាយករដ្ឋមន្ត្រីការពារជាតិ ព្រមទាំងជាប្រធានអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ។

[១៤:៣៩:២០]

ដូច្នេះ យើងអាចចាត់ទុកថា ស-២១ គឺជាមន្ទីរដែលជាចំណុះរបស់អគ្គសេនាធិការ ក៏ប៉ុន្តែនេះគ្រាន់តែជាការបញ្ជាក់អំពីផ្នែកភស្តុភារនិងការចាត់តាំងតែប៉ុណ្ណោះ ។ ប៉ុន្តែ ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយវិញ ខ្ញុំគិតថាវាប្រហែលជាមានន័យជាងប្រសិនបើយើងចាត់ទុក ស-២១ គឺជាស្ថាប័ននៅក្រោមបង្គាប់របស់គណៈអចិន្ត្រៃយ៍ នៃគណៈមជ្ឈិមរបស់បក្សកុម្មុនីស្តកម្ពុជា ។

**ស៖** សូមអរគុណលោកបណ្ឌិត ។ លោកបណ្ឌិតបានជម្រាបជូនអង្គជំនុំជម្រះរួចហើយថា នៅក្នុងប្រអប់នីមួយៗជាមន្ទីរ ហើយគ្មានរចនាសម្ព័ន្ធនោះទេ ក៏ប៉ុន្តែមានមនុស្សម្នាក់ដែលជាអ្នកមានតួនាទីខ្ពស់បំផុត ដែលគេហៅច្រើនហៅថា “លេខា” មានសិទ្ធិនៅក្នុងការសម្រេចគ្រប់កិច្ចការនៃការប្រតិបត្តិ-ការនៅក្នុងមន្ទីរនីមួយៗ ។

អ៊ីចឹងខ្ញុំចង់ដឹងថា តើមន្ទីរ ស-២១ ហ្នឹង វាដូចគ្នាទៅនឹងអ្វីដែលលោកបានលើកឡើងនោះទេ?

**ឆ៖** សូមអរគុណលោកមេធាវី ។ ខ្ញុំចង់ឲ្យនិយាយយោងទៅលើសេចក្តីអធិប្បាយរបស់ខ្ញុំដែលធ្វើពីមុនទាក់ទៅនឹងសំណួររបស់លោកពីមុនមួយនេះ ។ នៅក្នុងចំណុចភាគច្រើនមន្ទីរ ស-២១ គឺមានលក្ខណៈពិសេសណាស់ ។ លក្ខណៈពិសេសនោះ គឺពិសេសនៅក្នុងចំណោមមន្ទីរសន្តិសុខនានានៅក្នុងបណ្តាញទូទាំងប្រទេស ហើយជាពិសេសទៅទៀតនោះ គឺវាមានលក្ខណៈពិសេសដោយពេលនុំង គឺមន្ទីរនោះគឺជាស្ថាប័នមួយរបស់រដ្ឋាភិបាល ឬក៏ជាស្ថាប័នមួយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងន័យនេះ ទោះបីជាមន្ទីរស-២១ ដឹកនាំឡើងដោយគណៈដែលមានគ្នាបីនាក់ក៏ដោយ ដែលស្ថាប័នភាគច្រើនដែលមានបង្ហាញនៅក្នុងតារាងនេះ ក៏មានការដឹកនាំដោយគណៈដែលមានគ្នានោះដែរ ។ ក៏ប៉ុន្តែមន្ទីរស-២១ គឺមានតួនាទីពិសេសនឹងការទទួលខុសត្រូវខ្ពស់ពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃបដិវត្តន៍ ។ ហើយខ្ញុំ

គិតថា យើងមិនត្រូវមានការភ័ន្តច្រឡំចំពោះការបង្ហាញតារាងរបស់ខ្ញុំនេះទេ ។ មកពីដោយឃើញថា ប្រអប់របស់មន្ទីរនេះវាមានទំហំដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នាទៅនឹងប្រអស់ដដែៗទៀតនៅក្នុងតារាងចាត់ ដែលមានដែលមានបង្ហាញនៅក្នុងតារាងនេះ ។

**ស៖** បាទ សូមអរគុណលោកបណ្ឌិត ។ ខ្ញុំសូមសួរសំណួរតទៅទៀត នៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យមានមន្ទីរសន្តិបាលច្រើនណាស់ នៅតាមតំបន់ផ្សេងៗក៏មាន ចុះហេតុអីបានជានៅក្នុងរចនាសម្ព័ន្ធលោកដាក់តែមន្ទីរសន្តិបាលស-២១? សូមអរគុណ ។

[១៤:៤៣:១៧]

**ឆ៖** សូមអរគុណលោកមេធាវី ។ នៅក្នុងការបង្ហាញជាក់លាក់មួយនេះ ខ្ញុំព្យាមធ្វើការបង្ហាញនូវស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាលកណ្ដាល ។ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខតែមួយគត់របស់រដ្ឋា-ភិបាលមជ្ឈិម ។ ដូច្នេះហើយបានជាមានការបញ្ចូលនៅក្នុងតារាងនេះ ។

តាមពិត ទៅយើងក៏មានតារាងផ្សេងៗទៀតដែរ ដែលមានការបង្ហាញមន្ទីរសន្តិសុខនានា ក៏ប៉ុន្តែការពិនិត្យមើលទៅលើរចនាសម្ព័ន្ធផ្ទៃក្នុងនៃមន្ទីរសន្តិសុខនោះ គឺមិនមែនជាគោលដៅសំខាន់នៃរបាយ-ការណ៍វិភាគនេះទេ ។

**ស៖** សូមអរគុណលោកបណ្ឌិត ។ ហើយខ្ញុំសូមសួរមួយសំណួរទៀតដែលជាសំណួរចុងក្រោយមាននៅក្នុងរបាយការណ៍របស់លោក ទំព័រខ្មែរ៦៤ ហើយ ERNហ្នឹង ជា ERN ខ្មែរដែរ គឺ00314841 ហើយនៅបន្ទាត់ពីលើៗពាក្យថា "សភាតំណាងប្រជាជន" នៅបន្ទាត់ពីលើហ្នឹងទៀត ហើយខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីអានអ្វីសំណេររបស់លោកបណ្ឌិតបន្តិច ដើម្បីអានរួចហើយចាំខ្ញុំតាំងសំណួរជាក្រោយ ។

ខ្ញុំសូមអានតែត្រឹមកថាខណ្ឌជាចុងក្រោយនេះទេ ដាក់ថា "ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច វន វ៉េត បានសារភាពនូវមន្ទីរស-២១ ថាវាជាការលំបាកសម្រាប់គាត់ក្នុងការការពារអ្នកក្រោមឱវាទសំខាន់ៗរបស់ខ្លួនពីល្បិចកលរបស់សាខាពិសេសដូចដែល ជួនកាលគេហៅថាមន្ទីរស-២១" ប្រហែលជានៅភាសាអង់គ្លេស ខ្ញុំអត់ដឹងនៅចំណុចណា បើសិនណាជាអង្គជំនុំជម្រះបានឃើញហើយខ្ញុំនឹងតាំងសំណួរតែម្ដង ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ជាភាសាអង់គ្លេសគឺនៅទំព័រ៣៧ ។

**លោក គង់ ពិសី៖**

អ៊ីចឹងខ្ញុំសូមតាំងសំណួរតែម្តងគឺថា ពាក្យថា "ល្បិចកិច្ចកល ល្បិចកលរបស់សាខាពិសេសដូចដែលជួនកាលគេហៅថា មន្ទីរស-២១" នេះសួរថា តើវាមានន័យសំខាន់យ៉ាងដូចម្តេច? ហើយវាស៊ីជម្រៅយ៉ាងដូចម្តេចបានលោកសរសេរថា ជាល្បិចកល ហើយនៅក្នុងនោះទៀតដាក់ថា ជាសាខាពិសេស? សូមអរគុណ ។

[១៤:៤៧:១៣]

**លោក ក្រេក អេតធេសាន់៖**

សូមអរគុណលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

តើលោកអាចឲ្យលេខកថាខណ្ឌមកឲ្យខ្ញុំបានទេ? កថាខណ្ឌទីប៉ុន្មានទៅ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

បាទ គឺនៅក្នុងកថាខណ្ឌ១៤៨ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ប្រហែលជាលោកប្រធានអាចឲ្យលោក អេតធេសាន់ ពិនិត្យមើលអត្ថបទជាដើម ដែលជាភាសាអង់គ្លេសបាន ។

**លោក ក្រេក អេតធេសាន់៖**

សូមអរគុណលោកមេធាវី ។ ខ្ញុំគិតនេះ គឺជាចំណុចមួយទៀតក្នុងចំណោមចំណុចដ៏ច្រើនទាក់ទងទៅនឹងការធ្វើការនៅជាបីភាសានៅក្នុងតុលាការយើងនេះ ។ ខ្ញុំនឹងអានអត្ថបទនេះជាភាសាអង់គ្លេសហើយបន្ទាប់មកយើងអាចធ្វើការពិភាក្សាទៅលើពាក្យដែលត្រូវបានបកប្រែកថា ជាភាសាខ្មែរថាទៅជាល្បិចកលនោះ ។

នៅក្នុងភាសាអង់គ្លេសប្រយោគហ្នឹង ។ ខ្ញុំសូមដកស្រង់ឡើងវិញ "ក្នុងនាមជាឧបនាយរដ្ឋមន្ត្រីផ្នែកសេដ្ឋកិច្ចលោក វន វ៉េត បានសារភាពនៅស-២១ ថា គឺជាការពិបាកសម្រាប់គាត់ណាស់ ដើម្បីការពារអ្នកនៅខាងក្រោមបង្គាប់សំខាន់ៗរបស់គាត់ពីការបំផ្លាញរបស់សាខាពិសេស ដែលជួនកាលគេ

ហៅថា ស-២១" ។ នៅក្នុងករណីបែបនេះ--

**លោក គង់ ពិសី៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធានម្តងទៀតថា អ៊ីចឹងយើងយកភាសាណាមួយដើម្បីសូមឲ្យមាននៅក្នុងប្រតិចារឹកថា យើងកំណត់យកភាសាមួយសិន ហើយចាំសឹមឲ្យលោកបណ្ឌិតបកស្រាយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវ បញ្ជាក់ឡើងវិញអំពីលោកបណ្ឌិតក្នុងការប្រើភាសានេះ ជាភាសាអង់គ្លេស យើងអានតែមួយពាក្យទេ គឺក្នុងពាក្យថា "កលល្បិច" ហើយថាតើភាសាអង់គ្លេសត្រង់កន្លែងហ្នឹង ដែលយើងមកជាការកម្ទេច ឬក៏ការបំផ្លាញវិញហ្នឹង តើភាសាអង់គ្លេសថាយ៉ាងម៉េច? ហើយសូមអ្នកបកប្រែ គឺបកប្រែឃ្លានេះឲ្យបានច្បាស់ ពាក្យនេះឲ្យបានច្បាស់ ពីព្រោះអាចខុសគ្នាច្រើនណាស់ បើភាសានេះ ។

[១៤:៥០:២០]

**លោក គ្រេក អេតធេសាន់៖**

គឺជាការត្រឹមត្រូវហើយលោកមេធាវី នេះគឺជាបញ្ហានៃការបកប្រែដែលមិនបានល្អឥតខ្ចោះនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំអាចនិយាយ ខ្ញុំចង់និយាយថា ខ្ញុំយល់ថា ពីមុនមកយើងបានរំឭករួចមកហើយថា យើងមានការបារម្ភជាក់លាក់ ទៅលើមាត្រា១៥ទាក់ទងទៅនឹងការធ្វើទណ្ឌកម្មនោះ ។ ឥឡូវនេះ គឺយើងនិយាយអំពីអត្ថបទនៃចម្លើយសារភាពរបស់នរណាម្នាក់ ដែលបានជាប់នៅឯស-២១ ។ ហើយគាត់ប្រហែលជាត្រូវបានទទួលនូវការសួរចម្លើយ ដោយធ្វើទារុណកម្ម ។ ដូច្នេះ ខ្ញុំមិនដឹងថា តើនេះជាយោបល់ល្អ ឬក៏អត់ទេ ដើម្បីធ្វើការផ្អែកទៅលើឯកសារយោងបែបនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងត្រូវសម្រេចឲ្យបានច្បាស់លាស់ ពីព្រោះថាការបកស្រាយនេះ ឥឡូវហ្នឹងដល់មានការពិភាក្សាលើផ្នែកមួយនៃកថាខណ្ឌ១៤៨ ហើយកថាខណ្ឌនេះ ដោយសារមានហេតុផលនៃការបញ្ហាការបកប្រែភាសា ហើយជាគោលការណ៍ដែលយើងបានសម្រេចរួចហើយ ដោយសារតែលោកបណ្ឌិត ដែលជាអ្នកជំនាញ លោកសរសេរនូវរបាយការណ៍របស់ខ្លួន ជាភាសាដើម ជាភាសាអង់គ្លេស ហើយទើបតែបកប្រែជាភាសាខ្មែរ ។ អ៊ីចឹងហើយបានជាយើងចង់ផ្ទៀងផ្ទាត់ភាសាត្រង់ចំណុច ដែល

ខុសគ្នានេះ ជាភាសាអង់គ្លេស ហើយអ្នកជំនាញក្នុងការបកប្រែនេះ ភាសាអង់គ្លេសដែលត្រឹមត្រូវ ឆ្លើយតបនឹងឃ្លានេះ ឱ្យស្របគ្នានឹងឃ្លា ដែលលោកបណ្ឌិត ពាក្យដែលលោកបណ្ឌិតប្រើប្រាស់ត្រង់ចំណុចនេះ ជាភាសាខ្មែរ ជាភាសាអ្វី ។ អ៊ីចឹង គឺយើងផ្អែកលើមូលដ្ឋាននេះ យើងមិនយកភាសាខ្មែរទេ ដោយសារភាសាខ្មែរបកចេញពីភាសាអង់គ្លេស ដែលជារបាយការណ៍ដើមរបស់អ្នកជំនាញ ដែលយើងកំពុងធ្វើការពិភាក្សាដេញដោលនេះ ។ អ៊ីចឹងហើយ បានជាយើងខ្ញុំឱ្យអ្នកបកប្រែភាសា បកនូវចំណុចនេះទីមួយអានជាភាសាអង់គ្លេសឱ្យបានច្បាស់លាស់ ត្រង់ចំណុចដែលនាំឱ្យមានការបកប្រែ មានការភ័ន្តច្រឡំនេះ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក អេតធេសាន់ តើលោកអាចបញ្ជាក់ប្រាប់ដល់យើងខ្ញុំទេថា ប្រសិនបើឯកសារយោងដែលលោកបានលើកឡើងទាក់ទងទៅនឹងចម្លើយសារភាពរបស់ វន វ៉េត នោះ គឺជាចម្លើយសារភាពដែលគាត់បានធ្វើនៅពេលដែលគាត់ជាប់ឃុំឃាំងឬ? ហើយថាតើចម្លើយសារភាពនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីគាត់ត្រូវបានគេសួរចម្លើយ ដោយប្រើអំពើហិង្សា ឬក៏យ៉ាងម៉េច?

**ឆ៖** សូមអរគុណលោកចៅក្រម ។ ត្រឹមត្រូវហើយ ចម្លើយសារភាពនេះត្រូវបានដកស្រង់មកពី វន វ៉េត នៅពេលដែលគាត់ជាប់ឃុំឃាំងនៅស-២១ ។ ក៏ប៉ុន្តែ យើងមិនបានដឹងច្បាស់ថា អត្ថបទជាក់លាក់មួយផ្នែកនៅក្នុងចម្លើយសារភាពរបស់គាត់នេះ ត្រូវបានសរសេរនៅមុនពេល ឬក៏នៅក្នុងអំឡុងពេល ឬក៏នៅក្រោយពេល ដែលគាត់អាចនឹងត្រូវបានគេធ្វើទារុណកម្មនោះ ។ ដូច្នេះ ខ្ញុំមិនអាចឆ្លើយបានឱ្យបានច្បាស់លាស់ទៅលើផ្នែកទីពីរនៃសំណួររបស់លោកនោះទេ ។

[១៤:៥៥:០៧]

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម យូរ ឧត្តរា អាចបញ្ជាក់ពីភាសានេះបានទេ? ដើម្បីឱ្យច្បាស់លាស់ភាសាដែល--ឃ្លាដែលប្រើប្រាស់ជាភាសាអង់គ្លេសនៅ ដែលត្រូវយកមកពិភាក្សានេះ ។ នៅក្នុងនោះ គឺមានការខុសពាក្យគ្នា គឺពាក្យល្បិចកល ហើយនិងការបំផ្លាញនេះ ។

**ចៅក្រម យូរ ឧត្តរា៖**

*(មិនឮសំឡេង)*

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹង ខ្ញុំចង់ឲ្យអ្នកបកប្រែហ្នឹង អាចបកប្រែពាក្យភាសាអង់គ្លេស ដែលថា ឌីភីដេសិន មកជាភាសាខ្មែរបានទេ?

ដូច្នេះ គឺយើងត្រូវការការបកប្រែជាភាសាខ្មែរ ។

*(សម្រាប់លោកចៅក្រម ពាក្យអង់គ្លេសថា ឌីភីដេសិន ហ្នឹង ជាភាសាខ្មែរបកថា ការបំផ្លិចផ្លាញ)*

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាកិច្ចពិភាក្សាបន្តនេះ គឺត្រូវយល់នូវឃ្លាត្រង់ចំណុចនេះ គឺជាការបំផ្លិចបំផ្លាញ ដែលជំនួសនឹងពាក្យថា ល្បិចកល ពីព្រោះផ្អែកលើឯកសារដើម ដែលរៀបចំឡើងដោយអ្នកជំនាញ ។

**សួរដោយ លោក គង់ ពិសី៖**

បាទ, ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីតាំងសំណួរសាថ្មីវិញ? ព្រោះប្តូរពាក្យហ្នឹង ។

លោកបណ្ឌិត ខ្ញុំសូមអនុញ្ញាតសួរលោក សំណួរដដែល ប៉ុន្តែយើងប្រើពាក្យពេចន៍ថ្មី ។

**ស៖** ទាក់ទងទៅនឹងប្រយោគតែងនេះ ខ្ញុំចង់សួរលោកថា តើពាក្យថាការបំផ្លិចបំផ្លាញរបស់សាខាពិសេសដូចដែលជួនកាល គេហៅថាមន្ទីរស-២១ មួយនោះ តើនៅក្នុងហ្នឹងមានន័យយ៉ាងដូចម្តេចដែរ? ហើយហេតុអីបានជាដាក់ថា ដូចដែលជួនកាលគេហៅថាមន្ទីរស-២១? សូមអរគុណ ។

**ឆ៖** សូមអរគុណលោកមេធាវី ។ ប្រហែលជាយើងមានបញ្ហាចំនួនពីរនៅត្រង់ចំណុចនេះ ។ នៅក្នុងបញ្ហាទីមួយសាខាពិសេស ជួនកាលត្រូវបានគេប្រើជាឈ្មោះសម្រាប់មន្ទីរស-២១ ។

ជាឧទាហរណ៍នៅក្នុងវគ្គបណ្តុះបណ្តាលរបស់គាត់ សម្រាប់បុគ្គលិកស-២១ ជនជាប់ចោទនេះជួនកាលហៅ គាត់ស្ថាប័នដែលគាត់ជាប្រធាននេះ ថាជាសាខាពិសេស ។ ដូច្នេះ ខ្ញុំមិនមានធ្វើឲ្យមាន--ចង់មានការភ័ន្តច្រឡំនៅលើចំណុចនេះទេ ពីព្រោះអី ពាក្យថា សាខាពិសេសនេះ គឺជាឈ្មោះមួយទៀតរបស់ ស-២១ ។ គ្រាន់តែអ្នកខ្លះហៅថា ស-២១ អ្នកខ្លះទៀតហៅថា “ទួលស្លែង” អ៊ីចឹង ។ បញ្ហាទីពីរ គឺទាក់ទងទៅនឹងពាក្យថា *ឌីភីដេសិន* ហើយនិងអ្វី ដែលលោក វន វ៉េត ប្រហែលជាមានន័យ គាត់ចង់និយាយទាក់ទងទៅនឹងស-២១ នោះ ។

[១៥:០០:១៤]

ដូច្នេះ ខ្ញុំចង់និយាយអំពីការធ្វើការចាប់ជាបន្តបន្ទាប់នូវកម្មាភិបាល នៅក្រោមបង្គាប់របស់គាត់នៅមន្ទីររបស់គាត់ ។ គឺធ្វើឲ្យប៉ះពាល់ដល់ដំណើរការរៀបចំ គ្រប់គ្រង ធ្វើផែនការ និងដំណើរការនានា

និងក្នុងការអនុវត្តគោលនយោបាយនៅក្នុងក្រសួងរបស់គាត់ ពីព្រោះអ្នកនៅក្រោមបង្គាប់សំខាន់ៗរបស់គាត់ ដែលទទួលភារកិច្ចក្នុងការបំពេញភារកិច្ចមួយចំនួន នៅក្នុងគោលនយោបាយក្រសួងរបស់គាត់នោះ គឺចេះតែបាត់ខ្លួនបន្តបន្ទាប់ទៅមន្ទីរស-២១ ។ ដូច្នេះហើយ មានន័យថាគាត់ត្រូវចាប់ផ្ដើមជាថ្មីម្តងទៀត។ នេះគឺជាអ្វីដែលខ្ញុំចង់មានន័យ នៅពេលដែលខ្ញុំប្រើពាក្យថា ការបំផ្លិចបំផ្លាញនោះ ។ តើចម្លើយរបស់ខ្ញុំរបស់ហ្នឹង វាឆ្លើយតបទៅនឹងសំណួររបស់លោកទេ លោកមេធាវី?

**ស៖** សូមអរគុណ ។ អ៊ីចឹងទាក់ទងទៅនឹងការបំផ្លិចបំផ្លាញ ដែលស្តែងចេញពី ស-២១នេះ តើលោកយល់ថា វាជាចេតនាពិសេសរបស់មន្ទីរ ស-២១ ឬមួយក៏ក្រៅពីហ្នឹងផ្សេងទៀត?

**ឆ៖** សូមអរគុណលោកមេធាវី ។ សំណួរនេះ គឺពិតជាពិបាកណាស់ ដែលវាត្រូវតែធ្វើការពិនិត្យទៅលើចំណុចនេះ ហើយចុងក្រោយធ្វើការសម្រេចដោយអង្គសវនាការ ។ យើងអាចនិយាយថា ការសម្រិតសម្រាំងពីខាងក្រសួងសេដ្ឋកិច្ចនោះ គឺវាកើតឡើងដោយការភ័យខ្លាចរបស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ។ ហើយចំណុចមួយទៀតនោះ យើងអាចនិយាយថា ការសម្រិតសម្រាំងនៅក្នុងក្រសួងសេដ្ឋកិច្ច គឺកើតឡើងដោយបញ្ហាវិធីសាស្រ្ត ដែលគេធ្វើឡើង ដើម្បីស្វែងរកខ្មាំង ហើយវិធីសាស្រ្តនេះ ត្រូវបានបង្កើតឡើង និងអនុវត្តដោយជនជាប់ចោទ ។ ដូច្នេះ ចម្លើយដែលត្រឹមត្រូវចំពោះសំណួររបស់លោកហ្នឹង គឺវាអាចកើតចេញពីចំណុចទាំងពីរនេះ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកបណ្ឌិត ហើយខ្ញុំក៏សូមអរគុណលោកប្រធានដែរ ហើយសហសេវិកខ្ញុំខាងមេធាវីអន្តរជាតិគាត់នឹងមានសំណួរទៀត បើសិនជាលោកប្រធានអនុញ្ញាតពេលនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកហើយ អាចឈប់សម្រាកម្ភៃមីនុត រហូតដល់ម៉ោងបី និងម្ភៃនាទីចូលវិញ ។ ហើយទើបបន្តដំណើរការសវនាការទៀត ហើយអ៊ីចឹងសូមមេធាវីរង់ចាំពេលចូលមកវិញ ។

*[សវនាការសម្រាកពីម៉ោង១៥:០៤នាទី ដល់ម៉ោង ១៥:២៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត ដំណើរការសវនាការ ។ ជាបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីស្ទូតហ្សឺនស្តី ដែលជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ អញ្ជើញ

តាំងសំណួរពាក់ព័ន្ធ ទៅនឹងអ្នកជំនាញ ក្រេក អេតឆេសាន់ ។

**លោកស្រី ស៊ីលយីស្ទូត ហ្សីនស្ដី៖**

**ស៖** សូមអរគុណ លោកប្រធាន ។ សួស្ដីលោកអ្នកជំនាញ! ជាដំបូង ខ្ញុំចង់ឲ្យលោកធ្វើការបញ្ជាក់បន្តិចទៅលើអ្វី ដែលលោកបាននិយាយពីមុនមក គឺទាក់ទងទៅនឹងអំណាចរបស់ជនជាប់ចោទ ។ សំណួររបស់ខ្ញុំនោះគឺថា លោកបានជម្រាបប្រាប់យើងខ្ញុំថា លោកមានមន្ទិលសង្ស័យថា ជនសង្ស័យមិនមានអំណាចក្នុងការដោះលែងអ្នកទោសណាម្នាក់ទេ តើលោកអាចពន្យល់បានពីមូលដ្ឋាននៃការធ្វើសេចក្ដីសន្និដ្ឋានបែបបនេះរបស់លោកទេ?

**ឆ៖** សូមអរគុណអ្នកស្រីមេធាវី ។ លោកបានរៀបឃ្លារបស់លោក គឺមានន័យថា ជាឃ្លាបដិសេធដល់ទៅពីរដង ដែលថាខ្ញុំមានមន្ទិលសង្ស័យ ថាគាត់គ្មានអំណាចក្នុងការដោះលែងនរណាម្នាក់ អ៊ីចឹងមានន័យថា លោកស្រីនិយាយថា ខ្ញុំជឿថា គាត់អាចដោះលែងមនុស្សបាន តើការយល់ដឹងរបស់ខ្ញុំត្រឹមត្រូវទេ?

**ស៖** នេះជាអ្វីដែលខ្ញុំបាននិយាយថា គាត់បានិយាយពីមុនមក ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ទៅលើចំណុចនេះទេ ។

**ឆ៖** ខ្ញុំមិនជឿថា ជនជាប់ចោទមានអំណាចស្វយ័ត ក្នុងការដោះលែងជនជណាម្នាក់នោះទេ ។ ហើយខ្ញុំជឿថា បើសិនជាគាត់បានធ្វើដូច្នោះមែន តួនាទីនិងតំណែងរបស់គាត់នោះ នឹងត្រូវបានគេបំផ្លាញបាត់ទៅហើយ ។ ក៏ប៉ុន្តែ ខ្ញុំក៏ជឿដែរថា មានកាលៈទេសៈមួយចំនួន ដែលគាត់មិនបានទទួលការអនុញ្ញាត ឬក៏បានទទួលការណែនាំ ក្នុងការដោះស្រាយបុគ្គលមួយចំនួន ។

**ស៖** សូមអរគុណ ចំពោះការបកស្រាយរបស់លោក ។ ឥឡូវនេះ ខ្ញុំចង់បានយោបល់ជំនាញរបស់លោកទៅលើបញ្ហាដែលយើងបានពិភាក្សាគ្នាកាលពីព្រឹកមិញនេះ អំពីទំនាក់ទំនងរវាងជនជាប់ចោទហើយនិង ស៊ូ ម៉េត ។ សំណួររបស់ខ្ញុំដាក់ទៅជូនលោកដែលជាអ្នកជំនាញនោះគឺថា នៅពេលដែលយើងមើលទៅលើការទាក់ទងគ្នាទៅតាមឯកសារ ដែលជាលិខិតអស់ទាំងនុ៎ះ តើយើងអាចយកថានេះគឺជាគំរូនៃការប្រាស្រ័យទាក់ទងរវាងជនជាប់ចោទនិងលេខានៃកងពលនានាដែរឬទេ? ថាតើកងពលអស់ទាំងនុ៎ះ បានរាយការណ៍ដោយផ្ទាល់ទៅមជ្ឈិមដែរឬទេ?

**ឆ៖** បាទ, លោកស្រីមេធាវី! ខ្ញុំនឹងមិនភ្ញាក់ផ្អើលទេ បើសិនជាយើងអាចពិនិត្យ ឬក៏ឃើញឯកសារផ្សេងៗមកពីកងពលផ្សេងៗ ដែលអាចបង្ហាញអំពីទម្រង់ប្រហាក់ប្រហែលគ្នានៃការប្រាស្រ័យ

ទាក់ទងរវាងលេខានៃមន្ទីរស-២១ និងលេខានានានៃកងពលដទៃទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា ឬមួយក៏លេខានានានៃអង្គភាពចាត់តាំងផ្សេងៗទៀតនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះ ។

ដូច្នេះចម្លើយរបស់ខ្ញុំ គឺបាន ។ ខ្ញុំគិតថា យើងអាចចាត់ទុកថា នេះគឺជាគំរូ ឬក៏ទម្រង់នៃការប្រាស្រ័យទាក់ទងគ្នា ។

**ស៖** សូមអរគុណ ។ ឥឡូវ ខ្ញុំនិយាយអំពីខ្សែសង្វាក់នៃការដាក់បញ្ជា។ តើអ្វីទៅជាវិធីសាស្រ្តដែលត្រូវបានគេប្រើនៅក្នុងការត្រួតត្រាតាមលំដាប់នីមួយៗ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើកថាខណ្ឌ ៥៧ នៃរបាយការណ៍របស់លោក ដែលលោកបានរៀបរាប់អំពីវិធីសាស្រ្តដទៃទៀត និងថាតើមានវិធីសាស្រ្ត ឬក៏យន្តការនៃការត្រួតពិនិត្យបែបណា?

**ឆ៖** សូមអរគុណ លោកស្រីមេធាវី ។ នៅក្នុងផ្នែកនៃរបាយការណ៍នេះ គឺនៅកថាខណ្ឌ៥៧ នៃរបាយការណ៍របស់ខ្ញុំ គឺជាការបង្ហាញមួយអំពីរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ។ ហើយខ្ញុំបានធ្វើការពិភាក្សាអំពីការ គំរូនៃការប្រាស្រ័យទាក់ទងរវាងថ្នាក់ភូមិភាគទៅនឹងមជ្ឈិម ។ ខ្ញុំបានធ្វើការពិភាក្សាអំពីសារទូរលេខ និងសារតាមរយៈនីរសារ ព្រមទាំងការជួបប្រជុំផ្ទាល់មុខ រវាងគណៈលេខា និងបុគ្គលិករបស់ភូមិភាគ និងបុគ្គលិកដែលមកពីគណៈមជ្ឈិម ដែលការប្រជុំអស់ទាំងហ្នឹង អាចធ្វើឡើងនៅទីក្រុងភ្នំពេញ ឬក៏នៅតាមភូមិភាគ ។

ប្រហាក់ប្រហែលគ្នានេះដែរ ទៅតាមការកត់សម្គាល់របស់ខ្ញុំ ថ្នាក់ដឹកនាំភូមិភាគបានធ្វើការប្រាស្រ័យទាក់ទងជាមួយថ្នាក់ក្រោម នៅក្នុងភូមិភាគផ្ទាល់ខ្លួនរបស់ខ្លួននោះ ដោយប្រើការសរសេរជាលាយលក្ខណ៍អក្សរ ព្រមទាំងការជួបប្រជុំដោយផ្ទាល់មុខ ។ មេដឹកនាំតាមភូមិភាគ ជួនកាលបានចេញទៅធ្វើទស្សនកិច្ចតាមតំបន់ តាមស្រុក និងជួនកាលតាមសហករណ៍ផងដែរ ដើម្បីធ្វើការពិនិត្យមើលស្ថានភាពនៅក្នុងភូមិភាគរបស់ខ្លួន ។

[១៥:៣៣:៣៦]

ខ្ញុំក៏បាននិយាយផងដែរ នៅក្នុងផ្នែកនៃរបាយការណ៍នេះ ដែលថាការប្រជុំរបស់បក្សជាផ្លូវការត្រូវបានធ្វើនៅតាមថ្នាក់នីមួយៗ ទៅតាមអំឡុងពេលដែលបានកំណត់ជាទៀងទាត់ ។ ហើយនេះ គឺបណ្តាលឲ្យមានគណៈបក្សនៅតាមថ្នាក់នីមួយៗមានឱកាសក្នុងការពិភាក្សាគ្នាដោយម៉ឺងម៉ាត់ អំពីបញ្ហានានាទាក់ទងទៅនឹងបក្ស ទៅនឹងការចាត់តាំង ទៅនឹងការកសាង និងទៅនឹងមាគ៌ារបស់បក្ស ព្រមទាំងធ្វើការពិភាក្សាទៅការអនុវត្ត នូវសេចក្តីណែនាំជាក់លាក់ណាមួយពីថ្នាក់លើ ។

ជាទីបញ្ចប់ ក៏មានការពិភាក្សាផងដែរ អំពីភាពញឹកញាប់នៃការធ្វើសេចក្តីរាយការណ៍ទៅតាមថ្នាក់នីមួយៗ ហើយខ្ញុំក៏បានធ្វើការកត់សម្គាល់ថា ភូមិភាគត្រូវធ្វើសេចក្តីរាយការណ៍ទៅមជ្ឈិម យ៉ាងហោចណាស់មួយដងក្នុងមួយសប្តាហ៍ ។ ហើយដូច្នេះហើយ ដូចជាទំនងថា មានការធ្វើការរាយការណ៍បែបនេះ ឬក៏ប្រហាក់ប្រហែលជាគ្នានេះដែរ ពីថ្នាក់ក្រោមៗមកថ្នាក់ភូមិភាគ ។ តើអ្វីដែលខ្ញុំលើកឡើងនេះវាឆ្លើយទៅនឹងសំណួររបស់លោកទេ លោកស្រីមេធាវី?

**ស៖** ចាស៎ ខ្ញុំចង់បន្តទៀត ។ តើខ្ញុំត្រឹមត្រូវទេ នៅពេលដែលធ្វើការសន្និដ្ឋានថា ការធ្វើរបាយការណ៍ និងការពឹងអាស្រ័យទៅលើរបាយការណ៍នោះ គឺមិនមែនជាមធ្យោបាយតែមួយទេ ដើម្បីបានដឹងពីអ្វីដែលកំពុងតែកើតមានឡើងនៅតាមមូលដ្ឋាននានានោះ ។ មានន័យថា ការត្រួតពិនិត្យជាលក្ខណៈបុគ្គលទៅលើស្ថានភាព និងអ្វីដែលកើតឡើងនៅក្នុងប្រទេសនេះ ក្រៅពីអ្វីដែលមានចែងនៅក្នុងរបាយការណ៍នោះ?

**ឆ៖** បាទ, លោកស្រីមេធាវី នៅក្នុងករណីជាច្រើនដែលយើងបានដឹង ហើយខ្ញុំមានការសង្ស័យយ៉ាងរឹងមាំថា នៅក្នុងករណីមួយចំនួនទៀត ដែលពួកយើងមិនទាន់បានដឹងនៅឡើយនោះ មេដឹកនាំមកពីមជ្ឈមបក្សបានធ្វើដំណើរទៅភូមិភាគ និងទៅថ្នាក់ក្រោមដទៃៗទៀតនៃអង្គការ ដើម្បីធ្វើការអង្កេតដោយផ្ទាល់អំពីស្ថានភាពដែលកំពុងតែកើតមានឡើងនៅទូទាំងប្រទេស ។ នេះគឺជាវិធីសាស្ត្រមួយទៀតសម្រាប់ពួកគេក្នុងការប្រមូលព័ត៌មាន ហើយនេះក៏ជាវិធីដែលមិនអាស្រ័យដោយផ្ទាល់ ទៅលើការរាយការណ៍ជាត្រឹមត្រូវពីអ្នកដទៃទៀត ។

**ស៖** សូមអរគុណ ។ លោកបានរៀបរាប់អំពីខ្សែរយៈទទឹង បណ្តោយ នៅក្នុងការប្រាស្រ័យទាក់ទងផ្នែកយោធានិងលេខាភូមិភាគនានា គឺមានការត្រួតត្រាយ៉ាងមានប្រសិទ្ធភាព ទៅលើថ្នាក់ក្រោមដទៃទៀត អាស្រ័យទៅតាមការស្រាវជ្រាវរបស់លោកនោះមែនទេ?

[១៥:៣៧:៤៧]

**ឆ៖** សូមអរគុណលោកស្រីមេធាវី ។ នេះគឺជាសំណួរមួយដែលមានលក្ខណៈស្មុគស្មាញ ពីព្រោះដូចជាលោកស្រីបានដឹងអ៊ីចឹង គឺថាមានភូមិភាគច្រើនណាស់ ហើយនិងមានតំបន់ដ៏ច្រើន និងមានស្រុកកាន់តែច្រើនថែមទៀត ហើយនិងមានសហករណ៍ និងឃុំដ៏ច្រើន ។ ហើយប្រហែលជាមិនសមហេតុសមផលទេ ដើម្បីធ្វើការ ធ្វើសេចក្តីសន្និដ្ឋានរួម ហើយដែលយល់ថា សេចក្តីសន្និដ្ឋាននោះគឺវាអាចអនុវត្តបាននៅគ្រប់ទីកន្លែងនៅគ្រប់ពេលវេលាទាំងអស់នោះ ។ ហើយចំណុចនេះ វាកាន់តែពិតទៀត

ទាក់ទងទៅនឹងករណីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលពួកគេមានឧប្បត្តិហេតុដ៏ខ្ពស់នៃការទាក់ទងទៅនឹងការចាត់តាំង ។ មានការសម្រិតសម្រាំងជាបន្តបន្ទាប់នៅក្នុងជួរ ទៅតាមពេលវេលាដែលមានកើតមានជាបន្តបន្ទាប់នោះ គឺកើតមានសឹងតែនៅគ្រប់ទីកន្លែងនៅក្នុងប្រទេស ។ ហើយនៅទីកន្លែងជាច្រើនការសម្រិតសម្រាំងបែបនេះ បានកើតមានឡើងម្តងហើយម្តងទៀត ហើយម្តងទៀតៗ សម្រាប់មន្ទីរតែមួយនោះ នៅទីកន្លែងតែមួយ និងនៅថ្នាក់តែមួយនោះ ។

ថិតនៅក្នុងកាលៈទេសៈបែបនេះ ដែលចេះតែបន្ត ហើយនិងធ្វើការផ្លាស់ប្តូរថ្នាក់ដឹកនាំនោះ ហើយស្ថានភាពនៃភាពមិនដឹងច្បាស់លាស់អំពីស្ថានភាពពិតប្រាកដនោះ បណ្តាលឲ្យម្នាក់អាចគិតថា នឹងមានកម្រិតនៃការមិនអនុវត្តការងារ នៅក្នុងការចាត់តាំង និងការអនុវត្តគោលនយោបាយ ។ បើសិនជាយើងនិយាយឲ្យសាមញ្ញនោះ មានន័យថា ពេលនោះ គឺថាស្ថានភាពច្របូកច្របល់ និងគួរឲ្យភ័យខ្លាចណាស់ នៅក្នុងស្ថានភាពជាច្រើនលើពេលវេលា ។ ហើយទោះបីជានិយាយហើយដូច្នេះក៏ដោយ បក្សកុម្មុយនីស្តកម្ពុជាបានតម្លៃដ៏ខ្ពស់ ទៅលើការស្តាប់បង្គាប់ ហើយនិងវិន័យ ហើយនិងការអនុវត្តយ៉ាងម៉ឺងម៉ាត់នៃគោលមាគ៌ានយោបាយរបស់បក្ស ដែលបានកំណត់ដោយបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ។ ហើយខ្ញុំអាចនិយាយថា នៅក្នុងកន្លែង ទីកន្លែងដ៏ច្រើននោះ គឺភាគច្រើនកម្មាភិបាលគឺខំព្យាយាមអស់សមត្ថភាពរបស់ខ្លួនដើម្បីអនុវត្តន៍នូវមាគ៌ានយោបាយរបស់បក្ស ទៅតាមលទ្ធភាពដែលពួកគេបានយល់ដឹង ។

[១៥:៤១:០៧]

**ស៖** សូមអរគុណ ។ ខ្ញុំសូមនិយាយអំពីវគ្គអប់រំ ដែលលោកបានរៀបរាប់រួចមកហើយ ។ តើលោកបានដឹងដែរឬទេថា អ្នកដែលនៅក្នុងជួរជាមួយគ្នាហ្នឹងគឺបានចូលរួមនៅក្នុងវគ្គអប់រំតែមួយ ឬក៏វគ្គអប់រំនោះគឺចូលរួមដោយសមាជិកផ្សេងៗមកពី ឬក៏កម្មាភិបាលផ្សេងៗមកពីមន្ទីរដទៃៗ?

**ឆ៖** សូមអរគុណមេធាវី យើងឃើញមានវគ្គអប់រំផ្សេងៗខុសៗគ្នា ហើយវគ្គអប់រំនោះត្រូវបានរៀបចំឡើងនៅតាមកម្រិតនៃថ្នាក់ដឹកនាំរបស់បក្ស គឺមានការរៀបចំតាំងពីជួរមជ្ឈិម រហូតដល់ជួរភូមិភាគ រហូតដល់ជួរតំបន់ រហូតដល់ជួរយោធា ហើយរហូតដល់កម្រិតអគ្គសេនាធិការ... ។ល ។

នៅក្នុងករណីមួយចំនួន ឧទាហរណ៍មជ្ឈិមបក្ស គឺបានកោះហៅលេខាស្រុក ហើយនិងអនុលេខាស្រុកមកពីទូទាំងប្រទេស ឲ្យចូលរួមក្នុងវគ្គអប់រំដែលរៀបចំឡើងដើម្បីបង្ហាត់បង្រៀន ឬក៏អប់រំអ្នកដែលនៅក្នុងស្រុក ថ្នាក់ស្រុក ។ នៅក្នុងករណីមួយចំនួនទៀត ឧទាហរណ៍នៅក្នុងវគ្គអប់រំមួយចំនួន

ដែលខ្ញុំបានកំណត់វាថា វាជាមីទ្ទិង ឧទាហរណ៍ដូចជាការរៀបចំមីទ្ទិងនៅពហុកីឡដ្ឋានជាតិ ដែលយើងឃើញមានសមាជិកជាច្រើនបានចូលរួមនៅក្នុងវគ្គអប់រំ ឬមីទ្ទិងនោះ ដែលបានរៀបចំឡើង ។ អ៊ីចឹងដែលនៅក្នុងទីនោះគឺមានការចូលរួមពីថ្នាក់ជួរស្រុកនិងជួរតំបន់ផ្សេងៗ ។ ហើយចំពោះទាក់ទងទៅនឹងការប្រមូលមន្ទីរសន្តិសុខ លេខាមន្ទីរសន្តិសុខមកចូលរួមនៅក្នុងកិច្ចប្រជុំវគ្គអប់រំអីនោះ គឺខ្ញុំគិតថាដូចជាមិនដែលកើតឡើងនោះទេ ។

[១៥:៤៣:៥៧]

**ស៖** សូមអរគុណ ។ តើលោកបានដឹងដែរឬទេ ទាក់ទងទៅនឹងវគ្គអប់រំ? ប៉ុន្តែ ខ្ញុំមិនលើកឡើងអំពីមីទ្ទិងនៅក្នុងពហុកីឡដ្ឋានជាតិនោះទេ គឺខ្ញុំនិយាយអំពីវគ្គអប់រំតូចៗ ហើយលោកបានរៀបរាប់ថា នួន ជា និងខៀវ សំផន បានធ្វើការបណ្តុះបណ្តាលនិងអប់រំអំពីមាគ៌ាបក្ស ។ ថាតើលោកបានដឹងដែរឬទេ ថាតើការអប់រំនោះបានរៀបចំឡើងនៅក្នុងកម្រិតណាដែរ ដោយជនជាប់ចោទ? ហើយក្រៅពីនោះតើវាមានការរៀបចំនៅក្នុងទួលស្លែងនិងសម្រាប់បុគ្គលិកទួលស្លែងដែរឬទេ? លោកបានរៀបរាប់ និងពិភាក្សាទៅលើបញ្ហានេះហើយ ដែលថាជនជាប់ចោទគឺគាត់បានចូលរួមនៅក្នុងវគ្គអប់រំទាំងអស់នោះ ។

**ឆ៖** គឺខ្ញុំបានលើកឡើងទៅលើបញ្ហាហ្នឹង ។ ក្រៅវគ្គអប់រំរបស់ស-២១ ដែលរៀបចំឡើងពីពេលមួយទៅពេលមួយ ដោយជនជាប់ចោទខ្លួនឯងនោះ អ្នកដឹកនាំជាន់ខ្ពស់ស-២១ ដែលយើងគិតថាពួកគេចូលរួមក្នុងវគ្គអប់រំ គឺនៅក្នុងជួរនៃវគ្គអប់រំអគ្គសេនាធិការ ។ វគ្គអប់រំនេះ គឺផ្តោតទៅលើការសិក្សាអំពីមាគ៌ាចាត់តាំងរបស់បក្ស គឺយើងអាចនិយាយថា អំពីគោលនយោបាយ ដែលធ្វើឡើងដោយ សុន សេន និងអ្នកជួរដឹកនាំរបស់មជ្ឈិមបក្ស ដែលគាត់នឹងមកចូលរួម ហើយធ្វើការបណ្តុះបណ្តាលនៅក្នុងជួរវគ្គអប់រំផ្នែកយោធានោះ ។

**ស៖** សូមអរគុណចំពោះចម្លើយនេះ ។ ខ្ញុំសូមចូលទៅដល់សំណួរចុងក្រោយរបស់ខ្ញុំ ។ យោងតាមការស្រាវជ្រាវរបស់លោក អ្វីដែលយើងបានឮព្រឹកមិញនេះពីជនជាប់ចោទ ដែលគាត់បាននិយាយម្តងហើយម្តងទៀតៗ អំពីរចនាសម្ព័ន្ធ តើវាជាការពិតដែរឬទេ ដែលថាសុន សេន គឺបានចាត់តាំងការងារ និងភារកិច្ចមួយចំនួនដោយខ្លួនគាត់ផ្ទាល់ ដែលក្នុងនោះរួមមានការសម្លាប់ដប់នាក់ក្នុងមួយថ្ងៃ? ផ្អែកតាមការពិនិត្យចម្លើយសារភាពរបស់ជនជាប់ចោទ តើមានដែរឬទេក្នុងករណីនេះ?

**ស៖** សូមអរគុណលោកស្រីមេធាវី វាជាសំណួរមួយដែលគួរឲ្យចាប់អារម្មណ៍ ។ ខ្ញុំសូមលើកឡើងថា សុន សេន គឺជាសមាជិកគណៈអចិន្ត្រៃយ៍ ។ សុន សេន គឺជាឧបនាយករដ្ឋមន្ត្រី ដែលទទួល

បន្ទុកផ្នែកការពារជាតិ ។ គាត់គឺជាអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ដូច្នេះគាត់មានតួនាទីច្រើន ហើយដោយសារបញ្ហានេះគឺ គាត់ជាបុគ្គលម្នាក់ដែលរវល់នឹងការងាររបស់គាត់ ។ ព្រឹកមិញនេះ ជនជាប់ចោទបានរៀបរាប់ជូនយើងទាំងអស់គ្នា ហើយខ្ញុំសូមដកសម្ដីថា “មេរបស់ខ្ញុំគឺបានយកចិត្តទុកដាក់ទៅលើការសួរចម្លើយអ្នកទោសសំខាន់” សូមបញ្ចប់ការដកស្រង់សម្ដីនេះ ។ ចម្លើយនេះ គឺវាអាចជឿជាក់បាន ដែលថា សុន សេន គឺគាត់ទទួលបន្ទុកក្នុងការធានាសន្តិសុខផ្ទៃក្នុង ។

[១៥:៤៩:00]

ដូច្នេះហើយ គឺគាត់យកចិត្តទុកដាក់ទៅលើការសួរចម្លើយចំពោះអ្នកទោសសំខាន់ៗមួយចំនួនរួមទាំងធានាដល់ការកម្ទេចទៅដល់អ្នកទាំងអស់នោះ ក្រោយពីការសួរចម្លើយបានចប់សព្វគ្រប់ ។ ប៉ុន្តែនៅពេលដែលយើងធ្វើការពិនិត្យបញ្ជីអ្នកទោសរួម ដែលរៀបចំឡើងដោយសហព្រះរាជអាជ្ញា យើងយល់ឃើញថា បុគ្គលមួយចំនួន ដែលបញ្ជូន និងធ្វើការគិតគូរតាមរយៈស-២១ គឺត្រូវបានគេចាត់ទុកថាវាមិនមានលក្ខណៈសំខាន់ ដែលយើងគិតអំពីតួនាទីនិងឋានានុក្រម ។ ឧទាហរណ៍នៅក្នុងក្រសួងសង្គមកិច្ច អ្នកកសិករដែលមិនចេះដឹងមួយចំនួន គឺត្រូវបានគេអប់រំក្នុងរយៈពេលខ្លី ដែលបង្រៀនអំពីការចាក់តាមរយៈស៊ីរ៉ាំង ការចាក់ថ្នាំ ហើយក្រោយមកឲ្យអនុវត្តការងារនៅក្នុងមន្ទីរពេទ្យ ។

យើងឃើញមានចំនួន អ្នកទាំងអស់នោះចំនួនច្រើនត្រូវបានរងទារុណកម្ម និងសម្លាប់ចោលនៅស-២១ ដោយរងការចោទប្រកាន់ថា ជាភ្នាក់ងារ សេអ៊ីអា ឬក៏ភ្នាក់ងារ កាហ្សេបេ ។

ចំណុចនេះ វាជាពិបាកសម្រាប់ខ្ញុំ ដើម្បីធ្វើឲ្យខ្ញុំជឿថា បុគ្គលម្នាក់ដែលទទួលការងារជាតិដូចលោក សុន សេន នេះគឺគាត់នឹងចំណាយពេលយ៉ាងច្រើនទៅលើការងារសួរចម្លើយ និងការងារពិនិត្យទៅលើចម្លើយសារភាពនៅស-២១ ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

សូមអរគុណ ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយនេះ គឺមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ តើមានសំណួរអ្វី? អញ្ជើញមេធាវី?

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរតែមួយសំណួរទេដើម្បីសួរទៅអ្នកជំនាញ ។ សំណួរ

របស់ខ្ញុំពាក់ព័ន្ធទៅនឹងលិខិតឆ្លើយឆ្លងតាមរយៈខ្សែបណ្ដោយ ។ នៅក្នុងគោលនយោបាយបក្សកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលមានទំនាក់ទំនងការងារ គឺត្រូវតែធ្វើទៅតាមរយៈខ្សែបណ្ដោយ មិនអាចធ្វើទៅតាមរយៈខ្សែទទឹងបានទេ ។ ដូច្នេះ ហើយខ្ញុំចង់សួរថា តើរាល់លិខិតស្នាមដែលធ្វើឡើងរវាងមន្ទីរស-២១ ទៅកាន់ភូមិភាគនានានៅទូទាំងប្រទេស គឺត្រូវឆ្លងកាត់តាមរយៈថ្នាក់លើ គឺលោក សុន សេន ។

**ស៖** ដូច្នេះតាមរយៈការស្រាវជ្រាវរបស់លោក ខ្ញុំចង់សួរថា តើនៅពេលដែលលោក សុន សេន ទទួលបានលិខិតឆ្លើយឆ្លងនោះ តើគាត់ចាំបាច់ត្រូវតែធ្វើចំណារទៅលើលិខិតនោះ ឬមួយក៏ចុះហត្ថលេខាទៅលើលិខិតនោះ មុននឹងធ្វើការបញ្ជូនបន្តទៀតទៅថ្នាក់ក្រោមរបស់គាត់?

[១៥:៥៣:៤៧]

**ឆ៖** សូមអរគុណមេធាវី ។ ចំពោះបញ្ហានៃការទាក់ទងរវាង ស-២១ និងតំបន់ដែលនៅឆ្ងាយៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យើងត្រូវពិចារណា តើវាមានមធ្យោបាយទំនាក់ទំនងយ៉ាងម៉េចនៅក្នុងប្រទេសទាំងមូល? ហើយជាការពិតមធ្យោបាយនោះគឺមានលក្ខណៈកម្រិត ។ ក្រៅពីការបញ្ជូនដោយផ្ទាល់តាមរយៈនីរសារ ហើយដែលបញ្ហានេះ វាជាការពិបាកនៅក្នុងប្រទេសទាំងមូល ។ ដូច្នេះយើងចាំបាច់ត្រូវប្រើប្រព័ន្ធ *អេឡិចត្រូនិច* គឺវិធីសាស្ត្រទំនាក់ទំនងតាមលក្ខណៈ*អេឡិចត្រូនិច* ។ ខ្មែរក្រហម អង្គការខ្មែរក្រហម គឺធ្វើការទំនាក់ទំនងតាមរយៈទូរលេខ ។ យើងឃើញមានទូរលេខនោះ គឺត្រូវបានគេគ្រប់គ្រងយ៉ាងហ្មត់ចត់ដោយមជ្ឈិមបក្ស នៅក្នុងការិយាល័យក១ ហើយយើងឃើញមានកំណត់សម្គាល់មួយទៀតដែលធ្វើការគ្រប់គ្រងដោយអគ្គសេនាធិការ គឺ សុន សេន ខ្លួនឯង ។

ទោះបីជាយើងមិនមានព័ត៌មានពិស្ដារច្រើនទៅលើបញ្ហានេះ ស្ដីអំពីការអនុវត្តការទំនាក់ទនងនោះយ៉ាងណាក៏ដោយ ខ្ញុំគិតថាយើងអាចសន្និដ្ឋានបានថា នៅពេលដែលការទំនាក់ទំនង ឬសារដែលថាត្រូវបញ្ជូនទៅស-២១ នោះ គឺយើងនឹងឃើញមាននីរសារបញ្ជូនទៅមណ្ឌលគីរីជាដើមតាមរយៈនីរសារហើយមានលេខកូដ និងធ្វើការទំនាក់ទំនងទៅដល់ទីនោះតាមរយៈនីរសារនិងក្នុងជួរអគ្គសេនាធិការ ។

ខ្ញុំអាចធ្វើការពិភាក្សាទៅលើបញ្ហានេះ ប៉ុន្តែ វាជាបញ្ហាមួយ ព័ត៌មានពិស្ដារដែលយើងមានលើករណី គឺវាជាផ្នែកមួយនៅក្នុងរឿងលេខ២ ហើយនៅពេលនេះសំណុំរឿងនេះស្ថិតនៅក្រោមការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដោយសារបញ្ហានេះ ករណីនេះវានៅតែជាចំណុចមួយសម្ងាត់នៅឡើយនៅពេលនេះ ។ ប៉ុន្តែ អ្វីដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ តើឆ្លើយតបទៅនឹងសំណួររបស់មេធាវីដែរឬទេ?

[១៥:៥៧:២៩]

**ស៖** សូមទោស ។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺពាក់ព័ន្ធទៅលើលិខិតដែលឆ្លើយឆ្លងរវាងលោក ឌុច ជាមួយនឹងលោក ស៊ូ ម៉េត ដែលគាត់ធ្វើជាលិខិត ដែលពាក់ព័ន្ធលិខិតរបស់គាត់ហ្នឹងគឺមានរូបភាពហាក់បីដូចជាធ្វើឡើងរវាងលោក ឌុច ផ្ទាល់ជាមួយនឹង ស៊ូ ម៉េត តែម្តង គឺតាមសម្តីរបស់គាត់ពីព្រឹកមិញ គឺគាត់និយាយថារាល់លិខិតហ្នឹង គឺមានការឆ្លងកាត់តាមរយៈថ្នាក់ដឹកនាំរបស់គាត់គឺលោក សុន សេន ។ ហើយអ៊ីចឹងខ្ញុំគ្រាន់តែចង់ដឹងថា តើនៅពេលដែលលោក សុន សេន ទទួលបានលិខិតនោះ តើគាត់មានធ្វើចំណារអ្វីដើម្បីបញ្ជាក់ថា គាត់បានទទួលលិខិតនោះ ហើយទើបបានផ្ញើបន្តទៀតទៅភាគីម្ខាងទៀត ឬក៏ភាគីម្ខាងទៀតត្រឡប់មកគាត់វិញ? តាមការស្រាវជ្រាវរបស់លោក តើលោកមានបានពិនិត្យឃើញទៅលើចំណុចហ្នឹងដែរ ឬក៏យ៉ាងម៉េច?

[១៥:៥៨:៣៨]

**ឆ៖** សូមអរគុណចំពោះការបំភ្លឺទៅលើចំណុចនេះ ។ ចម្លើយរបស់ខ្ញុំនោះ គឺថាពិតជាមានមែនចំពោះចំណារ ។ យើងឃើញមានករណីមួយចំនួនដែលមាននៅក្នុងសំណុំរឿងដែលថា ឯកសារបញ្ជូនពី ស-២១ ដែលក្រោយមកឯកសារទាំងអស់នោះត្រូវបានចារដោយ សុន សេន ។ ហើយបន្ទាប់ពីធ្វើចំណារគឺមានការបែងចែកទៅដល់អង្គភាពផ្សេងៗ ដូចជាកងពល៥០២ ។ ហើយចំពោះកងពល៥០២ នេះ គឺយើងឃើញមានទីតាំងនៅពោធិ៍ចិនតុង អាកាសយានដ្ឋានពោធិ៍ចិនតុង ហើយវាមានទីតាំងជិតនៅទីបញ្ជាការរបស់ សុន សេន ហើយវាជាបញ្ហាមួយមានលក្ខណៈងាយស្រួលក្នុងការបញ្ជូនលិខិត ឬក៏សារផ្សេងៗទៅវិញទៅមករវាងលេខា៥០២ និង សុន សេន ។

ជាការពិត បញ្ហានេះ គឺវាមានលក្ខណៈងាយស្រួលសម្រាប់ សុន សេន ក្នុងការហៅលេខា៥០២ ហើយធ្វើការចារទៅលើឯកសារផ្សេងៗដែលត្រូវការបញ្ជូនទៅទីនោះ ។

**ស៖** ខ្ញុំសូមសរុបនូវអ្វីដែលលោកមានប្រសាសន៍បន្តិច ថាតើអ្វីដែលខ្ញុំយល់ហ្នឹងគឺស្របគ្នាជាមួយនឹងលោក ឬមួយក៏ មានន័យថា រាល់លិខិតស្នាមដែលមានការផ្ញើពីមន្ទីរស-២១ គឺសុទ្ធតែមានចំណារនៅពេលដែលលិខិតនោះទៅដល់ថ្នាក់ដឹកនាំ គឺលោកគ្រូ សុន សេន ។ តើមែនទេ?

**ឆ៖** មិនមែនអ៊ីចឹងទេ លោកស្រីមេធាវី ខ្ញុំមិនជឿថា ចំណុចនេះជាការត្រឹមត្រូវនោះទេ ។ ជាឧទាហរណ៍នៅក្នុងអំឡុងពេលក្រោយពីខែកញ្ញា ឆ្នាំ១៩៧៧ មកយើងមានឧទាហរណ៍ជាច្រើនស្តីអំពីឯកសារ ដែលមិនមានចំណារផ្ទាល់ដៃទៅលើឯកសារទាំងនុ៎ង ដែលយើងអាចសន្និដ្ឋានថា នេះមិនមែន

ជាការចាំបាច់ទេ ហើយមិនដឹងថា តើឯកសារត្រូវបានគេប្រគល់ទៅឲ្យ សុន សេន ដែរឬក៏អត់? ហើយយើងក៏មានឧទាហរណ៍នៃឯកសារមួយចំនួននៅពេញផ្ទាំងប្រតិបត្តិការនៃមន្ទីរស-២១ ដែលមិនមានចំណារជាលាយលក្ខណ៍អក្សរដោយផ្ទាល់ដៃទេ ។ ហើយឯកសារអស់ទាំងនេះ អាចត្រូវបានគេបញ្ជូនឲ្យទៅភាគី ឬក៏ភាគីនានា ក៏ប៉ុន្តែ មិនមានការបង្ហាញថាមានចំណារដៃនៅលើឯកសារនោះទេ ។

[១៦:០២:២៤]

**ស៖** អ៊ីចឹងខ្ញុំសូមបន្តដើម្បីបញ្ជាក់បន្ថែម គឺខ្ញុំគ្រាន់តែចង់សួរទៅលោកថា តើនៅពេលដែលលិខិតស្នាមមួយដែលបញ្ជូនរវាងថ្នាក់ក្រោមទៅថ្នាក់លើឆ្លងកាត់តាមរយៈលោក សុន សេន បានន័យពីមន្ទីរស-២១ ទៅភូមិភាគ ឬក៏ទៅកងពល គឺត្រូវតែឆ្លងតាមរយៈលោក សុន សេន ។

ខ្ញុំចង់សួរថា តើមានការកំណត់សម្គាល់យ៉ាងម៉េច ដើម្បីឲ្យដឹងតើលិខិតហ្នឹងបានដល់ដៃលោក សុន សេន ហើយទើបបានឈានទៅដល់ភាគីម្ខាងទៀត? តាមការស្រាវជ្រាវរបស់លោក តើលោកមានសង្កេតឃើញត្រង់ចំណុចហ្នឹងដែរឬទេ? មានអីជាកំណត់សម្គាល់ដែរឬទេ?

**ឆ៖** សូមអរគុណលោកស្រីមេធាវី ។ គឺថាមានវិធីដ៏ច្រើនសម្រាប់បញ្ជាក់អំពីព័ត៌មានទាំងនេះ ឬដើម្បីបញ្ជាក់ថាឯកសារហ្នឹងជាឯកសាររបស់ ស-២១ ឬក៏ជាចម្លើយសារភាពរបស់ ស-២១ ឬក៏ជាប្រភេទឯកសារដទៃទៀត ។ ជាឧទាហរណ៍ឯកសារនោះ អាចនឹងមានចំណារផ្ទាល់ដៃនៅខាងលើ ដែលនិយាយថា “ផ្ញើជូនបង” ឬមួយអាចមានការសរសេរថា “ចម្លងជូន នួន” ឬមួយក៏អាចនិយាយថា “បានរាយការណ៍រួចហើយ” ឬមួយអាចមានសរសេរថា “មួយច្បាប់បញ្ជូនទៅខាងភូមិភាគពាយ័ព្យ” គឺថាមិនមានទម្រង់ជាផ្លូវ ឬក៏វិធីជាផ្លូវការនោះទេ ក៏ប៉ុន្តែយើងឃើញមានវិធីដែលមិនមែនជាផ្លូវការដ៏ច្រើនក្នុងដែលត្រូវបានគេបង្ហាញ ឬក៏ប្រើប្រាស់នៅលើឯកសារអត់ទាំងហ្នឹង ។ ថាតើពេលណាដែលគេបានចារលើ ហើយពេលណាដែលគេបានបញ្ជូនឯកសារនោះទៅ?

**ស៖** ខ្ញុំសូមបន្តទាក់ទៅនឹងលិខិតមួយ ដែលលិខិតហ្នឹងលើកឡើងដល់ខាងសហព្រះរាជអាជ្ញា ប្រសិនបើលិខិតហ្នឹងខ្ញុំលើកឡើងខុស ខ្ញុំសូមឲ្យខាងសហព្រះរាជអាជ្ញាមេត្តាជួយបញ្ជាក់ ។ លិខិតហ្នឹងមានលេខERN0002416 ជាភាសាខ្មែរ ។ ខ្ញុំពុំបានដឹងលេខកូដជាភាសាអង់គ្លេសទេ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

បើសិនជាខ្ញុំអាចជួយបាន លោកប្រធាន នេះគឺជាឯកសារដែលចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧ ដែល ស៊ូ ម៉េត ផ្ញើទៅឲ្យ ឌុច ដែលមាន D57 ភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយនៅ

ថ្ងៃ២ ខែមេសា ឆ្នាំ២០០៨ ដែលមានលេខERN001766 ។ 002488 ជាភាសាបារាំង ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធាន នេះគ្រាន់តែជាការអង្កេតការរបស់ខ្ញុំ ខ្ញុំយល់ថា សហសេវិករបស់ខ្ញុំបានសួរទៅលើសំបុត្រដែល ឌុច បានសរសេរទៅឲ្យបុគ្គលដទៃទៀត ក៏ប៉ុន្តែតាមភាពជាក់ស្តែងឯកសារដែលយើងពឹងផ្អែកជាឯកសារមូលដ្ឋាននេះ គឺផ្ទុយពីនេះទៅវិញ ។ មានន័យថា នោះគឺជាសំបុត្រដែលមនុស្សម្នាក់បានផ្ញើមកឲ្យ ស-២១ តាមរយៈ សុន សេន នោះ ។ ខ្ញុំចង់ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំណុចនេះ ហើយនិងសំណួរដែលត្រូវបានសួរទៅលើអ្នកជំនាញ គឺថាទាក់ទងទៅនឹងសំបុត្រដែលគេផ្ញើមកស-២១ ឬក៏ ស-២១ ផ្ញើទៅភូមិភាគនោះ តាមរយៈ សុន សេន ។

អញ្ចឹងឥឡូវនេះ យើងនិយាយពីទិសដៅនៃការបញ្ជូនលិខិតពីណា ទៅណានេះ?

**កញ្ញា ទី ស្រ៊ីនណា៖**

ខ្ញុំសូមបញ្ជាក់ជូនប្រធាន មូលហេតុដែលខ្ញុំលើកករណីនេះឡើង គឺករណីនេះ គឺគេគ្រាន់តែជាឧទាហរណ៍មួយដែលខ្ញុំត្រូវការសួរទៅអ្នកជំនាញ ។ ពីព្រោះថាមានលិខិតស្នាមជាច្រើនដែលបានផ្ញើពីមន្ទីរស-២១ ទៅកាន់តំបន់ផ្សេង ភូមិភាគ ហើយក៏មានលិខិតជាច្រើនដែរ ដែលត្រូវផ្ញើពីភូមិភាគមកកាន់មន្ទីរស-២១ វិញ ជាពិសេសគឺទាក់ទងទៅនឹងចម្លើយសារភាពរបស់អ្នកទោសនៅក្នុងមន្ទីរស-២១ ដែលត្រូវឆ្លើយទៅពាក់ព័ន្ធទៅនឹងបុគ្គលផ្សេងទៀត ។ ដូច្នេះហើយ ទើបខ្ញុំលើកជាឧទាហរណ៍នៅក្នុងលិខិតនេះមួយ ដើម្បីសួរទៅកាន់អ្នកជំនាញ ពីព្រោះលិខិតនេះក៏មានលក្ខណៈសំខាន់នៅក្នុងការពាក់ព័ន្ធទៅនឹងរឿងនេះដែរ ។

**ប្រធានអង្គជំនុំ៖**

លិខិតដែលមេធាវីលើកឡើងហ្នឹង នៅក្នុងចំណោមលិខិតទាំងប្រាំបួន ដែលលើកពិភាក្សាព្រឹកមិញហ្នឹងមែនទេ?

[១៤:០៩:០៤]

សូមអញ្ជើញបើសិនជាលិខិតពីព្រឹកមិញ គឺយើងអាចធ្វើការពាក់ព័ន្ធបានហើយ ព្រោះពិនិត្យព្រឹកមិញគឺលិខិតតែទម្រង់តែមួយទេ គឺពីឈ្មោះ ម៉េត មកស-២១ នៅក្នុងទម្រង់ទាំងអស់ដែលយើងដាក់ពិភាក្សានេះ ។ យើងអនុញ្ញាតឲ្យពិភាក្សាតាំងពីមុនមក ។ គោរពអញ្ជើញ ។

**កញ្ញា ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំសូមសួរទៅលោកបណ្ឌិត តើលោកបណ្ឌិតធ្លាប់ឃើញលិខិតមួយនេះជាច្បាប់ដើមដែរឬទេ? លិខិតដែលខ្ញុំបានលើកលេខ ERN ជូនអង្គសវនាការអម្បាញ់មិញ?

[១៦:១០:០០]

**ឆ៖** សូមអរគុណ លោកស្រីមេធាវី ។ ខ្ញុំបានឃើញឯកសារជា ភាសាខ្មែរ ជាឯកសារដើម ខ្ញុំគិតថា ខាងអង្គសវនាការ ឬក៏សហព្រះរាជអាជ្ញា បានធ្វើការបែងចែកនូវឯកសារទាំងប្រាំបួន ដែលយើងបានពិភាក្សាគ្នានេះ ឲ្យទៅខាងភាគីពាក់ព័ន្ធរួចហើយ ។ ប៉ុន្តែ ពួកគេមិនបានធ្វើការបែងចែកលិខិតចម្លងទាំងប្រាំបួននោះមកឲ្យខ្ញុំទេ ។ អ៊ីចឹង ខ្ញុំមិនដឹងថា តើឯកសារខ្មែរដែលជាច្បាប់ដើម ឬក៏ការបកប្រែជាភាសាអង់គ្លេសដែលខ្ញុំមាន ដើម្បីពិនិត្យមើលនោះទេ ។ ហើយដូច្នេះ ខ្ញុំសូមទោសប្រសិនបើខ្ញុំមិនអាចចាំឯកសារមួយនេះទៅតាមការចងចាំរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញា អាចបង្ហាញលិខិតជាអង់គ្លេស ដើម្បីឲ្យលោកអ្នកជំនាញអាចទទួលយកបាននូវឯកសារនេះទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

បាទ យើងអាចសូម លោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ថា អ្វីដែលលោក អេតឆេសាន់ បាននិយាយនោះគឺថា សហព្រះរាជអាជ្ញាបានផ្តល់ទៅឲ្យភាគីពាក់ព័ន្ធទាំងអស់នូវបញ្ជីឈ្មោះឯកសារ ប៉ុន្តែ មិនបានប្រគល់ឯកសារនោះទេ គ្រាន់តែបញ្ជីតែប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំអាចផ្តល់ឯកសារជាភាសាអង់គ្លេសបាន ។

ខ្ញុំមិនដឹងថា តើលោកប្រធានចង់ដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់ ឬក៏អត់ទេ? បើសិនជាចង់នោះ គឺថាយើងអាចធ្វើបាន ដោយឲ្យខាងផ្នែកសោតទស្សន៍ដាក់បញ្ចាំងកុំព្យូទ័ររបស់យើងនៅលើអេក្រង់តែម្តង ។

**ប្រធានអង្គជំនុំ៖**

ដើម្បីឲ្យបានច្បាស់ លោកខាងអ្នកជំនាញសោតទស្សន៍ សុំភ្ជាប់មកកុំព្យូទ័ររបស់ខាងផ្នែកតំណាងសហព្រះរាជអាជ្ញា ដើម្បីបង្ហាញពីឯកសារនេះដល់អង្គជំនុំជម្រះ ក៏ដូចជាអង្គសវនាការទាំងមូល ដើម្បីបានយល់ ។

**កញ្ញា ទី ស្រ៊ីនណា៖**

ខ្ញុំសូមបន្តទៀត ដោយសារតែលិខិតនេះ បានបង្ហាញនៅក្នុងអេក្រង់កុំព្យូទ័រហើយ អ៊ីចឹង ខ្ញុំសុំសួរលោកអ្នកជំនាញ លោកបណ្ឌិតបន្តទៀត ។ ពាក់ព័ន្ធទៅនឹងលិខិតនេះ គឺលិខិតនេះ គឺលិខិតហ្នឹង គឺខ្ញុំពិនិត្យទៅឃើញថា ពុំមានចំណារ ឬមួយក៏ហត្ថលេខារបស់លោក សុន សេន ដែលគាត់ជាបុគ្គលថ្នាក់ដឹកនាំខ្ពស់ ដែលលិខិតនេះត្រូវឆ្លងកាត់រយៈគាត់ ។

អ៊ីចឹង ខ្ញុំចង់សួរថាតើលោកយល់យ៉ាងម៉េចដែរ នៅពេលដែលលិខិតនេះពុំមានចំណារ ឬមួយក៏ហត្ថលេខារបស់លោក សុន សេន? តើលិខិតនេះមានការផ្ញើហ្នឹងពិតជាមានការឆ្លងកាត់តាមរយៈគាត់ដែរ ឬមួយក៏យ៉ាងម៉េច? សូមលោកជំនាញជួយបំភ្លឺ ។

[១៦:១៣:៤៥]

**លោក គង់ ពិសី៖**

សូមអនុញ្ញាតបន្តិច សូមកាត់បន្តិច ។ ខ្ញុំសុំរំខានបន្តិចត្រង់ចំណុចថា លិខិតនេះ គឺជាភាសាអង់គ្លេស ហើយយើងតែប្រើលិខិត ដែលជាភាសាដើម ភាសាខ្មែរ ឥឡូវយើងមានភាសាខ្មែរ យើងគួរតែប្រើភាសាខ្មែរ ពីព្រោះថា មេធាវីខាងសហសេវិករបស់ខ្ញុំ គាត់លើកឡើងថា ក្នុងលិខិតមានចំណារ ឬក៏គ្មាន ។ អ៊ីចឹង ការចំណារនោះគឺវាសំខាន់បំផុត គឺនៅលើភាសាដើម ។ អ៊ីចឹង គួរដាក់ភាសាខ្មែរវាសំខាន់ជាងបាទ ។ សូមអធ្យាស្រ័យ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ការដែលយើងរៀបចំនេះ គឺគោលដៅដែលអ្នកជំនាញ គាត់អត់បានយល់អំពីថា លិខិតណាមួយត្រូវលើកយកមកពិភាក្សានៅពេលនេះទេ ដោយគាត់លើកជាភាសាខ្មែរ ហើយវាទាមទារជាភាសាដើមទៀត ។ អ៊ីចឹង ភាសាខ្មែរ ភាសាដើមឥឡូវហ្នឹង ក៏យើងអត់មានដែរ ប៉ុន្តែឯកសារដែលដាក់នេះ គឺយើងចាត់ទុកថា ជាឯកសារដើម ជាភាសាខ្មែរ ។ ប៉ុន្តែ ដែលការយើងដាក់បញ្ចាំងនេះ គឺគាត់ចង់ដឹងថាឯកសារណាមួយដែលមេធាវីកំពុងតែដាក់មកពិភាក្សានេះ ។ បើយើងដាក់ភាសាខ្មែរនោះ បានន័យថា គាត់អត់យល់អំពីខ្លឹមសារនៃលិខិតទេ នេះដែលជាជំហរដែលយើងបានដាក់នេះ ។

ហើយប្រសិនបើយើងអាចបញ្ជាក់ពីបញ្ហាចំណារ គឺយើងអាចប្រើវិធីផ្សេងទៀត បានន័យថា ទាល់តែបង្ហាញនូវឯកសារជាភាសាខ្មែរ ថាតើមានចំណារឬអត់? ពីព្រោះជាភាសាដែលបកប្រែនេះ គឺមិនមានការបកប្រែទាំងចំណារ ឧទាហរណ៍អ៊ីចឹង។ អាហ្នឹង បានវាបាន អ៊ីចឹងអាចលក្ខខណ្ឌពីរហ្នឹង

ខុសគ្នា រវាងតម្រូវការនៃការបង្ហាញ ។

ឥឡូវនេះ លោកបណ្ឌិតអាចយល់ហើយអំពីខ្លឹមសារនៃលិខិត ដែលពាក់ព័ន្ធនឹងសំណួរនេះមានការប៉ុនប៉ងសួរដោយមេធាវីរូបនេះ ជាសំណួរពាក់ព័ន្ធនឹងសំណួរនេះ ។ ឥឡូវដើម្បីបញ្ជាក់ ពីព្រោះការសួរនេះមានការពាក់ព័ន្ធនឹងចំណារ ដែលពាក់ព័ន្ធនឹងឯកសារភាសាខ្មែរ ក្រែងលោថាចំណារហ្នឹងមិនមានការបកប្រែ មិនដឹងជាបកប្រែថាយ៉ាងម៉េចទេ? អ៊ីចឹង ដើម្បីឲ្យច្បាស់ សូមខាងសហព្រះរាជអាជ្ញាបញ្ចាំងពីឯកសារនេះដដែល ប៉ុន្តែជាភាសាខ្មែរ ។

[១៦:១៦:៣១]

មេធាវីសួរ តាំងសំណួរសារជាថ្មីម្តងទៀត ចំពោះលោកអ្នកជំនាញ សំណួរចុងក្រោយអម្បាញ់មិញនេះ ។

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

**ស៖** សូមអរគុណ លោកប្រធានដែលជួយសម្របសម្រួល ។ នាងខ្ញុំចង់សួរថា នៅក្នុងលិខិតមួយនេះដែលនៅក្នុងអេក្រង់នេះ តើអ្នកជំនាញយល់ឃើញយ៉ាងម៉េចដែរ ពីព្រោះនៅលើលិខិតនេះពុំមានចំណាររបស់លោក សុន សេន ដែលអាចបញ្ជាក់ថា១ លិខិតនេះក៏មានការឆ្លងកាត់តាមរយៈលោក សុន សេន ដែរ ។ តើតាមការស្រាយជ្រាវរបស់លោក តើបើមានអ្វីមូលដ្ឋានកំណត់អ្វី ដែលដឹងដែលថាលិខិតនេះមានការឆ្លងកាត់តាមរយៈលោក សុន សេន?

**ឆ៖** សូមអរគុណ កញ្ញាមេធាវី ។ កញ្ញាបានលើកឡើងនូវសំណួរមួយ គួរឲ្យចាប់អារម្មណ៍ ។ ដូចដែលខ្ញុំបានពិភាក្សាមុននេះបន្តិច យើងបានដឹងថា កាលពីថ្ងៃ៣០ ខែមីនា ឆ្នាំ៧៦ ឯកសារដែលជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមនោះ គឺថា សេនាធិការជាអ្នកទទួលបន្ទុកទៅលើនយោបាយក្នុងការកម្ទេចខ្មាំងនៅក្នុងកងទ័ពមជ្ឈិម ។ ហើយយើងក៏បានដឹងដែរ តាមប្រភពនានា ដែលថា កងពល៥០២ គឺជាផ្នែកមួយនៃកងទ័ពមជ្ឈិម ហើយយើងក៏បានដឹងដែរថា ស៊ូ ម៉េត គឺជាលេខានៃកងពល៥០២ ហើយយើងក៏ដឹងដែរថា សុន សេន គឺជាអគ្គសេនាធិការ ។

ដូច្នេះ ទៅតាមប្រភពព័ត៌មានអស់ទាំងនេះ យើងមានហេតុផលដើម្បីធ្វើការសន្និដ្ឋានថា សារ ឬក៏លិខិតនានា ទាក់ទងនឹងខ្មាំងនៅតាមកងពលនេះ គឺដែលត្រូវឆ្លងកាត់ សុន សេន ដើម្បីបញ្ជូនមកស-២១ ។ ក៏ប៉ុន្តែ នៅពេលដែលមានអវត្តមាននៃការបង្ហាញផ្សេងពីនេះ មិនមានព័ត៌មានណា ថាតើឯកសារនេះត្រូវបានចែកទៅ ឬក៏បញ្ជូនទៅ ឬក៏បញ្ជូនតាមរយៈជាជាងទៅលើអ្វី ដែលមានចារនៅលើលិខិតនេះ

ផ្ទាល់ ។ នៅក្នុងករណីបែបនេះ យើងអាចអាស្រ័យទៅលើទ្រឹស្តី ដែលខ្ញុំមានទៅតាមប្រតិបត្តិការរបស់របបនោះ ទៅតាមឯកសារដែលខ្ញុំមាន គឺមានន័យថា យើងត្រូវអាស្រ័យទៅលើពាក្យសម្តីរបស់ជនជាប់ចោទ ថាតើលិខិតហ្នឹងពិតជាបានឆ្លងកាត់ សុន សេន? ពីព្រោះអីគឺថា មិនមានភស្តុតាងណាផ្សេងពីនេះវិញទេ ។

[១៦:២០:៤៥]

**កញ្ញា ទី ស៊្រីនណា៖**

សូមអរគុណ ។ ខ្ញុំសូមអស់សំណួរ ហើយខ្ញុំសូមផ្ទេរសំណួរខាងសហមេធាវីបរទេសរបស់ខ្ញុំ ក៏មានសំណួរបន្តទៀតដែរ អ៊ីចឹង សុំការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់វេទិកានេះជូនសហមេធាវីអន្តរជាតិរបស់ខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីអន្តរជាតិក្រុមមួយ ។ ប៉ុន្តែសុំខាងសោតទស្សន៍បង្វែរអេក្រង់ទូរទស្សន៍នោះទៅប្រក្រតីភាពវិញ ។

**លោក អាឡាំង វែនណឺ៖**

សូមគោរព លោក លោកស្រីចៅក្រម ។ គឺខ្ញុំមានពេលប្រហែលជាដប់នាទីជាង ហើយគឺខ្ញុំនឹងមានសំណួរសម្រាប់អ្នកជំនាញ ហើយខ្ញុំគិតថា ខ្ញុំគួរ ឬមិនគួរធ្វើការតាំងសំណួរនៅពេលនេះ គឺអាស្រ័យទៅលោកចៅក្រមជាអ្នកកំណត់ និងសម្រេច ។

**ប្រធានអង្គជំនុំ៖**

ឥឡូវ ម៉ោងបួនម្ភៃនាទីហើយ យើងជាការកំណត់កាលវិភាគក្នុងការសវនាការថា ម៉ោងបួនដប់ប្រាំនាទីទេ ។ ហើយការប្រឹងប្រែងតទៅទៀត លុះត្រាការប៉ាន់ស្មានវាអាចចប់ដោយដំណើរការសវនាការនេះអាចក្រុមមួយ នៅមានសំណួរពាក់ព័ន្ធ ។ ហើយម្យ៉ាងទៀត ភាគីខាងមេធាវីអ្នកតំណាងមេធាវីការពារក្តីនៅតែមិនឱកាសក្នុងការតាំងសំណួរដល់អ្នកជំនាញដដែល ។

ដូច្នេះ អង្គជម្រះសម្រេចថា ដំណើរការសវនាការនៅថ្ងៃនេះផ្អាកត្រឹមនេះ ហើយលើកទៅបន្តសវនាការនៅថ្ងៃស្អែកវេលាម៉ោងប្រាំបួនដូចសព្វដង គឺម៉ោងប្រាំបួនព្រឹក។ អ៊ីចឹងគឺ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះ នៅថ្ងៃស្អែកវេលាម៉ោងប្រាំបួន។ ហើយលោក ក្រេក អេតឆេសាន់ គឺសូមអរគុណលោកច្រើន ដែលបានអត់ធ្មត់ក្នុងការអង្គុយនៅទីនេះ

ដើម្បីឆ្លើយនឹសំណួរផ្សេងៗក្នុងនាមជាអ្នកជំនាញ ។ ហើយយើងកត់សម្គាល់ឃើញថា មានការនឿយហត់ច្រើន ដោយសារចូលដំណើរការសវនាការហ្នឹងចំណាយពេលវេលាច្រើនជាងគេ ។ ក៏ប៉ុន្តែ តាមការព្យាករណ៍នៃពេលវេលាប្រហែលជាស្អែកព្រឹកនេះ យើងអាចចប់ហើយ ។ អ៊ីចឹងគឺ អង្គជម្រះសូមអញ្ជើញលោកមក ធ្វើសក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលបាន និងរបាយការណ៍របស់លោកនេះ ជាបន្តនៅថ្ងៃស្អែកចាប់វេលាម៉ោងប្រាំបួនព្រឹកទៅ ៕

*[សវនាការផ្អាកនៅម៉ោង១៦:២៥ នាទី]*